៦

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣៣ លេខ ៦ ខែមិថុនា

ព.ស. ២៥០៤ គ.ស. ១៩៦១

– ភ្នំពេញ –

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣៣ លេខ ៦ ខែមិថុនា

ព.ស. ២៥០៤ គ.ស. ១៩៦១

ភ្នំពេញ

# ពិធីបុណ្យនៅវត្តឧណ្ណាលោម

# ប្រគេន-ថ្វាយ សម្តេចទាំងពីរព្រះអង្គ

ថ្ងៃទី ៥ មិថុនា ១៩៦១ ម៉ោង ៨ យប់ នាមហាកុដិវត្តឧណ្ណាលោម មានការជួបជុំពុទ្ធបរិស័ទជាច្រើន ក្រោមកិច្ចចាត់ចែងនៃពុទ្ធិកសមាគមកម្ពុជរដ្ឋ រៀបធ្វើពិធីបុណ្យប្រគេនមហាកុសល ចំពោះសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ ដែលកំពុងព្យាបាលព្រះនេត្រនៅប្រទេសបារាំង និងថ្វាយព្រះរាជកុសលចំពោះសម្តេចព្រះប្រមុខរដ្ឋ ជាទីគោរព និងជាទីស្នេហាស្មើជីវិតនៃយើង ដែលព្រះអង្គកំពុងព្យាបាលព្រះរោគនៅប្រទេសបារាំង ព្រមទាំងទ្រង់កំពុងបំពេញព្រះរាជបេសកកម្មនៅក្រុងហ្សឺណែវ រកសន្តិភាពជូនប្រទេសលាវនិងសាកលលោក ។

ថ្ងៃទី ៦ ខែ ឆ្នាំដដែល ម៉ោង ៩ ព្រឹក មានពិធីដាក់បាត្រព្រះសង្ឃ ៥០០អង្គ, បប់កិច្ចដាក់បាត្រ ព្រះសង្ឃស្វាធ្យាយពុទ្ធជ័យមង្គលប្រសិទ្ធិពរ ប្រគេន ថ្វាយ ចំពោះសម្តេចទាំងពីរព្រះអង្គ សូមបាន, សូមទ្រង់បានសះស្បើយព្រះរោគ និងសូមទ្រង់បានជោគជ័យមហាប្រសើរក្នុងព្រះបេសកកម្មដ៏លំបាកក្រៃលែងនេះ ។

ពិធីនេះបានចប់សព្វគ្រប់នៅវេលាម៉ោង ៩, ៤៥ នាទីព្រឹក ។

ពុទ្ធសាសនបណ្ឌិត្យសូមចូលរួមក្នុងពិធីបុណ្យដោយកតញ្ញុតាភាព ។

ពុទ្ធសាសនបណ្ឌិត្យ

NATIONALE
DU CAMBODGE
P.K. 1
1961 _ 6

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

### ផ្នែកសាសនា

ទំព័រ

- វិចារណកថា អំពីគោលសំខាន់នៃព្រះពុទ្ធសាសនា (ត) លោក ផល-ទិត្យ រៀបរៀង ៥៩៧
- ពុទ្ធជីវប្បវត្តិ (តនឹងចប់) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ៦០៨
- លោកុត្តរាភិសម័យ អ្នកឧកញ៉ា ទា-សាន អតីតរដ្ឋមន្ត្រី រៀបរៀង . . ៦១៧
- ព្រះអភិធម្មបិដក គម្ពីរព្រះយមក (ត) លោក ប៊ូ-ប៉ូ រៀបរៀង . . . ៦៣១
- មធុរសវាហិណី(ត)សម្ដេចព្រះធម្មលិខិតល្វី-ឯម ប្រែ ព្រះ ញ.ឈឹង ពិនិត្យ . . ៦៤៣
- មហោសថជាតក(ត)លោកអ៊ុម-ភនបម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្សកឹម-តួរពិនិត្យ. ៦៥២

### ផ្នែកអក្សរសាស្ត្រ

- វប្បធម៌ខ្មែរ (ត) លោក លី-ធាមតេង រៀបរៀង . . . ៦៦១
- ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការវប្បធម៌ (ត) . . . . . ៦៦៦
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ៦៦៧
- ដើមកំណើតប្រាសាទអង្គរ លោក ល្វីហ្វីណូត៍រៀបរៀង ក្រមការ ជុំ-មៅ ប្រែ· ៦៦៨
- រឿងសាមកុក (ត) ឧកញ៉ា នូ-កន ប្រែ . . . . ៦៨០
- រឿងមនុស្សចិត្តប្រែប្រួល (ត) លោក ប៊ូ-ប៉ូ រៀបរៀង . . ៦៩១
- ភូមិសាស្ត្រសេដ្ឋកិច្ចប្រទេសឥណ្ឌៀលោករ៉ូហ្សេមបែរត៍រៀបរៀងលោកញ៉ែម-ទឹមប្រែ ៦៩៩
- លទ្ធផលនៃការប្រឡងប្រជែងអក្សរសាស្ត្រទូទៅ នៃសមាគមអ្នកនិពន្ធខ្មែរ . . ៧០៩

### ផ្នែកកំណត់ទិនប្រវត្តិការណ៍

- ពិធីសម្ពោធធម្មមន្ទីរ វត្តព្រះវិហារហ្លួង ឧត្តុង . . . . . . . . . . ៧១៣

មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃជាវ ២៣០ រ០០

33e Année — No 6 — juin 1961

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

## Sommaire

### Partie religieuse

Pages

— Editorial " Les principes du Bouddhisme " ( suite ) par *M. PHAL-TITH* . . . . 597
— La Vie du Buddha ( suite et fin) par Vèn - *PANG-KHAT* . . 608
— Lok kuttara Bhisamaya par L'Oknha *TEA - SANN* . . . . . 617
— Prah Abhidhamma pitaka (Kampi Prah yamaka (suite) par *M. BOU - FO* . . . . . . 631
— Madhurasavahini (suite) traduit par Samdech Prah Dhammalikhita *LOUIS - EM*, revu et corrigé par Vèn. *NHÉAN - CHHOEUN* . . . . 643
— Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par *M. IM - PHON*, revu et corrigé par Vèn. *KEM - TO* . . . . 652

### Partie littéraire

— La Culture Khmère (suite) par *M. LY - THEAM - TENG* . . 661
— Activités de la Commission Culturelle (suite) . . . . . . . . . . 666
— Dictionnaire Sanscrit-Khmèr (suite) par Vèn. *PANG-KHAT* . . 667
— Origine d'Angkor par Louis Finôt traduite par *M. CHUM-MAU* 668
— Histoire de Sam-Kok (suite) traduite par Oknha *NOU - KAN* . . . . . . 680
— L'homme au coeur changeant (suite)par *M.BOU-FO* . . . . . . 961
— Géographie économique de l'Inde par *M ROSEMBERT*, professeur de la Faculté de Droit traduite par *M. NHEM - KHEM* 699
— Résultát du concours littéraire organisé par l'Association des Ecrivains khmèrs par *M. TRINH - HOANH* . . . . 709

### Notes et chroniques

— Fètê d'inauguration d'un sala à Vat Preah Vihean Lûong (Oudong) . . . 713

Prix d'abonnement annuel (comprenant 12 numéros): 23o|oo

## ផ្នែកសាសនា

### វិចារណកថា

# អំពីគោលសំខាន់នៃពុទ្ធសាសនា

(តមក)

លោក ជួស-ធិត្យ នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

ព្រះមុនីកោសល សូរ-ហាយ ពិនិត្យ

---

- មនុស្សក្តី តិរច្ឆានក្តី ពួករុក្ខជាតិក្តី តើកើតមកអំពីអ្វី?

— កើតមកពីធម្មជាតិដូចគ្នាទាំងអស់ ។

- បើកើតចេញពីធម្មជាតិដូចគ្នា ហេតុអ្វីក៏បានជាមានដំណើរចេះដឹងខុសគ្នា ដូចជាមនុស្ស មានការចេះដឹងជាងពួកតិរច្ឆាន និងពួករុក្ខជាតិ, តិរច្ឆាន មានការចេះដឹងជាងពួករុក្ខជាតិ?

— ព្រោះតែមាន មនោធាតុ ចាស់-ខ្ចីខុសគ្នា គឺពួករុក្ខជាតិនោះ ទើបតែនឹងកកើត មនោធាតុ ពីមូលធាតុ គឺធាតុដើមផ្ទាល់. ដូច្នេះ បានជានៅល្ងិតល្ងង់ណាស់ ស្ទើរតែមិនមានប្លែកអ្វីពីធាតុដើម គឺ ដី ទឹក ភ្លើង ខ្យល់ អាកាសនោះឡើយ ។ ឯពួកតិរច្ឆាន ក៏មាន មនោធាតុ ចាស់ជាងពួករុក្ខជាតិ ព្រោះតែកើតចំរើន មនោធាតុ ជាតំណបន្ទាប់ពីរុក្ខជាតិមក បានជាចេះដឹងជាងពួករុក្ខជាតិ, ចំណែកពួកមនុស្សវិញ បានជាចេះដឹងជាងគេ ព្រោះតែមាន មនោធាតុ កើតចំរើនបន្តពីពួកតិរច្ឆានមក ហើយមានលក្ខណៈជា មនោ ពេញលេញផង ។

– បើកើតពីធម្មជាតិយ៉ាងនេះ មានតែពេលស្លាប់-រលាប់ទៅ ក៏នឹងរលាយសូន្យទៅជាធម្មជាតិដើមវិញ មែនឬទេ ?

រឿងនេះ ជាសេចក្ដីល្អិតល្អន់ ខ្ញុំមិនអាចនិយាយឲ្យរាយស្ដាប់ដោយពាក្យខ្លីទេ , សូមចាំស្ដាប់អត្ថាធិប្បាយដូចតទៅនេះ ៖

រូបកាយនៃពួកមនុស្ស និងពួកតិរច្ឆានដែលមានជីវិតគឺការរស់នៅក្នុងលោកនេះ , តាមផ្លូវសាសនា លោកប្រាប់ថា មាន ធម៌ ២ យ៉ាង ដែលនៅជាប់ជាមួយគ្នាមិនអាចបំបែកចេញបាន គឺរូបធម៌ ១ ណាមធម៌ ១ ៗ រូបធម៌ បានដល់រូបកាយដែលយើងមើលឃើញ, ឯ ណាមធម៌ បានដល់ វិញ្ញាណ ( មនោ-ចិត្ត ) នេះឯង ៗ ប៉ុន្តែធម៌ទាំងពីរយ៉ាងនេះ ដែលអាចនឹងតាំងនៅបាន ក៏ត្រូវមានការទាក់ទងជាមួយនឹងធម្មជាតិឯ-ទៀត ៗ ដែរ ដូចមានសេចក្ដីបញ្ជាក់យ៉ាងច្បាស់ក្នុងមហាវគ្គថា :

អស្សាសុបដិពទ្ធំ ជីវិតំ បស្សាសុបដិពទ្ធំ ជីវិតំ
អស្សាសបស្សាសុបដិពទ្ធំ ជីវិតំ មហាភូតុបដិពទ្ធំ ជីវិតំ
ឧស្មូបដិពទ្ធំ ជីវិតំ កវឡីង្ការាហារុបដិពទ្ធំ ជីវិតំ
វិញ្ញាណុបដិពទ្ធំ ជីវិតំ = ជីវិត (របស់មនុស្សសត្វគ្រប់រូប)

ជាធម្មជាតិជាប់ទាក់ទងដោយដង្ហើមចេញ ដោយដង្ហើមចូល ដោយដង្ហើមចេញនិងដង្ហើមចូល ដោយមហាភូតរូប ដោយឧស្មូន និង ដោយវិញ្ញាណ ៗ

ដូច្នេះឃើញថា មនុស្សសត្វ ដែលមានជីវិតរស់នៅនោះ ព្រោះតែមានដង្ហើម មានរាងកាយមិនខូចខាត មានកំដៅឧស្ម័ន មានការបរិភោគអាហារភោជន និងមានវិញ្ញាណ (មនោ - ចិត្ត) ។ ប៉ុន្តែ ក្នុងកាលណាវិញ្ញាណ (មនោ - ចិត្ត) នឹងភ្លើងធាតុក្នុងរាងកាយនេះរលត់ហើយ, ក្នុងកាលនោះ រូបរាងកាយ ក៏បានឈ្មោះផ្សេងទៀតថា ខ្មោច ឬ ស្លាប់វិញ រឿងនេះក្នុងមហាវគ្គបញ្ញាក់ថា :

អាយុ ឧស្មា ច វិញ្ញាណំ យទា កាយំ ជហន្តិមំ
អបវិទ្ធា តទា សេតិ និរត្ថំវ កលិង្គរំ

អាយុ គឺតំណជីវិតផង ឧស្មា គឺកំដៅភ្លើងធាតុក្នុងរូបកាយផងវិញ្ញាណ គឺមនោ - ចិត្តផង, (ធម្មជាតទាំង ៣ នេះ) លះបង់រូបរាងកាយចោលក្នុងកាលណា, ក្នុងកាលនោះ រូបរាង។ យក៏រមែងត្រូវគេយកទៅបោះចោលឲ្យដេកលើផែនដី (ស្លាប់ - ងាប់) ដូចជាអង្កត់ឈើដែលគ្មានប្រយោជន៍ គឺយកមកប្រើជាសម្ភារៈពុំបាន ដូច្នោះ ។

សេចក្តីនេះ ឲ្យយើងយល់ថា ក្នុងរូបរាងកាយនៃមនុស្សសត្វ មានអាយុនិងឧស្ម័នជារបស់សំខាន់មួយផ្នែកដែលសម្រាប់ធ្វើជីវិត គឺការរស់នៅឲ្យស្ថិតស្ថេរបាន ; តែអាយុនិងឧស្ម័ននេះ បើវិញ្ញាណ គឺមនោ - ចិត្តចេញផុតពីរូបរាងកាយហើយ វាក៏ត្រូវរលត់ទៅដែរ ព្រោះវាមិនអាចបែកចេញពីវិញ្ញាណ (មនោ - ចិត្ត) បានឡើយ ។ ឯរូបរាងកាយវិញ

បើធម្មជាតទាំងនេះរលត់អស់ហើយ ក៏បានឈ្មោះថា ដាច់ ឬ ស្លាប់, វាមិនអាចរស់នៅតទៅទៀតបានឡើយ ។ លុះស្លាប់ហើយ វាក៏ត្រូវរលាយបែកខ្ញែកទៅជាមហាភូតរូប ( មូលធាតុ ) គឺ ទឹក ដី ភ្លើង ខ្យល់ អាកាស ដើមវិញ ។ ឯ វិញ្ញាណ ( មនោ - ចិត្ត ) ក្នុងខណៈដែលរូបកាយស្លាប់, វាក៏ត្រូវរលត់ដែរ ព្រោះវាគ្មានអ្វីនៅអាស្រ័យ ប៉ុន្តែ វាអាចផ្តួចបដិសន្ធិកើតឡើងក្នុងរូបថ្មីទៅទៀត ។ ដូចជាខ្ញុំបាននិយាយហើយថា ខ្សែនៃមនោ - ចិត្ត - វិញ្ញាណ មានកំលាំងណាស់ អាចផ្សាយទៅចាប់ជាតិកំណើតក្នុងភពថ្មីទៀតបាន ហើយវាមិនចេះសូន្យបាត់ទៅឡើយ ។ បើថា វិញ្ញាណ ( មនោ - ចិត្ត ) នេះ ដល់ពេលស្លាប់ហើយវានឹងសូន្យ, ពាក្យនេះពិតជាមិនសមទេ ព្រោះថា បើបានរកចំនេះពីភាពទន់ខ្សោយរហូតមកដល់ភាពមាំមួនពេញលក្ខណៈយ៉ាងនេះហើយ ស្រាប់តែរលាយទៅឯង ៗ ឃើញថា មិនគួរទាល់តែសោះ ។ យ៉ាងនេះហើយ បានជាមនុស្សសត្វគ្រប់រូប ត្រូវតែមានដំណើរអន្ទោលទៅក្នុងសង្សារវដ្ត គឺការកើត - ស្លាប់ ស្លាប់ - កើត រកទីបំផុតគ្មាន ដូចជាព្រះពុទ្ធដីកាបញ្ជាក់ក្នុងមហានិទ្ទេសថា :

អនមតគ្គោយំ ភិក្ខវេ សំសារស្ស បុព្វាកោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសារតំ = ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែល

មានអវិជ្ជាជាគ្រឿងរាំងរា, មានតណ្ហាជាគ្រឿងក្រងទុក, ដែលស្ទុះស្ទា អន្ទោលទៅ (កើត-ស្លាប់) រមែងមិនប្រាកដ ដើម និង ចុង នៃ សង្សារវដ្តដែលឥតមានអ្នកណាមួយដឹងបាននេះឡើយ ។

តាមន័យព្រះពុទ្ធដីកានេះ យើងល្មមយល់បានថា ពួកមនុស្សសត្វ ធម្មតា គឺមិនមែនជាពួកព្រះអរិយបុគ្គល រមែងកើតហើយស្លាប់ទៅ ស្លាប់ ហើយកើតមកវិញ មិនអាចកំណត់បាននូវ ដើម និង ចុង ឡើយ ។ ត្រង់ពាក្យថា ដើម និង ចុង នេះ គឺការកផ្តួច វិញ្ញាណ (មនោ-ចិត្ត) ឡើងជាដំបូង ហៅថា ដើម, ការរលត់ វិញ្ញាណ (មនោ-ចិត្ត) នោះទៅវិញ ហៅថា ចុង ។ ពាក្យថា មិនប្រាកដ បាន សេចក្តីថា មនុស្សសត្វគ្រប់រូប គ្មានអ្នកណាមួយអាចមើលឃើញថា " យើងបានចាប់កផ្តួចផ្តើម វិញ្ញាណ (មនោ-ចិត្ត) ជាលំដាប់រហូតមក ដល់កើតជាមនុស្សនេះ ពីកាលណាឡើយ ហើយពេលដែលមនុស្សសត្វ ឈប់ស្លាប់ ឈប់កើតនោះទៀត ក៏មិនដឹងជាទៅចប់នៅពេលណាដែរ។ រឿងកើត-ស្លាប់ឥតទីបំផុតនេះ គួរពុទ្ធជនយកចិត្តទុកដាក់ណាស់ ព្រោះ កុំលោកនេះ បើគ្មានការកើត ស្លាប់ឥតទីបំផុតនេះទេ ការកើតឡើងនៃ ព្រះពុទ្ធបរមគ្រូរបស់យើង ក៏គ្មានសារៈប្រយោជន៍ប៉ុន្មានដែរ, ព្រោះថា កុំ លោកនេះ ដែលកើតមានព្រះពុទ្ធ ក៏គឺព្រះអង្គមកដោះស្រាយសេចក្តីទុក្ខ នៃពិភពលោកព្រោះការកើតស្លាប់ឥតទីបំផុតនេះឯង, ចុះបើមនុស្សសត្វ

ស្លាប់ហើយសូន្យប្រាកដមែន គេចាំបាច់មានព្រះពុទ្ធមក ដោះស្រាយធ្វើអ្វី គឺថា បើទុកជាមនុស្សសត្វធ្វើអំពើអាក្រក់-ល្អ (បាប-បុណ្យ) យ៉ាងណាក៏ដោយ ដល់ពេលស្លាប់ហើយ ក៏នឹងលែងមានផលអាក្រក់-ល្អដែលតម្រូវឲ្យអ្នកធ្វើរងទុក្ខ-សុខតទៅជាតិមុខទៀតដែរ ដូច្នេះ ក៏ចប់ស្រេចឥតមានពិបាកដោះស្រាយអ្វីទៀតឡើយ ។ ឯសេចក្ដីពិតវិញ មនុស្សសត្វស្លាប់ហើយត្រូវតែកើតទៀតជាប្រាកដ គឺ វិញ្ញាណ (មនោ-ចិត្ត) ហ្នឹងឯង ដែលមិនរលត់សូន្យទៅដូចជារូបកាយទេ ក៏នៅចងខ្សែបដិសន្ធិទៅកើតក្នុងរូបថ្មីទៀត ។

-ចុះបើ វិញ្ញាណ (មនោ-ចិត្ត) ក៏រលត់ដូចរូបកាយដែរ ម្ដេចក៏ថា ក៏ទៅចាប់បដិសន្ធិកើតក្នុងភពថ្មីទៀតបាន ?

សូមលោកអ្នកអាន សង្កេតតាមពាក្យខ្ញុំតទៅមុខទៀត

ធម្មជាតិទាំងអស់ដែលកើតមកហើយ ត្រូវតែរលត់ទៅវិញជាការចាំបាច់ ដូចក្នុងមហាវគ្គបញ្ជាក់ថា :

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ

សង្ខារធម៌គឺធម្មជាតិទាំងឡាយ ពិតជាមិនទៀងទេ មានការកើតនិងស្លាប់ជាទំនៀម, ក៏តែងតែកើតឡើងហើយស្លាប់ទៅវិញៗ (យ៉ាងនេះឥតទីបំផុតចប់ឡើយ ) លុះតែរំលត់សង្ខារធម៌ គឺធម្មជាតិទាំងនោះបាន ទើប

បានសេចក្ដីសុខ គឺការឈប់កើត-ស្លាប់ ។

ដូច្នេះ ឃើញថា អ្វីក៏ដោយ ទោះជារូបកាយក្ដី វិញ្ញាណ (មនោ-ចិត្ត) នេះក្ដី ក៏ត្រូវតែស្លាប់-រលត់ដូចគ្នាទាំងអស់ ប៉ុន្តែ ការរលត់ទៅនៃវិញ្ញាណ (មនោ-ចិត្ត) នេះ មានដំណើរប្លែកពីរូបរាងកាយ គឺវាមានខ្សែបដិសន្ធិទៅផ្ដួចកើតក្នុងរូបថ្មីដែលយើងហៅថា បរលោក នោះទៀតបាន ។ គួរសង្ស័យដែរថា បើវារលត់ហើយ តើវាទៅផ្ដួចកំណើតជាថ្មីទៀតតាមទំនងដូចម្ដេច? រឿងនេះ ក្នុងគម្ពីរវិសុទ្ធិមគ្គបញ្ជាក់ថា :

លទ្ធប្បច្ចយមិតិ ធម្មមត្តមេតំ ភវន្តរមេតិ

នាស្ស តតោ សង្កន្តិ ន តតោ ហេតុំ វិនា ហោតិ ។

បើបានបច្ច័យស្រេចសព្វគ្រប់ ធម៌តែងតភពជាធម្មតា

តែមិនមែនចេញពីកាយា ទាំងវៀរហេតុវាក៏មិនមែន ។

ពាក្យថា ធម៌ គឺ រូបធម៌ នឹង នាមធម៌ ដូចបានអធិប្បាយពីខាងដើមរួចមកហើយ ។ ពាក្យថា "បានបច្ច័យសព្វគ្រប់" បានសេចក្ដីថា បើមានបច្ច័យ គឺរូបធម៌-នាមធម៌បច្ចុប្បន្ននេះហើយ រូបធម៌-នាមធម៌អនាគត ត្រូវតែកើតតភពទៅមុខទៀតជាធម្មតា ។ ពាក្យថា "វៀរហេតុវា" បានសេចក្ដីថា វៀរហេតុរបស់រូបធម៌-នាមធម៌បច្ចុប្បន្ន ។ រួមសេចក្ដីទៅថា កាលបើកើតមាន រូបធម៌ នាមធម៌ ហើយ, រូបធម៌-នាមធម៌ នេះ ក៏ចេញទៅជាហេតុបច្ច័យឲ្យកើត រូបធម៌-នាមធម៌

ថ្មី ៗ តទៅទៀត ប៉ុន្តែ ក៏មិនមែនកើតពី រូបធម៌-នាមធម៌ ចាស់នោះទៅទេ ហើយបើថាក៏មិនមែនចេញពី រូបធម៌-នាមធម៌ ចាស់ទេ គឺកើតមកពីហេតុបច្ច័យដទៃផ្សេងទៀត ដូច្នេះ ក៏មិនមែនដែរ, ប្រាកដជាក៏កើតថ្មីព្រោះ រូបធម៌ - នាមធម៌ ចាស់នោះឯងជាបច្ច័យ ៗ រឿងនេះក្នុងគម្ពីរដែលបានបញ្ជាក់ទៀតថា :

សិយុំ និនស្សាចេត្ត បដិឃោសាទិកា អថ
សន្តានពន្ធតោ នត្ថិ ឯកតា នាបិ នានតា

**ធម៌មួយហ្នឹង ឬធម៌ដទៃ ដែលមកជាប់ផ្ទៃ គ្មានឡើយណា**
**ដូចជារូបថត, សូរ, ភ្លើង, ត្រា ក្នុងរឿងនេះជាពាក្យនិទស្សន៍ ៗ**

ពាក្យថា “ធម៌មួយហ្នឹង” គឺ រូបធម៌-នាមធម៌ ចាស់ហ្នឹង ៗ ពាក្យថា “ ធម៌ដទៃ ” គឺរូបធម៌-នាមធម៌ ដទៃក្រៅពី រូបធម៌ នាមធម៌ ចាស់នោះ ៗ ពាក្យថា “ មកជាប់ផ្ទៃ ” គឺមកកើតជាថ្មីទៀត ៗ រួមសេចក្តីទៅថា រូបធម៌-នាមធម៌ ចាស់នោះក្តី ឬក៏ រូបធម៌-នាមធម៌ ផ្សេងដទៃទៀតក្តី ក៏មិនមកជាប់ជាតិកំណើតកើតថ្មីទៀតទេ គឺក៏គ្រាន់តែជាហេតុបច្ច័យឲ្យកើតប៉ុណ្ណោះ ប្រៀបដូចជារូបថត សូរ, ភ្លើង និងត្រាដូច្នោះ ៗ សូមជ្រាបពាក្យនិទស្សន៍ខាងក្រោមនេះ :

គេយកបរិធានថត មកថតរូបយើង, លុះថតហើយគេយកទៅផ្តិត ក៏លេចចេញរូបភាពយើងយ៉ាងច្បាស់នៅជាប់នឹងក្រដាស ៗ តើយើងថា

រូបភាពជាប់នឹងក្រដាស ក៏ជាខ្លួនយើងចេញទៅឬ? ឬក៏ជារូបដទៃវិញ? តាមពិតក៏មិនមែនជាខ្លួនយើងចេញទៅទេ ព្រោះខ្លួនយើងនៅឯនេះដដែល ហើយរូបភាព ក៏នៅជាប់នឹងក្រដាសឯនោះផ្សេង ប៉ុន្តែ បើនឹងថា ជារូបអ្នកណាមួយផ្សេងទៀត ក៏មិនមែនដែរ ព្រោះរូបភាពនោះ ក៏ធ្លងខ្សែស្រ-មោលពីរូបខ្លួនយើងទៅជាប់នឹងហ្វីលនោះ យ៉ាងណាមិញ, រូបធម៌-នាមធម៌ ថ្មី ក៏ធ្លងពី រូបធម៌-នាមធម៌ចាស់មក ប៉ុន្តែ នឹងហៅថា ក៏ជារូបធម៌-នាមធម៌ចាស់ចេញទៅក៏មិនមែន ឬថាជារូបធម៌-នាមធម៌ផ្សេងទៀតក៏មិនមែន យ៉ាងនោះដែរ ។

មួយទៀត ដូចជា ស្គរដែលគេដាក់នៅជិតទីមានទឹកច្រើន ឬទីមានគ្រឹះស្ថានធំ ៗ, កាលបើគេទូងក៏ក្នុងទីនោះ សូរក៏លាន់ឮឡើង ហើយបន្ទាប់គ្នា មានសូរមួយទៀតលាន់ឮឆ្លើយតបមកភ្លាម ដូចជាគេទូងក៏ក្នុងឡើង គេក៏នឹងឮសូរមួយទៀត លាន់ឆ្លើយពីក្នុងទឹកឬផ្ទះ ក្នុងឡើងដែរ ។ ដូច្នេះ យើងនឹងនិយាយថា សូរលាន់ឆ្លើយមកនោះ ជាសូរដែលលាន់ឮនឹងស្គរនោះបានឬទេ ? មិនបានទេ ព្រោះសូរដែលលាន់តបមកជាសូរផ្សេង ឯសូរដែលលាន់ឮក្នុងស្គរជាសូរផ្សេង ប៉ុន្តែ បើគ្មានសូរនឹងស្គរលាន់ឡើងទេ សូរឆ្លើយតបមកវិញក៏គ្មានដែរ ។ យ៉ាងនេះ បានជានឹងហៅថា ក៏ជាសូរដែលលាន់ឮក្នុងស្គរចេញទៅក៏មិនមែន ឬថាជាសូរលាន់ឡើងពីហេតុអ្វីមួយផ្សេងទៀតក៏មិនមែនដែរ យ៉ាងណាមិញ, រូប

ធម៌-នាមធម៌ចាស់ ជាបច្ច័យឲ្យកើតរូបធម៌-នាមធម៌ថ្មី ក៏យ៉ាងនោះដែរ ។

មួយទៀត ដូចគំនរសម្រាម ២ គំនរនៅខាងគ្នា , មនុស្សម្នាក់យកភ្លើងទៅដុតគំនរសម្រាម ១ , លុះភ្លើងឆេះគំនរសម្រាមនោះអស់ហើយ វាក៏ឆ្លងទៅឆេះគំនរសម្រាម ១ ទៀត ។ តើយើងគួរហៅថា ភ្លើងដែលឆេះគំនរសម្រាមថ្មីនេះ ជាភ្លើងដែលឆេះគំនរសម្រាមមុនបានឬទេ? តើភ្លើងនោះ វាមកពីណា? តាមពិត យើងនឹងហៅថា ជាភ្លើងឆេះសម្រាមមុនក៏មិនបាន ព្រោះភ្លើងដែលឆេះសម្រាមមុននោះ វារលត់បាត់ទៅហើយ ហើយយើងនឹងហៅថា វាជាភ្លើងផ្សេងមកពីទីឯទៀតក៏មិនមែន ព្រោះភ្លើងដែលឆេះសម្រាមថ្មីនេះ វាឆ្លងឆេះមកពីភ្លើងគំនរសម្រាមមុននោះដែរ យ៉ាងណាមិញ , រូបធម៌ - នាមធម៌ថ្មី ដែលឆ្លងមកពីរូបធម៌-នាមធម៌ចាស់ ក៏យ៉ាងនោះដែរ ។

មយ៉ាងទៀត ដូចជា ស្នាមត្រាដែលគេបោះទៅនឹងក្រដាស, តើយើងអាចហៅស្នាមនោះថា វាជាតួត្រាបានឬទេ? មិនបានទេ ព្រោះស្នាមត្រាដែលជិតជាប់ទៅនោះវាជារបស់ផ្សេង ឯតួត្រាវិញក៏នៅផ្សេងដែរ ប៉ុន្តែ បើគ្មានតួត្រា ក៏ស្នាមត្រាមិនអាចមានទៅកើតដែរ យ៉ាងណាមិញ, រូបធម៌-នាមធម៌ចាស់ ជាបច្ច័យឲ្យកើតរូបធម៌ នាមធម៌ថ្មីនោះក៏យ៉ាងនោះដែរ ។

សេចក្តីឧបមាទាំងនេះ អាចឲ្យយើងយល់បានថា រូបកាយ និង

វិញ្ញាណ (មនោ - ចិត្ត) របស់មនុស្សសត្វដែលរលត់ហើយ វាអាចជាបច្ច័យជូនទៅផ្ដើបដិសន្ធិ ជារូបកាយ និងវិញ្ញាណ (មនោ - ចិត្ត) ថ្មីទៀត យ៉ាងនេះឯង ។

–ចុះបើមនុស្សសត្វ ចេះតែទៅកើតទៀតយ៉ាងនេះ, តើមានពេលណានឹងចប់ការកើតស្លាប់ដែរឬទេ ? ក្នុងជីវិតមនុស្សសត្វម្នាក់ ១ គួរឲ្យនឿយណាយជិនឆ្អន់ណាស់ ព្រោះត្រូវជួបនឹងសេចក្ដីទុក្ខលំបាកច្រើនហួសបែប ដូចជាការប្រាសព្រាត់ស្លាប់ចោលគ្នា ការឈឺចាប់ ការសោកសៅ ពេគាពាធ ការខំប្រឹងរកទ្រព្យសម្បត្តិនឹងអាហារគោជនដោយសេចក្ដីនឿយព្រួយលំបាកគ្រប់យ៉ាងជាដើម ចុះបើស្លាប់ហើយត្រូវទៅកើតទៀតយ៉ាងនេះ តើវាមិនត្រូវលំបាកទៀតហើយ ?

- ពិតជាទុក្ខលំបាកយ៉ាងហ្នឹងហើយ បានជាកើតបញ្ហាព្រះពុទ្ធឡើងក្នុងលោកនេះ ព្រោះព្រះពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងពិភពលោក ក៏ដោយសារសេចក្ដីទុក្ខឈឺចាប់លំបាក នៃពិភពលោក ឥតមានពេលចប់ពេលហើយនេះឯង ។

–តើមានផ្លូវទៅបញ្ចប់ការកើតស្លាប់នេះដែរឬទេ ?

–មាន, គឺត្រូវធ្វើខ្លួនឲ្យដូចជាព្រះពុទ្ធ ដែលយើងធ្លាប់ហៅថាព្រះអរិយបុគ្គល (ព្រះខីណាស្រព) នោះទើបយើងបញ្ចប់ការកើតទៀតបាន ។

(នៅមានត)

# ពុទ្ធប្រវត្តិ

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

( តនិងចប់ )

## យសបព្វជ្ជាកថា ទី ១២

១- យសបរិភោគកាម ២- យសកុលបុត្រទៅរកព្រះមានព្រះភាគ ៣- មាតាបិតាយស.កុលបុត្រស្វែងរក ៤- ទ្រង់ប្រោសបិតាយសកុលបុត្រ ៥- ទ្រង់ប្រោសមាតានៃយសកុលបុត្រ ៦- ទ្រង់ប្រោសសំឡាញ់ព្រះយស ៤ នាក់ ៧- ទ្រង់ប្រោសសំឡាញ់ ៥០ នាក់ ៨- ទ្រង់បញ្ជូនសាវកទៅប្រកាសពុទ្ធសាសនាក្នុងលោកមុនដំបូង ។

## ១- យសបរិភោគកាម

សម័យ(១)នោះឯង ក្នុងក្រុងពារាណសី មានកុលបុត្រម្នាក់ឈ្មោះ យស ជាកូនសេដ្ឋី ជាបុគ្គលចំរើនដោយសេចក្ដីសុខ ។ យសកុល.បុត្រមានប្រាសាទ ៣ ប្រាសាទមួយសម្រាប់នៅក្នុងរដូវរងា ប្រាសាទមួយសម្រាប់នៅក្នុងរដូវក្ដៅ ប្រាសាទមួយសម្រាប់នៅក្នុងរដូវភ្លៀង ។ យសកុលបុត្រនោះ មាតាបិតាឲ្យពួកអ្នកភ្លេងតូរ្យតន្ត្រីសុទ្ធសឹងតែស្រីឥតមានបុរសឡើយ កំបម្រើអស់កំណត់ ៤ ខែក្នុងរដូវភ្លៀង មិនដែលចុះមកកាន់ផ្ទៃខាងក្រោមនៃប្រាសាទទេ ។ យសកុលបុត្របរិភោគកាមឆ្អែតស្កប់ស្កល់ដោយកាមទាំង ៥ ប្រការ កាលពួកស្រីកំពុងបម្រើ ក៏ដេកលក់ទៅមុន ជនជាបរិស័ទដេកលក់ជាក្រោយ ។ ប្រទីបនេះភ្លឺព្រោងព្រាយពេលយប់ពេលព្រឹក ។ គ្រានោះ យសកុលបុត្រភ្ញាក់ពីដំណេកមុនគេ បាន

---

១- មហាវគ្គ បឋមភាគ មហាខន្ធកៈ សៀវ. ៦ ទំព័រ ៤៣ ។

ឃើញបរិស័ទកំពុងដេកលក់ ស្រីខ្លះមានពិណនៅត្រង់ក្លៀក ស្រីខ្លះមានសម្ភោរនៅត្រង់ក ស្រីខ្លះមានស្គរធំនៅក្បែរទ្រូង ស្រីខ្លះមានសក់រំសាយ ស្រីខ្លះមានទឹកមាត់ហូរហៀរ ស្រីខ្លះកំពុងមមើ មើលទៅហាក់ដូចជាព្រៃស្មសានឋានស្ងាត់ ។ យសកុលបុត្រឃើញដូច្នោះហើយ កើតសេចក្តីនឿយណាយ ទើបបន្លឺឧទានថា ឱ! ទីនេះវឹកវរណាស់តើ ឱ! ទីនេះជំពាក់ពាក់វៃណាស់តើ ! ។

គ្រានោះ យសកុលបុត្រពាក់ទ្រនាប់ជើងមាស ដើរចេញទៅកាន់មាត់ទ្វារផ្ទះ ។ ទេវតាក៏បើកទ្វារឲ្យយសកុលបុត្រចេញទៅ ។ យស-កុលបុត្រដើរតម្រង់ទៅកាន់ឥសិបតនមិគទាយវ័ន ។

## ២- យសកុលបុត្រជួបព្រះមានព្រះភាគ

គ្រានោះឯង(១) ព្រះមានព្រះភាគទ្រង់តើនពីព្រឹកចង្រ្កមក្នុងទីវាល ទ្រង់ទតព្រះនេត្រឃើញយសកុលបុត្រពីចម្ងាយ ឃើញហើយស្តេចចៀសចេញពីចង្រ្កមប្រថាប់លើទីអាសនៈមួយកន្លែង ដែលក្រាលទុកស្រាប់ ។ ឯយសកុលបុត្របន្លឺឧទានថា ឱទីនេះវឹកវរណាស់តើ! ឱទីនេះជំពាក់ពាក់វៃណាស់តើ! ក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគត្រាស់តបវិញថា “ ម្នាលយស! ទីនេះមិនវឹកវរទេ ទីនេះមិនជំពាក់ពាក់វៃទេ, ម្នាលយស! មកណេះមកអង្គុយខាងនេះ តថាគតនឹងសំដែងធម៌ប្រាប់ ។

១ មហាវគ្គ មហាខន្ធកៈ សៀ. ៦ ទំព័រ ៤៩ ។

លុះយសកុលបុត្រចូលទៅអង្គុយក្នុងទីសមគួរហើយ ទ្រង់សំដែងអនុបុព្វីកថា គឺទានកថា សីលកថា សគ្គកថា កាមាទីនវកថា និងនេក្ខម្មានិសង្សកថា ។ តទៅទ្រង់សំដែងអរិយសច្ច ៤ ប្រការគឺ ទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ។ ធម្មតា សំពត់សស្អាតមិនប្រឡាក់ដោយកែមានពណ៌ទៅ គឺជ្រលក់ទៅជាដើម គួរទទួលទឹកជ្រលក់ដោយល្អបាន មានឧបមាដូចម្តេចមិញ ធម្មចក្ខុគឺសោតាបត្តិមគ្គ ដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់យសកុលបុត្រក្នុងកន្លែងអង្គុយនោះថា ធម្មជាតណាមួយដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅជាធម្មតា មានឧបមេយ្យដូច្នោះឯង ។

## ៣- មាតាបិតាយសកុលបុត្រស្វែងរក

កាលនោះ មាតាយសកុលបុត្រឡើងទៅលើប្រាសាទ មិនឃើញកូនក៏ទៅប្រាប់ស្វាមីថា កូនយើងមិនឃើញទេ ។ សេដ្ឋីជាបិតា ប្រើបម្រើឲ្យជិះសេះចេញទៅរកគ្រប់ទាំង ៤ ទិស ខ្លួនឯងដើរតម្រង់ទៅឥសិបតនមិគទាយវ័ន ទៅដល់ហើយ ឃើញស្នាមទ្រនាប់ជើងមាសហើយដើរតាមស្នាមជើងនោះទៅ ។ ព្រះមានព្រះភាគទ្រង់ទតព្រះនេត្រឃើញសេដ្ឋីជាបិតានៃយសកុលបុត្រមកពីចម្ងាយទ្រង់បរិវិតក្កថា តថាគតគួរធ្វើឥទ្ធាភិសង្ខារបំបាំងកូនមិនឲ្យសេដ្ឋីឃើញកូនដែលអង្គុយនៅក្នុងទីនេះ ។ សេដ្ឋីចូលទៅគាល់ព្រះមានព្រះភាគ ចូលទៅដល់ហើយក្រាបទូលថា បពិត្រ

ព្រះអង្គដ៏ចំរើន! ទ្រង់បានឃើញយសកុលបុត្រដែរឬទេ? ព្រះមានព្រះភាគគ្រាន់តែតបវិញថា ម្នាលគហបតី! ចូរអ្នកអង្គុយសិនចុះ បើអ្នកអង្គុយក្នុងទីនេះ អ្នកមុខជានឹងឃើញយសកុលបុត្រក្នុងទីនេះដែរ ។ ព្រះមានព្រះភាគទ្រង់ប្រទានអនុបុព្វីកថា លុះសំដែងចប់ហើយ សេដ្ឋីបានឃើញអរិយសច្ច ហើយឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន! ព្រះពុទ្ធដីកានេះពីរោះណាស់ ប្រៀបដូចជាគេផ្ងាររបស់ដែលគេផ្កាប់ឲ្យផ្ងារឡើង ឬដូចជាគេបើកនូវរបស់ដែលគេបិទបាំងទុក ពុំនោះដូចប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោត ដូចទ្រោលបំភ្លឺនូវប្រទីបក្នុងទីងងឹត ឲ្យមនុស្សមានចក្ខុមើលឃើញរូបបាន ។ បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គសូមដល់នូវព្រះពុទ្ធនូវព្រះធម៌ផង ព្រះសង្ឃជាទីពឹង សូមទ្រង់ជ្រាបថា ខ្ញុំព្រះអង្គនេះជាឧបា-សកអ្នកដល់នូវទីពឹងស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមតៗ ។ សេដ្ឋីគហបតីនេះ បាននាមបញ្ញត្តិថា តេវាចិកឧបាសក ជាដំបូងក្នុងលោក ។

## ៤ - ទ្រង់ប្រោសបិតាយសកុលបុត្រ

កាលព្រះមានព្រះភាគកំពុងសំដែងធម៌ដល់បិតាខ្លួន យសកុលបុត្រក៏ពិចារណានូវភូមិធម៌ដែលខ្លួនបានឃើញ បានត្រាស់ដឹងហើយ ចិត្តក៏រួចស្រឡះចាកអាសវធម៌ទាំងឡាយ ឥតជាប់ជំពាក់ ដោយឧបាទាន

ឡើយ ។ ព្រះមានព្រះភាគជ្រាបច្បាស់ការៈចិត្តនៃយសកុលបុត្រថាបាន ត្រាស់ដឹងធម៌ហើយ ទ្រង់ក៏រំសាយឥទ្ធាភិសង្ខារនោះចេញ ។

សេដ្ឋីជាបិតានិយាយថា នៃយស! មាតាអ្នក មានសេចក្តីសោក ខ្សឹកខ្សួល បូរអ្នកឲ្យជីវិតដល់មាតារបស់អ្នកផង ។ យសកុលបុត្រងើប មើលព្រះមានព្រះភាគ ។ ព្រះមានព្រះភាគមានពុទ្ធដីកាថា យសកុល-បុត្រនេះ បានឃើញធម៌ហើយដោយសេក្ខញាណនឹងសេក្ខទស្សនៈ ចិត្ត ក៏រួចស្រឡះចាកអាសវធម៌ទាំងឡាយហើយ ឥតមានជាប់ជំពាក់ ដោយ ឧបាទានឡើយ មិនគួរនឹងវិលត្រឡប់ទៅ ដើម្បីភាវៈជាគ្រហស្ថឡើយ ហើយបរិភោគកាមទាំងឡាយដូចកាលនៅជាឃរាវាសក្នុងកាលពីមុនទេ ។

សេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន! សូមព្រះមានព្រះភាគ ទទួលភត្តរបស់ខ្ញុំព្រះអង្គដើម្បីឆាន់ក្នុងថ្ងៃនេះ ព្រមទាំងយសកុលបុត្រជា បច្ឆាស្រមណ៍ផង និមន្តរួចហើយ ក៏ដើរចេញទៅ ។ សេដ្ឋីចេញទៅមិន យូរប៉ុន្មាន យសកុលបុត្រសូមបព្វជ្ជា នឹងឧបសម្បទាក្នុងសំណាក់ព្រះមាន ព្រះភាគ ។ កាលនោះព្រះអរហន្តទាំងឡាយ ៧ អង្គ កើតមានក្នុងលោក ក្នុងគ្រានោះឯង ។

## ៥– ទ្រង់ប្រោសមាតានៃព្រះយស

លំដាប់នោះ ព្រះមានព្រះភាគប្រដាប់ដោយបាត្រនឹងចីវរក្នុងបុព្វណ្ហ-សម័យ មានព្រះយសជាបច្ឆាស្រមណ៍ យាងចូលទៅកាន់គេហដ្ឋាន

សេដ្ឋីគហបតី លុះចូលទៅហើយ ទ្រង់ប្រថាប់លើអាសនៈដែលសេដ្ឋីក្រាលបម្រុងទុកហើយ ។ គ្រានោះ មាតានឹងបុណណទុតិយិការបស់ព្រះយសនាំគ្នាចូលមកគាល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់សំដែងអនុបុព្វីកថា លុះចប់ធម្មីកថាហើយ មាតានឹងបុណណទុតិយិការបស់ព្រះយស សូមដល់នូវព្រះត្រៃសរណគមន៍ថា បពិត្រព្រះអង្គដ៏ចំរើន! យើងខ្ញុំទាំងនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង សូមព្រះអង្គ ទ្រង់ជ្រាបនូវយើងខ្ញុំទាំងឡាយថាជាឧបាសិកា ដល់នូវទីរលឹកស្មើដោយជីវិត កន្លងកាលមានថ្ងៃនេះជាដើមតទៅ ។

# ៦- ទ្រង់ប្រោសសំឡាញ់ព្រះយស ៤ នាក់

លំដាប់នោះសំឡាញ់ ៤ នាក់របស់ព្រះយសឈ្មោះវិមល ១ សុពាហុ ១ បុណ្ណជិ ១ គវម្បតិ ១ ជាបុត្រនៃត្រកូលសេដ្ឋីនឹងអនុសេដ្ឋីក្នុងក្រុងពារាណសី បានឮដំណឹងថា យសកុលបុត្រ កោរសក់នឹងពុកមាត់ ពុកចង្កា ស្លៀកពាក់សំពត់កាសាយៈចេញពីផ្ទះ ហើយបួសកាន់យកភេទជាបុគ្គលមិនមានផ្ទះ ក៏នាំគ្នាចូលទៅរកព្រះយស ។ ព្រះយសក៏នាំសំឡាញ់ត្រូហស្ថទាំង ៤ នាក់នេះ ចូលទៅគាល់ព្រះមានព្រះភាគ សូមព្រះមានព្រះភាគឲ្យទូន្មានប្រៀនប្រដៅសំឡាញ់ទាំងអម្បាលនោះ ។ ព្រះមាន ពះភាគទ្រង់សំដែងអនុបុព្វីកថាទៀត, ទីបំផុតធម្មទេសនា សំឡាញ់ទាំង ៤ នាក់ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន! យើងខ្ញុំព្រះអង្គគួរ

បានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសំណាក់ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា ឯហិ ភិក្ខវោ ឬអ្នកទាំងឡាយចូលមកជាភិក្ខុចុះ ព្រះអរហន្តទាំងឡាយ ១១ អង្គកើតមានក្នុងលោកក្នុងកាលនោះ ។

## ៧- ទ្រង់ប្រោសសំឡាញ់ព្រះយស ៥០ នាក់

មានសំឡាញ់របស់ព្រះយស ប្រមាណ ៥០ នាក់ទៀត បានឮដំណឹងថា ព្រះយសបួសហើយក្នុងសំណាក់នៃព្រះមានព្រះភាគ ក៏នាំគ្នាចូលទៅរកព្រះយស ។ គ្រានោះ ព្រះយសមានអាយុក៏នាំសំឡាញ់ ៥០ នាក់ចូលទៅគាល់ព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ទើបក្រាបទូលសូមទ្រង់ព្រះមេត្តាប្រោស ប្រទានឱវាទប្រៀនប្រដៅសំឡាញ់ លុះចប់ធម្មកថាហើយ គ្រហស្ថជាសំឡាញ់សូមបព្វជ្ជា សូមឧបសម្បទា ។ ព្រះមានព្រះភាគទ្រង់ត្រាស់ទូន្មានភិក្ខុទាំងឡាយនោះដោយធម្មកថា ភិក្ខុទាំងឡាយចំនួន ៥០ អង្គនោះ បានរួចចាកអាសវធម៌ទាំងឡាយ ឥតមានជំពាក់ដោយឧបាទានឡើយ ។ ព្រះអរហន្តទាំងឡាយ ៦១ អង្គកើតឡើងក្នុងលោកក្នុងកាលនោះឯង ។

## ៨ ទ្រង់បញ្ជូនសាវ័កទៅប្រកាសពុទ្ធសាសនាក្នុងលោកមុនដំបូង

កាលស្ដេចប្រោសវេនេយ្យសត្វមុនដំបូង ក្រោយពីកាលដែលទ្រង់ទើបនឹងបានត្រាស់ថ្មីៗ កាលនោះមានភិក្ខុចំនួន ៦១ អង្គរួមទាំងអង្គព្រះពុទ្ធជាម្ចាស់ផង ព្រះមានព្រះភាគទ្រង់ក៏ចាប់ផ្ដើមធ្វើការជំផ្សាយពុទ្ធសាសនា

ដោយមានពុទ្ធបំណងឲ្យពុទ្ធសាសនាឈ្នះទុក ផ្សាយទូទៅពេញសាកលលោក ដូចមានព្រះតម្រាស់ដែលទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយ ៦០ រូប ថា(១)

មុត្តាហំ ភិក្ខវេ សព្វបាសេហិ យេ ទិព្វា យេ ច មានុសា ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ មា ឯកេន ទ្វេ អគមិត្ថ ទេសេថ ភិក្ខវេ ធម្មំ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេថ សន្តិ សត្តា អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតារោ អហម្បិ ភិក្ខវេ យេន ឧរុវេលា សេនានិគមោ តេនុបសង្កមិស្សាមិ ធម្មទេសនាយាតិ ។

ម្នាលភិក្ខុទាំងឡាយ! តថាគតរួចហើយចាកអន្ទាក់ទាំងអស់ ទោះបីជារបស់ទេវតាក្តី ទោះបីជារបស់មនុស្សក្តី, ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយក៏បានរួចហើយចាកអន្ទាក់ទាំងអស់

១ មហាវគ្គ បឋមភាគ មហាខន្ធក សៀវ. ៦ ទំព័រ ៦៦ ។

ដែរ ទោះបីជារបស់ទេវតាក្តី ទោះបីជារបស់មនុស្សក្តី ។ ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយ ចូរត្រាច់ទៅកាន់ចារិក (ស្រុក និគម រាជធានី)ហើយសំដែងធម៌ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់ជនជាច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីគុណ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ចូរអ្នកទាំងឡាយ កុំទៅ ២ នាក់តាមផ្លូវមួយជាមួយគ្នាឡើយ, ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយ ចូរសំដែងធម៌ឲ្យមានលំអ បទដើម បទកណ្តាលនិងបទចុង, អ្នកទាំងឡាយ ចូរប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធប្រកប ដោយអត្ថនិងព្យញ្ជនៈពេញបរិបូណ៌ទាំងអស់ សត្វទាំងឡាយ ដែលមានធូលីគឺរាគាទិក្លេសតិចក្នុងភ្នែកក៏មាន សត្វទាំងនោះ នឹងសាបសូន្យចាកមគ្គផល ព្រោះមិនបានស្តាប់ធម៌ សត្វទាំងឡាយច្រើននាក់ដែលបម្រុងត្រាស់ដឹងធម៌ ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ! ចំណែកតថាគត នឹងចូលទៅកាន់សេនានិគម ក្នុងឧរុវេលប្រទេស ដើម្បីប្រកាសធម៌ដែរ" ។

# លោកុត្តរវិស័យ

## ភាគទី ១

# សម្ភារនៃការត្រាស់ដឹងលោកុត្តរធម៌

អ្នកឧកញ៉ា ឆា-សាង អតីតរដ្ឋមន្ត្រី

រៀបរៀង

ការដុសខាត់ជំរះចិត្តឲ្យស្អាតបរិសុទ្ធផូរផង់ គោលគឺការលះកិលេស ដែលជាគ្រឿងសៅហ្មងចិត្តឲ្យដាច់ស្រឡះ ដោយសម្មប្បធាន គួរបាត់ទុកជាសម្ភារ ដែលអាចញុំាងការត្រាស់ដឹងលោកុត្តរធម៌ ឲ្យសម្រេចឡើងបាន, ពីព្រោះកិលេសមានពគាទិក្កិលេសជាដើម, កាលបើមកកើតក្នុងខន្ធសន្តានហើយ, រមែងតែធ្វើចិត្តឲ្យសៅហ្មង គឺធ្វើចិត្តឲ្យប្រឡាក់ដោយមន្ទិល, ធ្វើចិត្តខ្នត់ញាប់ញ័រអន្ទះសា ស្រេកឃ្លានចង់ស្រើបស្រាលត្រេកត្រអាលចំពោះអារម្មណ៍ ៥ មានរូបជាដើម, ធ្វើសត្វឲ្យស្រវឹងវង្វេងភ្លេចខ្លួនជាប់ស្អិតទៅវិលវល់ក្នុងវដ្តសង្សារ រងទុក្ខវេទនារកទីបំផុតគ្មានឡើយ ។

ដោយហេតុនេះ បានជាព្រះសម្ពុទ្ធទាំងឡាយ តែងដាស់តឿនទូន្មានសត្វឲ្យខំព្យាយាមដុសខាត់ជំរះចិត្ត ឲ្យស្អាតបរិសុទ្ធផូរផង់រួចចាកគ្រឿងសៅហ្មង, ព្រោះព្រះអង្គមានព្រះហឫទ័យករុណាអាណិតសត្វ ចង់ឲ្យសត្វបានត្រាស់ដឹងនូវមគ្គ ៤ ផល ៤ និងនិព្វានដែលជាវិមោក្ខធម៌ អាចញុំាង

សត្វឲ្យរួចផុតចាកកិលេស ដើម្បីបរមសុខ គឺសុខយ៉ាងឧត្តមក្រៃលែងនោះឯង ។

អាស្រ័យហេតុនេះ ទើបខ្ញុំយល់ឃើញថា មុននឹងធ្វើអត្ថាធិប្បាយអំពីលោកុត្តរកិសម័យ គឺការត្រាស់ដឹងលោកុត្តរធម៌នោះ គប្បីតែខ្ញុំលើកយកកិលេសនិងចិត្តមកបរិយាយ បញ្ជាក់ឲ្យឃើញហេតុបច្ច័យនិងផលជាមុនសិន ទើបជាហេតុអាចនឹងដឹកនាំអស់លោក-អ្នកអានឲ្យពឹងត្រិះរិះឈ្វេងយល់បានដោយងាយស្រួល នូវអត្ថរសយ៉ាងល្អិតនៃមគ្គផលនិព្វាននិងដំណើរប្រព្រឹត្តទៅនៃការត្រាស់ដឹងលោកុត្តរធម៌នោះបានផងទៀត ។

លំដាប់ពីនេះ ខ្ញុំនឹងបរិយាយរៀបរៀងសេចក្ដីតាមសមត្ថភាពដែលខ្ញុំបានចេះចាំដោយអានសៀវភៅធម៌ផ្សេង ៗ ផង និងតាមវិចារណប្បញ្ញាផង ដូចមានសេចក្ដីតទៅនេះ ៖

## ១ – កិលេស

មុននឹងធ្វើអត្ថាធិប្បាយអំពីកិលេសនេះ ខ្ញុំយល់ឃើញគប្បីបញ្ជាក់អត្ថន័យ នៃកិលេសស័ព្ទនេះឲ្យច្បាស់ជាមុនសិន ។

បើដូច្នេះ តើកិលេសស័ព្ទនេះមានន័យថាដូចម្ដេចទៅ ?

វចនានុក្រម ប្រែពាក្យកិលេសថា សេចក្ដីសៅហ្មងចិត្ត ។

មានអស់លោកជំនាញខាងភាសាបាលីខ្លះប្រែថា ៖ គ្រឿងសៅហ្មងចិត្ត ឬគ្រឿងសៅហ្មងនៃចិត្ត ។

រីឯសេចក្ដីប្រែពាក្យកិលេសដូចខាងលើនេះ ឃើញថាមានន័យមិនខុសគ្នាប៉ុន្មានឡើយ ក៏ប៉ុន្តែអស់លោកអ្នកនិពន្ធសៀវភៅធម៌ ឃើញច្រើននិយមប្រើតែគ្រឿងសៅហ្មងចិត្តទុកជាន័យនៃកិលេសនោះ ។

រីឯគ្រឿងសៅហ្មងចិត្តនោះ គឺសំដៅអកុសលធម៌ មានអកុសល-ចេតសិកជាដើម ពីព្រោះអកុសលធម៌នោះ កាលមកកើតក្នុងខន្ធសន្តានរបស់បុគ្គលណាហើយ តែងតែធ្វើខន្ធសន្តាននោះឲ្យសៅហ្មង គឺឲ្យប្រឡាក់ដោយមន្ទិល ប្រែទៅជាចិត្តមិនស្អាតមិនបរិសុទ្ធវិញ ។

ឯកិលេសនោះមានជាពួក ៗ ប្លែកផ្សេងពីគ្នាជាច្រើន តែទោះបីយ៉ាងនេះក៏ដោយ គេគង់អាចបំប្រួញឲ្យនៅត្រឹមតែ ២ ពួកគឺ ៖

ពួកលោភាទិក្កិលេស គឺពួកកិលេស ដែលមានលោភៈជាអាទិ ។

និងពួកពគាទិក្កិលេស គឺពួកកិលេសដែលមានពគៈជាអាទិ៍ ។

ឯអកុសលមូល ៣ និងកិលេស ១០ ហើយនិងឧបក្កិលេស ១៦ ពួក សង្គ្រោះចូលក្នុងពួកលោភាទិក្កិលេស ។

ចំណែកឯកិលេសមូល ៣, នីវរណៈ ៥, កិលេសកាម ៦, អនុស័យ ៧ និងសំយោជនៈ ១០ គប្បីសង្គ្រោះចូលក្នុងពួកពគាទិក្កិលេស ។

ឯកិលេសទាំងឡាយនេះ ខ្ញុំមិនលើកយកមករៀបរាប់នៅទីនេះទាំងអស់ទេ, ដើម្បីកុំឲ្យវែងសេចក្ដីបរិយាយពេក, ហើយម្យ៉ាងទៀត ពីព្រោះខ្ញុំជឿជាក់ថាអស់លោកអ្នកអានគង់បាន ជ្រាប អំពីកិលេសទាំងឡាយ

នោះសព្វគ្រប់ទៅហើយដែរ ។

ខ្ញុំសូមគ្រាន់តែលើកយកសំយោជនៈ ១០ មកអធិប្បាយបញ្ជាក់ ពីព្រោះសំយោជនៈ ១០ នោះជាប់ទាក់ទងជាពិសេស នឹងការត្រាស់ដឹងលោកុត្តរធម៌នោះ ។

ឯសំយោជនៈ ១០ នោះគឺ ៖

១- សក្កាយទិដ្ឋិ គឺសេចក្តីយល់ឃើញខុសចំពោះកាយ មានការយល់ឃើញថាមានរូបក្នុងកាយជាដើម ។

២- វិចិកិច្ឆា គឺសេចក្តីសង្ស័យចំពោះនាមរូប មានសេចក្តីសង្ស័យថាអាត្មាអញធ្លាប់បានកើតដែរឬទេជាដើម ។

៣- សីលព្វតបរាមាស គឺសេចក្តីចូលចិត្តកាន់អាននវត្តប្រតិបត្តិខុសទំនង ។

៤- កាមរាគ គឺតម្រេកក្នុងកាមភព ។

៥- បដិឃៈ គឺសេចក្តីបង្អៀតបង្អល់ចិត្ត ឬសេចក្តីអាក់អន់ចិត្ត ។

៦- រូបរាគ គឺតម្រេកក្នុងរូបភព ។

៧- អរូបរាគ គឺតម្រេកក្នុងអរូបភព ។

៨- មានះ គឺសេចក្តីប្រកាន់ខ្លួន ។

៩– ឧទ្ធច្ចៈ គឺ សេចក្ដីរាយមាយនៃចិត្ត ។

១០– អវិជ្ជា គឺ សេចក្ដីល្ងង់ ។

ឯសំយោជនៈ ១០ នេះ ជាកិលេសរឹតត្បិតរឹតតែងចិត្តសត្វ ធ្វើឲ្យសត្វវង្វេងភ្លេចខ្លួនជាប់ស្អិតនៅវិលវល់ក្នុងវដ្តសង្សារ, ដោយហេតុនេះ អរិយបុគ្គលគប្បីព្យាយាមលះសំយោជនៈ ១០នោះ ឲ្យដាច់ស្រឡះអស់ពីខន្ធសន្តានទើបអាចត្រាស់ដឹងលោកុត្តរធម៌ គឺមគ្គ ផល និព្វានបាន ។

លំដាប់តទៅនេះ ខ្ញុំនឹងអធិប្បាយវែកញែកបញ្ជាក់អំពីទោស នៃកិលេសដូចមានសេចក្ដីខាងក្រោមនេះ ។

កាលបើសត្វណាធ្វេសប្រហែស បណ្ដោយឲ្យពួកលោភាទិកិលេសចូលមកកើតក្នុងខន្ធសន្តានហើយ កិលេសពួកនេះរមែងធ្វើសត្វនោះឲ្យវង្វេងភ្លេចភាំងស្មារតី លែងមានគំនិតគិតបំពេញនូវបុញ្ញកិរិយាវត្ថុមានទានសីលជាដើម, គិតឃើញតែពីលោភចង់មានចង់បានហួសហេតុ, គិតតែខំរករឿងហេតុដើម្បីប្រទូស្តបៀតបៀនអ្នកដទៃ ហើយនឹងគិតឃើញតែខុសហើយប្រកាន់ឡើងថាជាត្រូវ ដែលជាហេតុនាំឲ្យកើតមនោទុច្ចរិត ៣ ប្រការគឺ អភិជ្ឈា, ព្យាបាទ និងមិច្ឆាទិដ្ឋិ ។ កាលបើសត្វលុះដោយអំណាចនៃមនោទុច្ចរិត ៣ ប្រការនេះហើយ, សត្វនោះលែងរអែង លែងញញើតនឹងប្រព្រឹត្តនូវកាយទុច្ចរិត ៣ និងវចីទុច្ចរិត ៤ ទៀត ដែលជាហេតុនាំឲ្យសត្វនោះ ធ្លាក់ខ្លួនទៅរងទុក្ខវេទនាក្នុងទុគ្គតិភពរកទីបំផុតគ្មានឡើយ ។

រីឯទោសនៃពគាទិក្កិលេសនោះ មានសភាពនឹងលក្ខណៈខុសពីទោសនៃលោភាទិក្កិលេសដូចបានអធិប្បាយខាងលើនេះ ។

ឯពគាទិក្កិលេសនេះ បើមកកើតក្នុងខន្ធសន្តានការណាហើយ រមែងដុតកំដៅខន្ធសន្តានឲ្យក្តៅក្រហល់ក្រហាយ ឲ្យអន្ទះអន្ទែង នឹងឲ្យស្រេកឃ្លានត្រេកត្រអាលសប្បាយរីករាយចំពោះអារម្មណ៍ ៥ មានរូបជាដើម ដែលជាហេតុ នាំឲ្យសត្វស្រវឹងជ្រុលជ្រប់វង្វេងវិលវល់នៅក្នុងវដ្តសង្សារ រងទុក្ខវេទនារកទីបំផុតគ្មានឡើយ ។

អាស្រ័យហេតុដូចខាងលើនេះ ទើបលោកចាត់ទុកពគាទិក្កិលេសជាកិលេសកាមគឺកិលេសជាអ្នកញុះញង់ នឹងលួងលោមចិត្តឲ្យប្រាថ្នាឲ្យពេញចិត្តនូវអារម្មណ៍ ៥ មានរូបជាដើម, ហើយលោកចាត់ទុកអា-រម្មណ៍ ៥ នោះជាវត្ថុកាម គឺវត្ថុដែលជាទីគួរឲ្យប្រាថ្នាគួរឲ្យពេញចិត្ត, ព្រោះអារម្មណ៍ ៥ នោះ សុទ្ធតែមានសុភនិមិត្តគឺគ្រឿងសំគាល់ថាល្អប្រចាំរៀងខ្លួនដូចជា:

រូបមានឆោមល្អប្រិមប្រិយជាដើម ជាសុភនិមិត្តលួងលោមចិត្តឲ្យស្រឡាញ់នឹងឲ្យប្រាថ្នា ។

សម្លេងពីរោះ ជាសុភនិមិត្តលួងលោមចិត្តឲ្យចង់ស្តាប់ ។ល។ គឺដំ-ណើរចំរើននៃសេចក្តីប្រាថ្នានូវអារម្មណ៍ ៥ នេះ ឬ សេចក្តីជំពាក់ចិត្តនឹងសេចក្តីប្រាថ្នានូវអារម្មណ៍ ៥ មានរូបជាដើមនេះហើយ ដែលហៅថា

កាមគុណនោះ ៗ ដោយហេតុនេះ ទើបសត្វដែលមានសន្តានចិត្តសៅហ្មងដោយកិលេសកាមនោះហើយ រមែងតែស្រវឹងជ្រុលជ្រប់វង្វេងភ្លេចខ្លួនជាប់ស្អិតនឹងវត្ថុកាមពោលគឺអារម្មណ៍ ៥ នោះ កម្រនឹងដកទាញចិត្តឲ្យរួចផុតពីវត្ថុកាមនោះបានដោយងាយស្រួលឡើយ ៗ

មិនតែប៉ុណ្ណោះ រាគាទិកិលេសនេះ លោកចាត់ទុកជាសមុដ្ឋាននៃតណ្ហា ពីព្រោះតណ្ហាដែលនឹងមានដំណើរប្រព្រឹត្តទៅជាប្រក្រតីបាន គឺព្រោះតែរាគាទិកិលេសនោះជាមូលហេតុ ៗ

តើតណ្ហានោះជាអ្វី ?

វចនានុក្រមឆ្លើយប្រាប់ថា ឯតណ្ហានោះគឺបំណង, សេចក្ដីប្រាថ្នា, សេចក្ដីស្រេកឃ្លាន ឬសេចក្ដីអន្ទះអន្ទែង ៗ

រីឯលក្ខណៈនៃតណ្ហានោះ មានសៀវភៅសតិបដ្ឋានសូត្រ ទ្រង់ទំព័រ ១០៣ ប្រាប់បញ្ជាក់ឲ្យដឹងថា : តណ្ហាឯណាដែលមានកិរិយាធ្វើនូវភពថ្មីជាប្រក្រតី កើតរលត់ព្រមដោយនន្ទិរាគៈ ត្រេកអរក្នុងភពនោះ ៗ ឬក្នុងអារម្មណ៍នោះ ៗ តណ្ហានោះហៅថា ទុក្ខសមុទយអរិយសច្ចៈ ៗ

សេចក្ដីបញ្ជាក់អំពីតណ្ហា ដែលខ្ញុំនាំយកមកពណ៌នាខាងលើនេះ ឃើញថាមានន័យគ្រោះគ្រាយល្មមឲ្យយល់បានហើយ ៗ

រីឯតណ្ហានោះមាន ៣ ប្រការគឺ :

- កាមតណ្ហា គឺសេចក្តីប្រាថ្នាចង់កើតក្នុងកាមភព ដោយមាន
កាមរាគ ជាសមុដ្ឋាន ។
- ភវតណ្ហា គឺសេចក្តីប្រាថ្នាចង់កើតក្នុងរូបភព ដោយមាន
រូបរាគ ជាសមុដ្ឋាន ។
- វិភវតណ្ហា គឺសេចក្តីប្រាថ្នាចង់កើតក្នុងអរូបភព ដោយមាន
អរូបរាគ ជាសមុដ្ឋាន ។

គឺតណ្ហានេះហើយ ដែលលោកចាត់ទុកជាមេជាង គឺជាអ្នកទទួលការកិច្ចខាងការស្ថាបនាកសាងខន្ធ ៥ គឺអត្តភាព ឬរូបកាយនៃសត្វឲ្យកើតមានក្នុងភពថ្មីទៀតនោះ ។

អាស្រ័យហេតុនេះ ទើបបណ្ឌិតទាំងឡាយ កាលបើបានដឹងជាក់ច្បាស់នូវទោសនៃពួកលោភាទិក្កិលេស និងពួករាគាទិក្កិលេស ហើយនិងទោសនៃតណ្ហាដូច្នេះហើយ រមែងតែព្យាយាមបំពេញកាតព្វធម៌ផ្សេង ៗ មានការចំរើនសមថកម្មដ្ឋាន និងវិបស្សនាភាវនាជាដើម ដើម្បីជាប្រយោជន៍ដល់ការត្រាស់ដឹងនូវមគ្គ ៤ ផល ៤ និងនិព្វាន ពីព្រោះមគ្គ ផល និព្វាន នេះ ៖

១— ជាវិមោក្ខធម៌ គឺធម៌អាចញ៉ាំងសត្វឲ្យរួចចាកកិលេស និងតណ្ហានោះបាន ។

២– ជាមោក្ខធម៌ គឺធម៌អាចញុំាងសត្វឲ្យរួចចាកកងទុក្ខ មានជាតិទុក្ខជាដើមបាន ។

៣– និងជាលោកុត្តរធម៌ គឺធម៌អាចបម្លងសត្វឲ្យឆ្លងចេញរួចចាកលោក លែងត្រឡប់មកអន្ទោលវិលកើតវិលស្លាប់ក្នុងភពតូចភពធំទៀត ។

សេចក្តីឆ្លើយអំពីសំនួរ ៨ ១

ដើម្បីឲ្យអស់លោក-អ្នកអានសៀវភៅនេះ បានយល់អំពីកិលេសកាន់តែជ្រៅទៅទៀត ខ្ញុំនឹងធ្វើអត្ថាធិប្បាយឆ្លើយដោះស្រាយអំពីសំនួរដូចតទៅនេះ ៖

សំនួរទី ១ — តើហេតុដូចម្តេចបានជាក្នុងពួកអកុសលមូលគឺ លោភៈ ទោសៈ មោហៈ និងក្នុងពួកកិលេសមូលគឺ រាគៈ ទោសៈ មោហៈ នោះគេឃើញមានទោសៈ និងមោហៈដូចគ្នា យ៉ាងដូច្នេះ ?

សេចក្តីឆ្លើយ– បានជាដូច្នេះ ពីព្រោះទោសៈ និងមោហៈនោះ កាលបើនៅជាប់ជាមួយនឹងលោភៈ ត្រូវមានន័យប្លែកផ្សេងបន្តិចអំពីទោសៈ និងមោហៈ ដែលនៅជាប់ជាមួយរាគៈ ។ អាស្រ័យហេតុនេះ កាលបើទោសៈ មោហៈ នៅជាប់ជាមួយលោភៈ ដែលជាអកុសលមូលនោះទោសៈ មោហៈ នោះត្រូវមានន័យដូច្នេះគឺ ៖

ទោសៈ គឺសេចក្តីប្រទូស្ត ឬកំហឹងខឹងក្រៀងហេតុ និងបៀតបៀនអ្នកដទៃឲ្យដល់នូវសេចក្តីវិនាសនិងសេចក្តីអន្តរាយផ្សេង ៗ ។

មោហៈ  គឺសេចក្តីវង្វេង  សេចក្តីលង់យល់ខុសហើយប្រកាន់ឡើងថាជាត្រូវដែលជាហេតុនៃមិច្ឆាទិដ្ឋិ ។

កាលបើទោសៈនិងមោហៈនៅជាប់ជាមួយនឹងរាគៈវិញ ទោសៈនិងមោហៈនោះគប្បីមានន័យផ្សេងដូច្នេះគឺ ៖

ទោសៈ  នេះគួរមានន័យត្រឹមតែបដិឃៈគឺសេចក្តីចង្អៀតចង្អល់ចិត្តឬថ្នាំងថ្នាក់ចិត្ត  ពីព្រោះអនិដ្ឋារម្មណ៍គ្រាន់តែធ្វើចិត្តឲ្យចង្អៀតចង្អល់មិនឲ្យរីករាយ  មិនឲ្យសប្បាយតែប៉ុណ្ណឹង  កម្រនឹងបណ្តាយឲ្យកើតទៅជាសេចក្តីប្រទូស្ត ឬបៀតបៀនឡើយ ។

មោហៈ  គឺសេចក្តីវង្វេងគាំងគំនិត  ឲ្យយល់ខុសក្នុងដំណើរនៃសង្ខារធម៌ព្រមទាំងយល់ខុសក្នុងផ្លូវស្វែងរកសេចក្តីសុខ  ដែលជាហេតុនៃសីលព្វតបរាមាសៈ គឺសេចក្តីពប់អានចូលចិត្តនឹងប្រតិបត្តិខុសទំនង ។ គឺមកតែពីទោសៈ មោហៈ មានន័យផ្សេងគ្នាយ៉ាងនេះហើយ  ទើបកិលេសទាំង ២ ពួកនោះមានទោសៈនិងមោហៈដូចគ្នា ។

សំនួរទី ២. អ្វីជាមូលហេតុដែលអាចញុំាងរាគៈ  ទោសៈឲ្យចូលមកកើតក្នុងខន្ធសន្តានបាន ?

សេចក្តីឆ្លើយ-  គឺអារម្មណ៍ ៤ មានរូបជាដើម  ពីព្រោះបើអារម្មណ៍នោះជាឥដ្ឋារម្មណ៍  គឺអារម្មណ៍ជាទីពេញចិត្តនោះ  រមែងតែញុំាង

សោមនស្សឲ្យកើតឡើងដែលជាហេតុនាំឲ្យរាគៈ គឺសេចក្តីត្រេកត្រអាលរីករាយ មកកើតក្នុងខន្ធសន្តាន ។

មួយវិញទៀត បើអារម្មណ៍នោះជាអនិដ្ឋារម្មណ៍ គឺអារម្មណ៍មិនជាទីពេញចិត្តវិញ ក៏រមែងតែញុំាងទោមនស្សឲ្យកើតឡើង ដែលជាហេតុនាំឲ្យទោសៈ គឺសេចក្តីអាក់អន់ចិត្ត ប្អូចឆ្អៀតចង្អល់ចិត្ត មកកើតក្នុងខន្ធសន្តានជាដរាប ។

រីឯមូលហេតុនៃមោហៈនោះ មិនគឺអ្វីក្រៅពីអវិជ្ជាទេ ពីព្រោះកាលបើសត្វណាគ្មានវិជ្ជាអ្វីសោះ សត្វនោះត្រូវតែល្ងង់ វង្វេងយល់ខុសពីការណ៍ពិតជាដរាប ។

**សំនួរទី ៣**_ កាលបើដឹងនូវមូលហេតុនៃរាគៈ ទោសៈ មោហៈ ដូច្នេះហើយ តើបុគ្គលជាបុថុជ្ជនអាចនឹងលះរាគៈ ទោសៈ មោហៈ ឲ្យដាច់ស្រឡះទៅបានឬទេ ?

**សេចក្តីឆ្លើយ**_ ទោះបីបានដឹងនូវមូលហេតុនៃរាគៈ ទោសៈ មោហៈ ដូច្នេះក៏ដោយ បុគ្គលជាបុថុជ្ជនពុំអាចនឹងលះរាគៈ ទោសៈ មោហៈ ឲ្យដាច់ស្រឡះទៅបានទេ បើគ្រាន់តែធ្វើរាគៈ ទោសៈ មោហៈឲ្យស្ងប់រម្ងាប់ស្រាលស្បើយពីខន្ធសន្តានតែប៉ុណ្ណោះ ទើបបុគ្គលជាបុថុជ្ជនអាចធ្វើឲ្យសម្រេចទៅបាន ដោយខំព្យាយាមសង្រួមឥន្ទ្រិយទាំង ៦ ប្រុងសតិសម្បជញ្ញៈប្រយ័ត្នកុំឲ្យសោមនស្ស នឹងទោមនស្សកើតឡើងបាននូវពេល

ដែលអារម្មណ៍ខាងក្រៅមានរូបជាដើម មកប៉ះនឹងអាយតនៈខាងក្នុងមានភ្នែកជាដើម ហើយដំកល់ចិត្តឲ្យតាំងនៅក្នុងឧបេក្ខាធ្វើព្រងើយកន្តើយមិនអើពើចំពោះអារម្មណ៍នោះ ឲ្យបានយូរដរាបណា ដរាបនោះរាគៈ ទោសៈ មោហៈក៏ពុំអាចនឹងកើតឡើងបានឡើយ ។

ក៏ប៉ុន្តែឧបេក្ខានេះ ជាព្រហ្មវិហារុបេក្ខាអាចតាំងនៅយូរបានតែត្រឹម ១ ខណៈដែលបុគ្គលកំពុងប្រុងស្មារតីសង្រួមឥន្ទ្រីយតែប៉ុណ្ណោះ លុះកាលណាលែងសង្រួមចិត្តគំនិតហើយ ឧបេក្ខានោះត្រូវផ្លាស់វេនឲ្យសោមនស្ស ឬឲ្យទោមនស្សចូលមកជំនួសខ្លួនវិញ ហើយនៅឱកាសនោះ រាគៈ ទោសៈ មោហៈ ក៏នឹងកើតឡើងវិញជាធម្មតា ។

សំនួរទី ៤– បើបុគ្គលនោះជាអរិយបុគ្គលវិញ តើលោកត្រូវធ្វើដូចម្តេចទើបលះរាគៈ ទោសៈ មោហៈ ឲ្យដាច់ស្រឡះទៅបាន ?

ចម្លើយ – ប្រសិនជាអរិយបុគ្គលវិញ លោករមែងតែលះរាគៈ ទោសៈ មោហៈ ឲ្យដាច់ស្រឡះអស់ពីខន្ធសន្តានដោយឈានូបេក្ខា គឺឧបេក្ខាដែលជាអង្គទី ២ នៃចតុត្ថជ្ឈាន ពីព្រោះឈានចិត្តទី ៤ នេះ ដែលសម្បយុត្តដោយអង្គឯកគ្គតា នឹងឧបេក្ខាតែងតាំងនៅជាកណ្តាលព្រងើយកន្តើយជានិច្ចចំពោះអារម្មណ៍ ៥ មានរូបជាដើម ធ្វើហាក់ដូចជាបិទទ្វារទាំង ៦ មានចក្ខុទ្វារជាដើម ប្រឆាំងរាំងមិនឲ្យរាគៈ ទោសៈ មោហៈ ចូលមកកើតក្នុងខន្ធសន្តានបានជាដាច់ខាត ដែលអាចនឹងញ៉ាំងអរិយ-

បុគ្គលអង្គនោះឲ្យលះរាគាទិកិលេសដាច់ស្រឡះអស់ពីខន្ធសន្តាន ដោយប្រការដូច្នេះឯង ។

សំនួរទី ៥– ហេតុដូចម្តេចបានជាអរិយបុគ្គលកន្លងដំណើរលះកិ-លេសនោះ ឃើញព្យាយាមលះតែសំយោជនៈ ១០ មិនឃើញខំព្យាយាមលះកិលេសឯទៀតមាន លោភៈ ទោសៈ មោហៈ ជាដើមផង ?

សេចក្តីឆ្លើយ– បានជាអរិយបុគ្គល លោកប្រព្រឹត្តដូច្នេះ ពីព្រោះសំយោជនៈ ១០ នោះ ជាកិលេសរឹងត្អឹងរឹតរួតចិត្តសត្វ ធ្វើឲ្យសត្វវង្វេងភ្លេចភាំងស្មារតី ភ្លេចខ្លួនជាប់ស្អិតនៅវិលវល់ក្នុងវដ្តសង្សារ ។

ម្យ៉ាងទៀត ពីព្រោះសំយោជនៈ ១០ ជាសមុដ្ឋាននៃតណ្ហា ៣ ប្រការដែលលោកចាត់ទុកថាជាមេជាងទទួលការកិច្ច ខាងការស្ថាបនាកសាងខន្ធ ៥ ឲ្យកើតមានក្នុងភពថ្មីទៀត ៗ ដើម្បីឲ្យរួចចាកផុតពីកណ្តាប់ដៃនៃតណ្ហា ៣ ប្រការនោះ ទើបអរិយបុគ្គលលោកព្យាយាមខំលះសំយោ-ជនៈ ១០ នោះឯង ។

ម្យ៉ាងវិញទៀត គប្បីយល់ថា ខន្ធសន្តានដែលរួចចាកសំយោជនៈ ១០ ហើយលែងអន្ទះអន្ទែង, លែងស្រេកឃ្លាននូវវត្ថុកាមទៅហើយ ក៏រមែងតែនឿយណាយលែងស្រេកឃ្លាន ចង់បាននូវលោកិយសម្បត្តិជាលំដាប់ដែរ ។

សំនួរទី ៦– ឈានដែលលោកចាត់ទុកថាជាគ្រឿងសម្រាប់ផុត

កំដៅខ្លួនសន្តានឲ្យរីងស្ងួតចាកកាមាទិកិលេសនោះ តើឈាននោះអាចដុតកំដៅខ្លួនសន្តានឲ្យរីងស្ងួតទៅបានដោយប្រការដូចម្តេចខ្លះ ?

សេចក្តីឆ្លើយ ឯពាក្យដែលពោលដូច្នេះ គឺជាពាក្យពោលដោយអត្ថប្បដិរូបគឺដោយបញ្ចិតបញ្ចៀង ពីព្រោះឈានចិត្តមានចតុត្ថជ្ឈានជាដើម មានអង្គឯកគ្គតានឹងឧបេក្ខាជាអ្នករង់ចាំតែបិទទ្វារទាំង ៦ មានចក្ខុទ្វារជាដើម មិនឲ្យរាគៈ ទោសៈ មោហៈ មកកើតក្នុងខ្លួនសន្តានបាន ដែលជាហេតុនាំឲ្យខ្លួនសន្តាននោះរីងស្ងួតចាកកាមាទិកិលេសអស់ទៅ ។

អាស្រ័យហេតុនេះ បានជាលោកអ្នកប្រាជ្ញ លោកពោលដោយសន្មតថា ឈានជាគ្រឿងដុតពេលខ្លួនសន្តាន ឲ្យរីងហួតស្ងួតចាកកាមាទិកិ-លេសដោយប្រការដូច្នេះឯង ។

រីឯវិបស្សនាញាណក៏ដូចឈាននោះដែរ ពីព្រោះវិបស្សនាញាណគឺញាណដែលដឹងច្បាស់នូវដំណើរនៃសង្ខារទៅតាមការណ៍ពិត, រមែងតែពាំងមោហៈ នឹងមិច្ឆាទិដ្ឋិ មិនឲ្យមកកើតក្នុងខ្លួនសន្តានបាន ដែលជាហេតុនាំឲ្យខ្លួនសន្តានរួចចាកមោហៈនឹងមិច្ឆាទិដ្ឋិទៅបាន ។

សំនួរទី ៣_ ម្យ៉ាងទៀត ហេតុដូចម្តេចបានជាការរលត់នៃកិ-លេសទៅជាហេតុអាចនឹងញុំាងជាតិ គឺការកើតឡើងនៃបញ្ចក្ខន្ធឲ្យរលត់ទៅផងដែរ ?

(នៅមានត)

# ព្រះអភិធម្មបិដក

## គម្ពីរព្រះយមក

*លោក ប៊ូ-ប៊ូ ប្រែរៀបរៀង*

(តមក)

---

កុលុបកត្ថេរំ បុច្ឆិ បុរសជាបុត្រអមាត្យនឹកបង់ចំរើនមេត្តាព្រហ្មវិហារ ទើបទូលសួរព្រះមហាថេរថា "ភន្តេ បពិត្រលោកម្ចាស់ ការចំរើនមេត្តានោះ តើនឹងឲ្យចំរើនទៅក្នុងបុគ្គលណា ?" ។

ព្រះមហាថេរប្រាប់ថា "បិយបុគ្គលេ ភាវេតព្វា បុគ្គលគប្បីចំរើនមេត្តាទៅក្នុងបុគ្គលជាទីស្រឡាញ់" ។ បុត្រអមាត្យមានភរិយាជាទីស្រឡាញ់ពេញចិត្តណាស់ ទើបផ្សាយមេត្តាទៅក្នុងភរិយា ក៏រអិលចិត្តធ្លាក់ទៅខាងកាមៈ (តម្រេក) ចាប់ចិត្តប្រតិព័ទ្ធក្នុងភរិយារបស់ខ្លួន រឹតតែទ្វេឡើង មិនអាចញុំាងមេត្តាឲ្យតាំងនៅបាន មានចិត្តពោរពេញទៅដោយកាមៈវិញ ។

មានព្រះបាលីទទួលពីររងជាសំអាង ដែលអាចារ្យពោលទុកថា "សព្វរត្តិ ភិត្តិយុទ្ធិ អកាសិ បុត្រអមាត្យខំអត់សង្កត់រំលត់ចិត្តមិនបាន ព្រោះហេតុផ្សាយមេត្តាទៅក្នុងអារម្មណ៍ជាវិសភាគគឺស្ត្រីមិនអាចញុំាងមេត្តាឲ្យកើតឡើងបាន ទើបលោកហាមមិនឲ្យផ្សាយក្នុងស្ត្រីជាមុន ។

ការដែលលោកហាមមិនឲ្យផ្សាយមេត្តាទៅក្នុងបុគ្គលស្លាប់នោះ ព្រោះមិនបានឧបចារជ្ឈាននឹងអប្បនាឈានទេ ដូចភិក្ខុកម្លោះមួយរូបចំរើនមេត្តា

កម្មដ្ឋានប្រារព្ធព្រះមហាថេរជាអាចារ្យ ដែលរលត់សង្ខារទៅហើយ ។ មេត្តាកម្មដ្ឋានក៏មិនបានប្រាកដ ភិក្ខុនោះកំណត់សំគាល់ថា "បត្តុណ្ណភាច មេត្តា អាត្មាអញទើងចំរើនមេត្តាៗ នេះក៏ស្អាតជំនាញចាំមាត់ប្រាកដក្នុងចិត្តអញ ហេតុអ្វីបានជាឧបចារជ្ឈានទើងអប្បនាឈានមិនកើតឡើង" សំគាល់ដូច្នេះហើយ ទើបចូលទៅរកព្រះមហាថេរជាធំ ទូលសួរថា "បពិត្រព្រះករុណាម្ចាស់! ខ្ញុំព្រះករុណាចំរើនមេត្តាពាល់តែស្អាត ចាំរត់មាត់ប្រាកដក្នុងចិត្ត ប៉ុន្តែមិនអាចធ្វើឲ្យកើតឧបចារជ្ឈានទើងអប្បនា-ឈានបាន ហេតុអ្វីបានជាយ៉ាងនេះ ? " ។

ព្រះមហាថេរប្រាប់ថា "គវេសាហិ អ្នកចូរស្វែងរកនិមិត្តចុះ" ។ ភិក្ខុនោះពិចារណាទៅក៏យល់ថា "អាត្មាផ្សាយមេត្តាទៅក្នុងលោកអាចារ្យដែលរលត់បញ្ចក្ខន្ធទៅហើយ" យល់ដូច្នោះ ទើបចំរើនមេត្តាប្រារព្ធបុគ្គលដទៃវិញ ក៏បាននូវមេត្តាសមាបត្តិ ។ ហេតុនោះ បានជាលោកហាមមិនឲ្យផ្សាយទៅក្នុងបុគ្គលស្លាប់ ។

ភិក្ខុចំរើននូវមេត្តាកម្មដ្ឋាន គប្បីចំរើន មេត្តាទៅក្នុងខ្លួនជាមុន ។ ចំរើនមេត្តាក្នុងខ្លួនឯងនោះថា "អហំ សុខិតោ ហោមិ ចូរឲ្យអាត្មាបានសុខ កុំឲ្យមានទុក្ខ ចូរកុំឲ្យមានពៀរពយាបាទអន្តរាយ ចូររក្សាខ្លួនឲ្យបានសុខ" ។ ឲ្យចំរើននូវខ្លួនរឿយ ៗ យ៉ាងនេះជាមុនជាងបុគ្គលដទៃទៀត មេត្តាឈានក៏នឹងកើតមានឡើង ។

មានពាក្យបុច្ឆាថា៖ ឯវំ សន្តេ កាលបើផ្សាយមេត្តាក្នុងខ្លួនជាមុន មិនផ្សាយមេត្តាក្នុងបុគ្គលទាំងពួងជាមុនដូច្នេះ តើពាក្យដែលសម្តេចព្រះមានព្រះភាគត្រាស់ក្នុងគម្ពីរព្រះវិភង្គថា ឯកំ ទិសំ ផរិត្វា ភិក្ខុ ប្រាប់ថានឹងចំរើនមេត្តា គឺផ្សាយក្នុងទិសមួយនឹងទិសពីរជាអាទិដោយចិត្តមេត្តា ឯពាក្យក្នុងគម្ពីរបដិសម្ភិទាថា ឲ្យផ្សាយមេត្តាទៅក្នុងសព្វសត្វ នឹងពាក្យក្នុងមេត្តសូត្រថា សម្តេចព្រះមានព្រះភាគត្រាស់ទេសនាថា ឲ្យភិក្ខុទាំងឡាយផ្សាយមេត្តាចិត្តកុំឲ្យរើសមុខ ហើយគប្បីពោលថា ដោយកំណត់ទុកក្នុងចិត្តថា សុខិនោ វា ខេមិនោ ហោន្តុ សត្វទាំងឡាយទាំងពួងចូរប្រកបដោយសេចក្តីសុខ, អស់ទុក្ខ; អស់ភ័យ, មានកាយនឹងចិត្តជាសុខ ។ ពាក្យទាំងឡាយដែលសម្តេចព្រះមានព្រះភាគត្រាស់ទេសនាក្នុងគម្ពីរវិភង្គ នឹងគម្ពីរបដិសម្ភិទា នឹងក្នុងមេត្តសូត្រ ដែលប្រាប់ឲ្យផ្សាយមេត្តាចិត្តទៅក្នុងសត្វទាំងពួង មិនខុសពីពាក្យដែលថា កុំឲ្យផ្សាយមេត្តាចិត្តទៅក្នុងមនុស្សទាំងឡាយជាមុនទៅហើយ ឬក៏មានន័យយ៉ាងណាទៅវិញ ? ។

មានពាក្យវិសជ្ជនាថា ពាក្យដែលថាឲ្យផ្សាយមេត្តាចិត្តក្នុងខ្លួនជាមុន នឹងពាក្យក្នុងគម្ពីរវិភង្គជាដើមនោះមិនខុសទេ ព្រោះហេតុថាឲ្យផ្សាយទៅក្នុងខ្លួនជាមុននោះ ដោយអំណាចបុគ្គលចំរើនមេត្តាក្នុងខាងដើម ឲ្យផ្សាយមេត្តាទៅឥតរើសមុខ ដោយអំណាចនៃបុគ្គលដល់នូវអប្បនាឈាន

នឹងឲ្យផ្សាយមេត្តាទៅក្នុងខ្លួនជាមុននោះ គឺនឹងបានធ្វើខ្លួនឲ្យជាបន្ទាល់ ហើយផ្សាយមេត្តាទៅក្នុងសត្វទាំងឡាយឥតលំបាកចិត្ត ។ ហេតុនោះ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា "ពាក្យដែលថាមកទាំងអស់នេះ មិនខុសគ្នាទេ គប្បីចូលចិត្តតាមន័យនេះចុះ" ។

## វិធីបំរើនមេត្តា

អថា ខេន អរិយបុគ្គលេសុ យត្ថ កាត្ថចិ បុឆប្បំ មេត្តំ សមាបជ្ជិត្វា វុដ្ឋហិត្វា បុឆប្បំ តំ បុគ្គលំ មេត្តាយន្តេន បដិឃំ វិនោទេតព្វន្តិ ។

លំដាប់នេះ នឹងពណ៌នានូវវិធីបំរើនមេត្តាតទៅ សេចក្តីថា: អថា ខេន ក្នុងកាលព្រះយោគាវចរកុលបុត្រផ្សាយមេត្តាទៅក្នុងបុគ្គលមានពៀរនឹងគ្នាដែលនៅជាបុថុជ្ជន លុះរឭកនឹកទៅដល់អ្នកមានពៀរនឹងគ្នាហើយ បដិឃចិត្តំ (ចិត្តគិតនឹងបៀតបៀន) ក៏កើតមានឡើង ហេតុតែនឹករឭកឃើញទោស ដែលបុគ្គលមានពៀរនឹងខ្លួននោះបានធ្វើដល់ខ្លួន កាលបដិឃចិត្តគិតបៀតបៀនបំផ្លិចបំផ្លាញគ្នាកើតហើយ ក៏ខំកំចាត់បង់ចេញបាន បើមិនព្យាយាមលះបង់ទេ ចិត្តបដិឃៈមិនរលត់ឡើយ គប្បីនឹករឭកដល់ព្រះបរមពុទ្ធោវាទទាំងឡាយ ដែលព្រះសាស្តាត្រាស់ដោយឧបមាក្នុងកកចូបមសូត្រជាដើម ហើយគប្បីឲ្យឱវាទប្រៀនប្រដៅខ្លួន

ដោយខ្លួនឯងថា "អវេរ គារុជ្ឈគារុរិស ម្នាលអ្នកជាបុរសច្រើន ដោយសេចក្ដីក្រោធ ជាមនុស្សអាក្រក់ សម្ដេចព្រះមានព្រះភាគមានព្រះពុទ្ធាធិប្បាយប្រោសប្រទាននូវព្រះបរមពុទ្ធោវាទថា សរេច បិ កិច្ចរេ គាការេច្ចុន ចោរា ម្នាលភិក្ខុទាំងឡាយ ចោរទាំងឡាយប្រព្រឹត្តនូវការដ៏ខ្មៅអាក្រក់ បើពាកាត់អវយវៈតូចធំរបស់អ្នក ហើយអ្នកខឹងនឹងចោរមានចិត្តប្រទូស្តរាយនឹងចោរវិញ អ្នកមិនឈ្មោះថាប្រតិបត្តិតាមឱវាទរបស់ព្រះតថាគតទេ យេភា បិ បដិគារុជ្ឈតិ សូម្បីភិក្ខុណាក្រោធខឹងតបនឹងបុគ្គលអ្នកក្រោធ ភិក្ខុនោះឈ្មោះថាប្រកបដោយកម្មដ៏អាក្រក់លា-មកគឺនឹងកាត់បង់នូវប្រយោជន៍ នឹងធ្វើខ្លួនឲ្យធ្លាក់ទៅក្នុងអបាយ ទាំងបួនមាននរកជាដើម គារុទ្ធអប្បដិគារុជ្ឈន្តោ បុគ្គលមិនក្រោធខឹងតបតទៅបុគ្គលអ្នកក្រោធខឹងនឹងខ្លួននោះ ឈ្មោះថាឈ្នះនូវសង្គ្រាមដែលគេឈ្នះបានដោយក្រ ឧភិន្នំ អត្ថំ ចរតិ បុគ្គលមិនក្រោធខឹងតបតនឹងអ្នកក្រោធខឹងនោះ ឈ្មោះថា ប្រព្រឹត្តធ្វើនូវប្រយោជន៍ ដល់បុគ្គលពីរនាក់ គឺខ្លួន ១ អ្នកដទៃ ១" ។

មនុស្សកើតមកក្នុងលោក គ្មានអ្នកណាម្នាក់មិនក្រោធខឹងទេ សុទ្ធតែក្រោធខឹងគ្រប់គ្នា ប៉ុន្តែ អ្នកណាមានស្មារតីត្រិះរិះថា "ចិត្តអញក្រោធខឹងហើយ ក៏ខំខាំមាត់អត់សង្កត់ដកការសំលើងចេញដោយចបគី ១ ដង្ក ឲ្យរឭកនឹកដល់ព្រះបរមពុទ្ធោវាទយ៉ាងនេះហើយ ទើបនឹងដំកល់ខ្លួនទុក

ក្នុងមូលនៃកុសលគឺ អទោសោ បាន អាស្រ័យមានខន្តី គឺសេចក្តីអត់ធន់" ។

ប្រការមួយទៀត ការដែលលះបង់នូវបដិឃចិត្តនោះ គប្បីកំណត់ក្នុងចិត្តតាមព្រះពុទ្ធដីកាដែលព្រះភគវន្តមុនីប្រទានព្រះសទ្ធម្មទេសនា ទុកថា "សត្តិមេ ភិក្ខវេ ធម្មា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៧ ប្រការ រមែងជាទីប្រាថ្នានៃបុគ្គលជាសត្រូវ ជាហេតុនៃបុគ្គលជាសត្រូវ រមែងមកដល់នូវស្ត្រីនិងបុរសដ៏ប្រកបដោយសេចក្តីក្រោធ" ត្រាស់ប៉ុណ្ណោះហើយ ទើបទ្រង់ត្រាស់បុច្ឆាថា "កតមេ សត្ត ធម៌ ៧ ប្រការ ជាទីប្រាថ្នានៃបុគ្គលជាសត្រូវនឹងគ្នានោះ តើគឺធម៌ណាខ្លះ ?"

ទើបត្រាស់វិសជ្ជនាដោយព្រះអង្គឯងថា "ម្នាលភិក្ខុសង្ឃ បុគ្គលជាសត្រូវក្នុងលោកនេះ រមែងប្រាថ្នាដល់បុគ្គលជាសត្រូវនឹងខ្លួនថា អ-ហោ វត ដូចអាត្មាអញប្រាថ្នា បុគ្គលនេះ គប្បីមានពណ៌សម្បុរអាក្រក់ជាទីស្អប់ខ្ពើមរបស់ជនទាំងឡាយ ហើយកុំឲ្យប្រកបដោយកិត្តិសព្ទ និងកិត្តិគុណឡើយ" ។ បុគ្គលជាសត្រូវប្រាថ្នាដល់បុគ្គលជាសត្រូវនឹងខ្លួនយ៉ាងនេះជាដើម ហេតុនោះ បុគ្គលជាសត្រូវនោះ មិនដែលប្រាថ្នាឲ្យបុគ្គលជាសត្រូវនឹងខ្លួន មានសេចក្តីសរសើរ ដេកជាសុខ និងមានភោគសម្បត្តិ, មានយសសក្តិ, អស់ជីវិតហើយទៅដេកនៅស្ថានសួគ៌ដូច្នេះសោះឡើយ ។ កោធនំ ធាយំ ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ

បុគ្គលក្រោធខឹងច្រើន សេចក្ដីក្រោធគ្របសង្កត់ជាប់ជានិច្ច មានចិត្តក្រោធជាត្រីមុខ រមែងប្រព្រឹត្តធ្វើនូវអំពើទុច្ចរិតដោយកាយវាចា នឹងចិត្ត កាយស្ស កេនា លុះអស់ជីវិតព្រោះកាយបែកធ្លាយហើយ រមែងទៅកើតក្នុងទុគ្គតិចតុរាបាយ គឺអសុរកាយ, ប្រេត, នរក នឹងសត្វតិរច្ឆានៗ

អ្នកប្រាជ្ញគប្បីនឹករឭកដល់ក្រសែព្រះពុទ្ធបរិហារដែលប្រទានទេសនាទុកដូចពោលមកហើយ គប្បីព្យាយាមកំចាត់បង់នូវចិត្តក្រោធខឹងចេញកុំឲ្យកើតមានឡើងក្នុងខន្ធសន្ដានបាន បើព្យាយាមអត់សង្កត់ក្រោធបានហើយ បដិឃចិត្តក៏ស្ងប់រម្ងាប់ នេះជាកុសល ៗ បើសុចរិតធម៌ណារបស់បុគ្គលនោះបរិសុទ្ធផូរផង់ គប្បីនឹករឭកដល់សុចរិតធម៌របស់បុគ្គលនោះឲ្យរឿយ ៗ លុះបានរឭកឃើញរឿយ ៗ ហើយ ក៏នឹងកំចាត់បង់នូវសេចក្ដីអាឃាតគំនុំគុំគួនចងពៀរព្យាបាទឲ្យដាច់បាន ៗ

បុគ្គលពួកមួយក្នុងលោកនេះ មានកាយសមាចារ គឺអាការប្រព្រឹត្តដោយកាយស្ងប់រម្ងាប់ ក៏ជាទីស្រឡាញ់នៃជនទាំងពួង ៗ បុគ្គលពួកមួយស្ងប់រម្ងាប់ល្អតែកាយម្យ៉ាង ឯវាចានឹងចិត្តមិនស្ងប់ល្អ កុំគប្បីគិតនឹកដល់វាចាសមាចារ នឹងមនោសមាចារនៃបុគ្គលនោះឡើយ គប្បីនឹករឭករឿយ ៗ តែកាយសមាចាររបស់អ្នកនោះម្យ៉ាង ។ បុគ្គលពួកមួយប្រព្រឹត្តល្អស្ងប់រម្ងាប់តែកាយនឹងវាចា ឯចិត្តមិនស្ងប់ល្អ មិនស្ងប់រម្ងាប់ បុគ្គលនោះក៏ជាទីស្រឡាញ់របស់ជនទាំងពួង ព្រោះហេតុឈ្មោះថាក្នុងសំដីនិយាយ

ភក់ទាក់ទទួលបដិសណ្ឋារៈចំពោះគេឡើ ។ កុលបុត្រអ្នកចំរើនមេត្តាព្រហ្ម-វិហារ កុំគប្បីគិតដល់កាយសមាចារ និងវចីសមាចារនៃបុគ្គលនោះឡើយ គប្បីនឹករឭកតែឿយៗ តែវាចាសមាចាររបស់បុគ្គលនោះ ។ បុគ្គលពួកខ្លះប្រព្រឹត្តល្អផ្លូវចិត្ត តែកាយនឹងវាចាមិនស្ងប់ល្អ ។ កុលបុត្រអ្នកចំរើនមេត្តាព្រហ្មវិហារផ្សាយទៅកាន់បុគ្គលនោះ កុំគប្បីគិតនូវកាយសមាចារនឹងវាចាសមាចារនៃបុគ្គលនោះឡើយ គប្បីនឹករឭកតែមនោសមាចាររបស់អ្នកនោះម្យ៉ាង ។ បុគ្គលប្រព្រឹត្តល្អផ្លូវចិត្តនោះ ប្រាកដក្នុងកាលសំពះព្រះចេតិយ ព្រះស្រីមហាពោធិជាដើម អវូបសន្តចិត្តោ បុគ្គលអ្នកមានចិត្តមិនស្ងប់រម្ងាប់នោះ នមស្ការព្រះមហាថេរ, ព្រះចេតិយនឹងព្រះស្រីមហាពោធិគ្មានសេចក្ដីគោរពទេ ជម្ពុស្សរជមណ្ឌលេកាលអង្គុយស្ដាប់ព្រះសទ្ធម្មទេសនាក្នុងមណ្ឌលជាទីស្ដាប់ធម៌ ក៏មិនតាំងចិត្តស្ដាប់ដែរ បលាយន្តោ ប្រៀបដូចជារត់ចេញទៅ ។

វូបសន្តចិត្តោ បន ចំណែកបុគ្គលអ្នកមានចិត្តស្ងប់រម្ងាប់កាលទៅសំពះព្រះថេរៈ, ព្រះចេតិយ ព្រះស្រីមហាពោធិ ក៏រមែងសំពះដោយគោរព , កាលស្ដាប់ព្រះសទ្ធម្មទេសនាក្នុងមណ្ឌលជាទីស្ដាប់ធម៌ក៏ស្ដាប់ដោយគោរព ។

បុគ្គលពួកមួយ មិនបានប្រព្រឹត្តស្ងប់រម្ងាប់ដោយកាយវាចាចិត្តទេ អ្នកផ្សាយមេត្តានោះ គប្បីតាំងទុកសេចក្ដីករុណាក្នុងបុគ្គលនោះថា "ឯស

ចរតិ បុគ្គលនេះគ្រាប់ទៅក្នុងមនុស្សលោកដោយប្រការនេះ រមែងប្រព្រឹត្តដូច្នេះក្នុងមនុស្ស លុះអស់ជីវិតហើយនឹងទៅកើតក្នុងឧស្សទនរក នឹងនរកធំ ៨ រណ្ដៅទៀត មិនបានយូរទេ ប្រមាណពីរថ្ងៃបីថ្ងៃ អាស្រ័យសេចក្ដីករុណានោះ ចិត្តអាឃាតព្យាបាទក៏ស្ងប់រម្ងាប់ ។

មានបុគ្គលពួកខ្លះស្ងប់រម្ងាប់ព្រមទាំងបីប្រការគឺ កាយ វាចា នឹងចិត្ត បុគ្គលផ្សាយមេត្តាទៅក្នុងអ្នកនោះនឹងធ្វើឲ្យច្រើនមិនបាន ។

កាលកុលបុត្រចំរើនមេត្តា ប៉ុន្តែ នៅតែមានចិត្តអាឃាតព្យាបាទ គប្បីឲ្យទូន្មានដល់ខ្លួនថា អត្តនោ វិសយេ ទុក្ខំ ទុក្ខរមែងកើតក្នុងវិស័យរបស់ខ្លួន បើអ្នកមិនបានធ្វើទុក្ខមកទេ បុគ្គលមានពៀរនោះធ្វើយ៉ាងណាមួយ ទុក្ខនេះមិនមែនវិស័យនៃបុគ្គលមានពៀរទេ គឺ បជហាសិ ហេតុអ្វីបានជាអ្នកមិនលះបង់ក្រោធខឹងចេញ ចិត្តក្រោធខឹងនេះធ្វើឲ្យខូចខាតប្រយោជន៍ច្រើនណាស់ ធ្វើឲ្យវិនាសយ៉ាងធំ យានិ រក្ខិតសីលានិ សីលទាំងឡាយឯណាដែលបុគ្គលរក្សា ទោសោ គឺសេចក្ដីក្រោធនេះកំចាត់បង់នូវទីតាំងនៃសីលទាំងនោះដែលបុគ្គលរក្សា គប្បីឲ្យទូន្មានដល់ខ្លួនដូច្នេះហើយនៅតែមិនបាត់បដិឃចិត្ត កម្មស្សកាតា វេធិតព្វា គប្បីពិចារណាឲ្យឃើញជាក់ច្បាស់ក្នុងចិត្តដោយភាពនៃខ្លួននឹងសត្វឯទៀតមានកម្មជារបស់ខ្លួន គប្បីពិចារណាឲ្យឃើញក្នុងកម្មស្សកតាបញ្ញាថា តស្ស កុទ្ធោ អ្នកក្រោធខឹងនឹងបុគ្គលនោះ នឹងធ្វើយ៉ាង

ណាដល់បុគ្គលនោះ អាការដែលអ្នកបានទុក្ខទោស អាស្រ័យហេតុអ្នកបានធ្វើអកុសលកម្មមិនមែនឬ ? ។

ប្រការមួយទៀត សូម្បីអ្នកបានសោយសេចក្ដីសុខ បុគ្គលដទៃប្រាកដជានឹងញុំាងអ្នកឲ្យប្រាសចាកសេចក្ដីសុខ ការនោះទឹងធ្វើយ៉ាងណា អ្នកបានសេចក្ដីសុខក៏អាស្រ័យអ្នកបានធ្វើកុសលកម្មទុកមក អ្នកដទៃដែលបានទុក្ខ អ្នកទឹងគិតធ្វើយ៉ាងណា អ្នកដទៃបានសុខនោះ ក៏អាស្រ័យតែកុសលកម្មដែលគេបានធ្វើទុកមក កម្មស្សកោម្ហិ ខ្ញុំអ្នកក្ដី បុគ្គលដទៃក្ដី កើតមកក្នុងលោកនេះមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើតនាំឲ្យកើតក្នុងសុគតិនិងទុគ្គតិ មានកម្មជាផៅពង្ស មានកម្មជាទីអាស្រ័យ ធ្វើកម្មណាទុកមក ក៏ត្រូវទទួលផលរបស់កម្មនោះ ។

សេចក្ដីក្រោធនេះ មិនអាចនាំឲ្យបាននូវសម្បត្តិ, បច្ចេកពុទ្ធសម្បត្តិ, សាវកសម្បត្តិ និងសម្បត្តិទេវតា, ព្រះឥន្ទ្រ, ព្រះព្រហ្ម, ព្រះបរមចក្រ, ស្ដេចប្រទេសរាជឡើយ ។ កាលបើអ្នកលុះទៅក្នុងអំណាចនៃទោសោ ធ្វើចិត្តឲ្យប្រទូសរាយអ្នកដទៃហើយក៏ឈ្មោះថា បាបសាចកោយកាយទោសដាក់លើខ្លួនឯង ប្រៀបដូចបុគ្គលនៅក្នុងទីក្រោមខ្យល់ ប្រាកដជានឹងបាចធូលីទៅលើអ្នកដែលនៅលើខ្យល់ ធូលីនោះត្រឡប់បកមកត្រូវខ្លួនឯងវិញមិនត្រូវខ្លួនអ្នកនៅលើខ្យល់នោះឡើយ ។ បើពិចារណាដោយកម្មស្សកតាញាណយ៉ាងនេះហើយ នៅតែមិនបាត់បង់យ-

ចិត្តគប្បីនឹករឭកដល់ព្រះគុណនៃសម្តេចព្រះបរមសាស្តាចារ្យកាលព្រះអង្គមិនទាន់បានត្រាស់ដឹង នៅជាព្រះបរមពោធិសត្វនៅឡើយ ដែលទ្រង់ប្រព្រឹត្តពីកាលមុនមកថា " សម្តេចព្រះបរមសាស្តាចារ្យកាលនៅជាព្រះពោធិសត្វ កំពុងតែស្វែងរកព្រះពោធិញាណនោះ មិនដែលមានចិត្តប្រទូសកយដល់អ្នកសម្លាប់ព្រះអង្គ, សម្លាប់ភរិយារបស់ព្រះអង្គទេ, កាលព្រះអង្គសោយព្រះជាតិជាភូរិទត្តនាគរាជ ក៏គ្មានចិត្តប្រទូសកយដល់អាលម្ពាយដែលធ្វើបាបព្រះអង្គ" ។ កាលនឹករឭកឃើញដោយន័យដូច្នេះជាដើមហើយ ក៏នឹងបាននូវមេត្តាឈាន នឹងផ្សាយមេត្តាចិត្តទៅកាន់ទិសទាំងដប់ គឺទិសធំបួន ទិសតូចបួន ទិសលើមួយ ទិសក្រោមមួយ គ្រប់ជាដប់ទិស ។ ព្រះយោគាវចរកុលបុត្រនោះ ក៏ប្រាសចាកពៀរ, ប្រាសចាកព្យាបាទ, ប្រាសចាកអាឃាត ប្រកបដោយសេចក្តីសុខគ្មានទុក្ខអ្វីឡើយ នឹងជាទីស្រឡាញ់ពេញចិត្តនៃមនុស្សទាំងឡាយ ដូចព្រះវិសាខត្ថេរ សេចក្តីថា ៖

សោ កិរ កុដុម្ពិកោ មានដំណាលថា ព្រះវិសាខត្ថេរកាលលោកនៅជាគ្រហស្ថនៅឡើយ ប្រកបដោយសម្បត្តិ មានសទ្ធាជ្រះថ្លាបរិច្ចាគសម្បត្តិអស់ហើយបួសឧបសម្បទក្នុងព្រះពុទ្ធសាសនា ចំរើនមេត្តា ជាទីស្រឡាញ់របស់មនុស្សទាំងឡាយ អ្នកទាំងនោះស្រឡាញ់ដោយសារតែលោកមានមេត្តា ។ ព្រះវិសាខត្ថេរបាននូវមេត្តានោះ, ព្រោះ

អាស្រ័យបាននូវខន្តី ។ កើតឡើងបានព្រោះអាស្រ័យនូវអទោសោ ។ ហេតុនោះ សម្តេចព្រះមានព្រះភាគទ្រង់រាប់អទោសោបញ្ចូលក្នុងមូលនៃកុសលប្រការមួយ ក្នុងបទគឺ អទោសោ កុសលមូលា ក្នុងគម្ពីរព្រះយមកដូច្នេះ ។

---

## អមោហោ

អមោហោតិ ឯត្ថ មុយ្ហន្តីតិ មោហោ, បមាទោ ឯវំ មោហោ ន មោហោ អមោហោ, សោ យស្ស សន្តានេ បវត្តោ សោ អប្បមត្តោ សតិសម្បជញ្ញោ យេវ ហោតិ ។

លំដាប់នេះ នឹងពណ៌នាក្នុងមូលនៃកុសលដែលមានក្នុងមូលយមកៈតទៅ ។ មានពាក្យព្រះអដ្ឋកថាថាវសំដែងដោយបទវិគ្រោះថា មុយ្ហន្តិ សភាវៈឯណាញ៉ាំងសត្វឲ្យវង្វេង សភាវៈនោះឯង ឈ្មោះថា មោហោ ។ នោះគឺសេចក្តីប្រមាទ, ការដែលមិនវង្វេង គឺមិនប្រមាទៈនោះ សូម្បីអ្នកប្រាជ្ញទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម ត្រាស់ហៅថា អមោហោ ។ នោះសម្តេចព្រះមានព្រះភាគទ្រង់ត្រាស់ចាត់ចូលក្នុងមូលនៃកុសលក្នុងមូលយមកនេះ ។

(នៅមានត)

## មធុរសវាហិណី

# សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ.ឈឺន ពិនិត្យ

( តមក )

## ព្យគ្ឃវត្ថុគាថា

សំដែងរឿងនិទានខ្លាធំជាលំដាប់តទៅទៀត ដោយបទបាលីថា:

ជម្ពុទីបេ បុណ្ឌ្រវទ្ធាសន្នេ ដូច្នេះជាដើម,

អធិប្បាយថា : ក្នុងជម្ពូទ្វីប ( ឥណ្ឌា ) មានផ្លូវធំមួយកាត់សំដៅទៅកាន់ភ្នំឈ្មោះបំសុបពិតជិតស្រុកឈ្មោះបុណ្ឌ្រវទ្ធនាក្រុងពារាណសីនោះៗ

ក្នុងទីពាក់កណ្ដាលផ្លូវនោះ មានខ្លាធំមួយឥតមានមេ មានតែបាចាស់ជរាខ្វាក់ភ្នែក ខ្លានោះបានយកបារបស់ខ្លួនទៅទុកឲ្យនៅក្នុងគុហាក្បែរភ្នំ ហើយស្វែងរកអាហារឲ្យបរិភោគ តែងចិញ្ចឹមថែរក្សាអស់កាលជានិច្ចទៅទីនោះ ៗ ឯទ្វារព្រៃភ្នំនោះសោតមានដើមឈើមួយដើម មានសេកមួយឈ្មោះតុណ្ឌិលនៅអាស្រ័យលើដើមឈើនោះ, ឯសត្វទាំងពីរគឺខ្លានិងសេក, ជាមិត្តសំឡាញ់ពេញចិត្តនិងគ្នាទៅវិញទៅមកយ៉ាងមាំឥតមានបែកចិត្តគំនិតគ្នានិងគ្នាឡើយ ៗ

សម័យមួយ មានមនុស្សអ្នកនៅក្នុងបច្ចន្តគ្រាមម្នាក់ កើតជម្លោះឈ្លោះប្រកែកតាស់ទែងគ្នានិងភរិយារបស់ខ្លួន ហើយលែងលះភរិយា

ទោល ដើរចេញទៅកាន់ទីក្រុងពារាណសី ក៏បានទៅដល់ទ្វារព្រៃនោះឯង ។

កាលនោះ សត្វសេកបានឃើញបុរសនោះ មានអត្តភាពដ៏ថោកថយ ដល់នូវសេចក្ដីទុក្ខលំបាកដើរមកដូច្នោះ ក៏មានចិត្តអាណិតញាប់ញ័រដោយសេចក្ដីករុណាពន់ពេកហើយស្រែកហៅបុរសនោះ ឲ្យដើរចូលមកកាន់សំណាក់នៃខ្លួនហើយសួរថា ម្នាលអ្នកដ៏ចំរើន! អ្នកដើរត្រាច់ទៅទីណា? មកពីណា? នេះ ។

បុរសនោះ បានស្ដាប់ហើយ ពោលតបថា យើងទៅកាន់ដងព្រៃខាងមុខនេះឯង ។ ឯតុណ្ឌិលសេកក៏និយាយប្រាប់ថា ម្នាលអ្នកដ៏ចំរើន ក្នុងដងព្រៃឯនោះ មានខ្លាធំមួយរឹងរឹងរូសកាចអាក្រក់ណាស់ វាមែងចាប់មនុស្សនឹងសត្វទាំងឡាយទំពាស៊ីជាអាហាររស់កាលជានិច្ច ៗ ដូច្នេះត្រូវអ្នកកុំដើរទៅកាន់ទីនោះឡើយ ។

ឯបុរសជាមនុស្សប្រែដៅក្រ មានសន្ដានចិត្តជាអកតញ្ញូនោះ ពុំបានអើពើស្ដាប់បង្គាប់ពាក្យសេក ដែលជាអ្នកប្រាថ្នាប្រយោជន៍ដល់ខ្លួននោះទេ ត្រឡប់ជាពោលពាក្យទ្រគោះតបវិញថា អញចេះតែទៅ អញមិនខ្លាចអ្វីឡើយ ។

តុណ្ឌិលសេកអ្នកមានសន្ដានចិត្តល្អជាសប្បុរស លុះបានស្ដាប់ពាក្យគំរោះគំរើយដូច្នោះហើយ ក៏ពុំលះបង់ធម៌សប្បុរសរបស់ខ្លួនឡើយ បាន

ពោលសាំតបទៅនឹងបុរសនោះទៀតថា: ម្នាលសំឡាញ់មានធុរៈស្មើ ! បើអ្នកពុំបានត្រឡប់វិញទេ បើតែទៅដូច្នោះនោះ ខ្ញុំមានខ្លាធំមួយជាសំឡាញ់នៅអាស្រ័យក្នុងទីនោះ, រីឯខ្លាធំនោះបើប្រសិនបានស្តាប់ពតិមាននៃខ្ញុំអំពីសំណាក់អ្នកហើយ មុខជាមិនអាចនឹងបៀតបៀនខាំពាំនាំអ្នកយកទៅធ្វើជាអាហារឡើយ ។

បុរសអកតញ្ញូនោះ ក៏ពុំបានអើពើកាន់យកពាក្យនោះទៀត ត្រឡប់ប្រែជាមានចិត្តប្រទុស្តតបដល់សេកនោះវិញ មិនត្រឹមតែប៉ុណ្ណោះ ក៏យកដំបងប្រហារពយសម្លាប់កុណ្ឌលសេកនោះឲ្យក្សីណក្ស័យទៅ ហើយបង្កាត់ភ្លើងដុតអាំងសេកនោះ លុះឆ្អិនហើយក៏ទំពាស៊ីអស់ទៅ ។

ការបំភ្លឺសេចក្តីថា កិរិយាដែលនៅប្រឡូកប្រឡល់ជាមួយបុគ្គលអសប្បុរសដូច្នេះនេះ ជាហេតុនាំមកនូវសេចក្តីទុក្ខលំបាកក្នុងលោកនេះនឹងលោកខាងមុខដោយចំណែកមួយពិត ។ ព្រោះហេតុដូច្នោះ បានជាព្រះគន្ថរចនាចារ្យ លោកពោលជាបទព្រះគាថាទាំងឡាយដូចមានសេចក្តីថា :

នរជនជាអសប្បុរស ទោះបីសំឡាញ់របស់ខ្លួន ប្រកាសសំដែងប្រាប់ប្រយោជន៍ល្អ, ធ្វើឧបការគុណដល់ខ្លួនក្តី ទោះបីសំឡាញ់ពោលបំភ្លឺសេចក្តីពិសេសជាងនេះក្តី ក៏គង់ក្លែងបញ្ឆោតសំឡាប់ ហើយដុតនូវសរីរៈសំឡាញ់ខ្លួននោះ ចំអិនឲ្យឆ្អិនធ្វើជាអាហារបរិភោគជាមួយនឹង

វត្តមានទឹកឃ្មុំ នឹងទឹកដោះគោជាដើម ជាអំពើពុំប្រពៃវិញ ។

ឯនរជនជាអសប្បុរសនោះតែងខឹង ហើយប្រទុស្តដល់មិត្តវិញ បីដូចជាសត្វអសិរពិសតែខឹងហើយ តែងចិកខាំនូវសរីរៈនៃបុគ្គលអ្នកចិញ្ចឹមនោះវិញដូច្នោះឯង ។ កិរិយាដែលសេពគប់សូម្បីតែមួយរំពេច ជាមួយនរជនកាចអាក្រក់ជាអ្នកសាត់ព្រាត់ មានបាបលាមកថោកទាបជាមនុស្សអកតញ្ញូយ៉ាងនេះ បុគ្គលមិនគប្បីសេពគប់យកជាមិត្តឡើយ ។ ម្យ៉ាងទៀត បុគ្គលជាអសប្បុរសតែងមានសេចក្តីក្រោធខឹងជាប់ជានិច្ច ព្រមទាំងធ្វើនូវសេចក្តីវិនាសដល់មិត្តវិញដោយពិត ។

លុះជនជាអសប្បុរស៍បានទំពាស៊ីសាច់សេកនោះរួចហើយ ក៏ដើរសំដៅទៅកាន់ដងព្រៃ កាលបានដល់កណ្តាលដងព្រៃនោះហើយ, ស្រាប់តែខ្លាធំបានឃើញមួយរំពេច ក៏ធ្វើនូវសំឡេងគ្រហឹមឲ្យលាន់ឮខ្ទាំង ស្ទុះលោតចូលមកប្រជិតនឹងចាប់ខាំបុរសនោះក្នុងកាលនោះឯង ។ បុរសអកតញ្ញូនោះ បានឃើញខ្លាធំស្ទុះលោតចូលមកប្រជិតនឹងខាំខ្លួនហើយ ក៏ដល់នូវសេចក្តីភ័យតក់ស្លុតពន់ពេក ទើបនឹករលឹកដល់ពាក្យបណ្តាំរបស់សេកឈ្មោះគុណ្ឌិលនោះ ហើយពោលអង្វរចំពោះខ្លាធំថា: បពិត្រអ្នកម្ចាស់ដ៏ចំរើនអើយ ! ខ្ញុំនេះបាននាំពតិមានមកអំពីសំណាក់នៃគុណ្ឌិលសេកជាសំឡាញ់របស់អ្នកដែលនៅឯនាយនោះ ។

ឯសត្វខ្លាធំ លុះបានស្តាប់ពាក្យថាគុណ្ឌិលសេកផ្តាំមកដូច្នោះហើយ

ក៏មានចិត្តត្រេកអរក៏កាយហៅបុរសនោះចូលមកថា ម្នាលសំឡាញ់មានធុរៈស៊េចូរអ្នកមកចុះ ហើយនាំបុរសនោះចូលនៅកាន់ទីលំនៅរបស់ខ្លួន បានឲ្យអាហារចំណីដែលគួរបរិភោគដល់បុរសនោះ ឲ្យបរិភោគដរាបដល់ឆ្អែតស្រេចហើយ ឲ្យអង្គុយនៅក្នុងសំណាក់នៃខ្លាចាស់ជាបារបស់ខ្លួន ហើយចេញទៅកាន់ដងព្រៃទៀត ដើម្បីស្វែងរកអាហារដោយរហ័ស ។

កាលនោះ ខ្លាចាស់ជាបារបស់ខ្លាធំនោះ, កាលបើខ្លាធំជាកូនរបស់ខ្លួនបានចេញទៅស្វែងរកចំណីហើយ, ក៏និយាយចរចាជាមួយនឹងបុរសនោះ ដោយសេចក្តីស្និទ្ធស្នាលស្មោះត្រង់ ហើយបានស្តាប់សម្តីសព្វពាក្យបុរសនោះ ក៏បានដឹងច្បាស់ថា បុរសនេះសំឡាប់សេកឈ្មោះគុណ្ឌិលបំពិនធ្វើជាអាហារបរិភោគរួចហើយ ដោយរលឹកតាមពាក្យបុរសអកតញ្ញូនោះឯង ។

បន្ទាប់ពីនោះ ខ្លាធំត្រឡប់មកពីរកចំណីវិញ ខ្លាចាស់ជាបាបាននិយាយប្រាប់កូនថា ម្នាលកូនដ៏ពុកអើយ ! គុណ្ឌិលជាសំឡាញ់របស់អ្នកគឺបុរសនេះក៏សំឡាប់ទៅហើយ ។

ឯខ្លាធំជាកូនបានស្តាប់ពាក្យនៃបាប្រាប់ដូច្នោះហើយ ក៏មានចិត្តអាក់អន់ញាប់ញ័រខ្លួន នឹកអាណិតអាសូរដល់សំឡាញ់ខ្លួនពន់ពេក ក៏ស្ទុះចេញទៅកាន់ទីលំនៅនៃគុណ្ឌិលសេកជាសំឡាញ់ ដោយរហ័សរួសរាន

កន់ហើយស្រែកហៅថា ម្នាលគុណពិលសំឡាញ់អើយ! សំឡាញ់ទៅណាទៅ? កាលបើស្រែកហៅពីរបីមាត់ពុំបានឮពាក្យឆ្លើយតបមកសោះ ក៏ដើរស្វែងរកគយគន់មើល បានឃើញស្លាបដែលបុរសនោះកាច់បោះចោលក្នុងទីនោះ ទើបចូលចិត្តដឹងច្បាស់ឥតមានសង្ស័យថា សំឡាញ់របស់អាត្មាអញត្រូវបុរសនេះកាប់សម្លាប់ដោយពិត, ហើយសោយសោកទ្រហោយំខ្សឹកខ្សួលបំរះនទៀល លុះក្រោកឡើងក៏រត់ត្រឡប់មកកាន់ទីលំនៅរបស់ខ្លួនវិញ ។

ចំណែកជនជាអសប្បុរស កាលបើខ្លាធំនោះបានចេញចាកពីទីនោះទៅហើយ ក៏លើកផែនថ្មយ៉ាងធំគប់ក្បាលខ្លាចាស់ប្រហារឲ្យក្សណក្ស័យទៅ ហើយគិតថា អញនឹងសម្លាប់ខ្លាធំនោះទៀតក្នុងពេលលំដាប់គ្នានេះឯង ។ ជនអសប្បុរសក៏នៅរង់ចាំមើលផ្លូវខ្លាធំនោះត្រឡប់មកវិញ, បានលាក់ខ្លួនពួននៅក្នុងទីកំបាំងមួយ ។

ខណៈនោះ ខ្លាធំក៏បានត្រឡប់មកដល់វិញក្នុងកាលនោះដែរ ។ ឯមនុស្សបាប លុះបានឃើញខ្លាធំមកដល់ហើយ ក៏ភិតភ័យតក់ស្លុតខ្លួនដោយតេជៈអំណាចនៃខ្លា បែរជាស្ទុះរត់ទៅក្រាបសំពះលូនដោយទ្រូងទៀបបាទដើងនៃខ្លាធំហើយពោលថាៈ បពិត្រអ្នកជាម្ចាស់សូមអ្នកមេត្តាឲ្យជីវិតដល់ខ្ញុំផង ។

ចំណែកឯខ្លាធំក៏បានញ៉ាំងសេចក្ដីក្រោធខឹងឲ្យរម្ងាប់រលត់ទៅ ក្នុង

អំពើដែលបុរសបាបនោះបានធ្វើហើយ ពុំបានចងគំនុំគុំគួនឡើយ ដោយពិចារណាយល់ថា: អំពើដែលអាត្មាអញប្រុងនឹងប្រទុស្តដល់បុរសដែលបាននាំពាក្យបណ្តាំរបស់សម្លាញ់មកឲ្យនេះពុំគួរសោះឡើយ, លុះខ្លាធំគិតដូច្នេះហើយ ក៏រសាយនូវសេចក្តីក្រោធខឹងចេញមួយរំពេច ត្រឡប់ជាមានចិត្តករុណាលួងលោមបុរសបាបលាមកនោះ ពុំឲ្យមានសេចក្តីភិតភ័យអ្វីឡើយ ហើយបញ្ជូនឲ្យទៅដោយស្រួលថា: ម្នាលសំឡាញ់មានធុរៈស្រេច ត្រូវអ្នកដើរចេញទៅដោយសុខសប្បាយចុះ ។

អំពើដែលបុគ្គលបានសេពគប់នឹងជនជាសប្បុរស រមែងនាំមកនូវសេចក្តីសុខសប្បាយយ៉ាងនេះឯង ។

ព្រោះហេតុដូច្នោះ បានជាមានពុទ្ធភាសិតសំដែងដូច្នេះថា :

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សណ្ឋវំ
សព្ទត្ថ សណ្ឋារេ សព្ភិ សេយ្យោ ហោតិ ន បាបិយោ
សុខាវហោ ទុក្ខានុទោ សទា សព្ភិ សមាគមោ
តស្មា សប្បុរិសេហេវ សង្គមោ ហោតុ ជន្តុនំ ។

អធិប្បាយថា: បុគ្គលត្រូវតែសេពគប់ជាមួយនឹងជនជាសប្បុរសទាំងឡាយដោយពិត, បុគ្គលត្រូវតែធ្វើនូវមិត្តសណ្ឋារៈរាប់អានរួមរមជាមួយនឹងជនជាសប្បុរសទាំងឡាយ មិត្តសណ្ឋារៈដែលបុគ្គលប្រព្រឹត្តស្និទ្ធស្នាលយកជាមិត្តមួយអន្លើដោយជនជាសប្បុរសទាំងឡាយហើយ តែងបានល្អ

ប្រសើរដោយវិសេស ពុំបានលាមកអាក្រក់ក្នុងទីទាំងឡាយទាំងពួង, អំពើដែលបុគ្គលសេពគប់ជាមួយនឹងជនជាសប្បុរសសព្វ ៗ កាលនេះ អាចបន្ទោបង់នូវសេចក្តីទុក្ខលំបាកបាន ហើយអាចប្រមូលនាំមកនូវសេចក្តីសុខក្សេមក្សាន្តដោយបំណែកមួយ, ព្រោះហេតុដូច្នោះ នរជនទាំងឡាយត្រូវសេពគប់ជាមួយនឹងជនជាសប្បុរសដោយពិត ៗ លុះដល់មកក្នុងកាលជាខាងក្រោយ ខ្ញុំក៏បានធ្វើមរណកាលក្សិណក្ស័យជីវិតទៅ, ដោយអានុភាពផលានិសង្សនៃសេចក្តីករុណាគុណនោះ ក៏បានឡើងទៅកើតក្នុងស្ថានសួគ៌ទេវលោកនាយ សោយទិព្វសម្បត្តិទាំង ១០ ប្រការ ជាសុខសួស្តីនៅក្នុងប្រាសាទកែវទាំង ៧ ប្រការ សឹងបរិបូណ៌ទៅដោយស្រីទេពអប្សរជាច្រើនចោមរោមជាបរិវារក្នុងកាលនោះឯង ៗ

ព្រោះហេតុដូច្នោះ ព្រះអរហន្តទាំងឡាយ លោកពោលជាបទព្រះគាថាដូច្នេះថា :

ឯវំ វិជានិ ជនុសោ បរមំ សហាយំ
ព្យគ្ឃា ធយាយុបកតោ សុគតី សុមេធោ
តស្មា ករោថ ករុណំ សុគតំ ជនានំ
តំ វោ ធនាតិ វិករញ្ញុ កវេសុ គោតិ ៗ

អធិប្បាយថា: សូម្បីខ្ញុំកាចអាក្រក់មានប្រការយ៉ាងនេះ តែងទាំពាំនាំមកនូវសាច់នៃសត្វដទៃជាប្រក្រតី តែថាជាសត្វមានប្រាជ្ញល្អអាច

ត្រឡប់ចិត្តទៅកាន់សេចក្តីករុណាធម៌វិញ, ហើយបានរួចចាកអបាយភូមិបានទៅកាន់សុគតិវិញ ព្រោះហេតុដូច្នោះ អ្នកទាំងឡាយត្រូវធ្វើនូវសេចក្តីករុណា តាមគន្លងនៃជនទាំងឡាយដែលជាសប្បុរសល្អចុះ, អំពើដែលប្រកបដោយករុណាធម៌នោះ នឹងមានអានិសង្សច្រើនអាចឲ្យនូវភោគសម្បត្តិក្នុងភពជាន់ទាបជាន់ខ្ពស់ទាំងឡាយផង អាចឲ្យនូវសម្បត្តិព្រះនិព្វានឥតមានភពដទៃប្រសើរជាងផង ដល់អ្នកទាំងឡាយដោយពិត ។

សំដែងរឿងនិទានសត្វខ្លាធំជាគំរប់ ៥ ក្នុងវគ្គទីពីរគឺចប់សេចក្តីជាសង្ខេបតែប៉ុណ្ណោះឯង ។

(នៅមានត)

# លោក អ៊ុម-ភគ បម្លងពីសាស្ត្រស្លឹករឹត

*ព្រះពុទ្ធវង្ស គិម-តូវ ពិនិត្យ*

(តមក)

---

អសំវិហិតកម្មន្តំ ពាលំ ឧម្មន្តិ មន្តិនំ
សិរី ជហាតិ ទុម្មេធំ ជិណ្ណំវ ឧរគោ តចំ
ឯតម្បិ ទិស្វាន អហំ វទាមិ បញ្ញោវ
សេយ្យោ ន យសស្សី ពាលោតិ ។

បពិត្រព្រះមហារាជអើយ ! សូម្បីសិរីសម្បត្តិ ក៏សឹងតែលះបង់នូវអ្នកខ្លៅអប្បឥតប្រាជ្ញា ឥតជំរិះ បើរិះគិតធ្វើការ ឧបមាដូចពស់វែកលះបង់ចោលនូវសំណកចាស់នោះហោង; ហេតុនោះខ្ញុំយល់ថា អ្នកមានប្រាជ្ញានោះទើបប្រសើរ, ឯអ្នកកំឡៅគ្រាន់តែមានយសបរិវារនោះពុំប្រសើរឡើយ ។

លំដាប់នោះ; ស្តេចទ្រង់ព្រះសណ្តាប់ហើយ មានព្រះបន្ទូលទៅនឹងអាចារ្យសេនកៈថា ដូចម្តេចទៅ ? អាចារ្យសេនកៈគិតហើយទូលថា ធេ៎ បពិត្រមហារាជអើយ ! រីមហោសថនេះជាក្មេងតូចក្តាត់គាត់ដឹងអ្វី, ខ្ញុំនឹងធ្វើមិនឲ្យមហោសថឆ្លើយតបបានឡើយ , សូមទានអញ្ជើញស្តេចស្តាប់ខ្ញុំ , ទើបអាចារ្យសេនកៈសូត្រនូវគាថានេះថា :

បញ្ច បណ្ឌិតា មយំ ភទ្ទន្តេ
សព្វេ បញ្ជលិកា ឧបដ្ឋិតា តេ
ត្វំ នោ អភិភុយ្យ ឥស្សរោសិ
សក្កោវ ភូតបតិ ទេវរាជា
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោ វិហីនោ សិរិមាវ សេយ្យោតិ ។

បពិត្រមហារាជមានសិរីសួស្តីប្រសើរអើយ ! រីយើងខ្ញុំផងទាំងឡាយជាអ្នកប្រាជ្ញទាំង ៥ នេះ សឹងបំរើធ្វើនមស្ការក្រាបថ្វាយបង្គំប្រណម្យព្រះអង្គជាអម្ចាស់នៃយើងខ្ញុំផងទាំងឡាយ ដូចព្រះឥន្ទ្រាធិរាជមានអំណាចអ៊ីក៏មកនៅជាខ្ញុំបំរើអម្ចាស់នេះ តើដូច្នេះយល់ថាមហោសថមានប្រាជ្ញប្រសើរ ឬអម្ចាស់មានសម្បត្តិជាឥស្សរនោះប្រសើរ, ខ្ញុំយល់ហេតុនោះហើយខ្ញុំថា អ្នកមានសម្បត្តិនោះប្រសើរ, ឯអ្នកមានតែប្រាជ្ញាថយលែងសម្បត្តិនោះពុំប្រសើរឡើយ ។

ហៃសប្បុរសផងទាំងឡាយអើយ! រីអាចារ្យសេនកៈនាំហេតុមកស្រដីដូច្នេះ បើវៀរលែងពោធិសត្វហើយ, ឯអ្នកដទៃទោះបីនឹងអាចឆ្លើយក់ទះទំលាយនូវពាក្យនោះបានឥតអង្គមានឡើយ; ស្តេចទ្រង់ព្រះសណ្តាប់ពាក្យអាចារ្យសេនក.ទូលនូវប្រការអម្បាលនោះហើយ ទ្រង់ព្រះចិន្តាថា អាចារ្យសេនកៈនាំនូវហេតុនេះ មកសំដែងដូច្នេះយល់ជាការគាប់ពិត ប៉ុន្តែគំនិត

មហោសថនឹងនាំនូវហេតុដទៃ មកស្រដីចំលាយតបនូវពាក្យនោះបាន ទើបស្តេចមានព្រះបន្ទូលទៅកាន់ពោធិសត្វថា បណ្ឌិត ហៃអ្នកប្រាជ្ញអើយ! បានឹងឆ្លើយដូចម្តេចវិញ? ពោធិសត្វស្តាប់ហើយ ក៏ឆ្លើយដោះចំ-លាយនូវពាក្យនោះបានដោយនូវអាថ៌កំបាំងដំណើងគាថា ទូលព្រះមហា-ក្សត្រថា បពិត្រមហារាជអើយ! អាចារ្យសេនកៈនោះទីងដឹងអ្វី គាត់រមិលមើលយល់តែយសឯង មិនទាន់ដឹងនូវប្រាជ្ញាវិសេសនៃខ្ញុំឡើយ, មហារាជអើយ! សូមទ្រង់ព្រះសណ្តាប់ខ្ញុំនឹងឆ្លើយថ្វាយឲ្យប្រាកដ, ទើបពោធិសត្វសូត្រជាបទគាថា ដូច្នេះថា :

ធាវេសោ បញ្ញស្ស យសស្សី ពាលោ
អត្ថេសុ ជាតេសុ តថាវិធេសុ
យំ បណ្ឌិតោ និបុណំ សំវិធេតិ
សម្មោហមាបជ្ជតិ តត្ថ ពាលោ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោវ សេយ្យោ ន យសស្សី ពាលោតិ ។

បពិត្រព្រះសម្មតិទេពមហារាជក្សត្រថ្លៃប្រសើរអើយ! អាចិសេចក្តីកើតមានដោយដំណូកដូច្នោះ ពោះអ្នកដ៏មានយសសម្បត្តិច្រើនប៉ុន្មានក្តី បើខ្លៅហើយ សឹងទៅបំរើធ្វើដូចខ្ញុំនៃអ្នកដ៏មានប្រាជ្ញានោះហោង; អ្នកមានប្រាជ្ញា កាលណាបើត្រិះរិះរកដណ្តាប់នូវកិច្ចការសេចក្តីឯណា សឹង

មានអាថិលាក់លៀមកំបាំងជ្រៅក្រៃ កម្រអ្នកដទៃនឹងអាចដឹងបានឡើយ ខ្ញុំយល់នូវហេតុនោះហើយ បានជាខ្ញុំសរសើរអ្នកមានប្រាជ្ញា, រីពាក្យអាចារ្យសេនកៈថា អ្នកមានសម្បត្តិប្រសើរ ហេតុអ្វីកាលអម្ចាស់ឲ្យគេអាថិប្រស្នាក្តែនឹងពពៃនោះ ក៏គាត់មិនយកសម្បត្តិនោះទៅដោះសាប្រស្នា គាត់ធ្វើអាត្មានោះដូចជាខ្ញុំគេ ទៅសុំរៀនអាថិប្រស្នាអំពីខ្ញុំ ហើយនាំអាថិប្រស្នានោះមកឆ្លើយថ្វាយព្រះអង្គ ? ទើបគាត់បានគង់ខ្លួននៅទាំងម្ល៉េះ ដូច្នេះយល់ថាអ្នកមានប្រាជ្ញាប្រសើរ ឬអ្នកកំឡៅមានសម្បត្តិប្រសើរ ? ។

ព្រះពោធិសត្វសំដែងហេតុនោះ ទូលព្រះមហាក្សត្រដោយនូវអានុភាពប្រាជ្ញា ឧបមាដូចអ្នកយកខ្សាច់មាសអំពីជើងភ្នំព្រះសុមេរុ លើកឡើង-យល់ជាប្រាកដ ពុំនោះសោតដូចព្រះចន្ទពេញបូណ៌មី យល់ច្បាស់ឮដឹកណ្ដាលពពួកផ្កាយនោះហោង ។ ស្ដេចទ្រង់ព្រះសណ្ដាប់ពាក្យពោធិសត្វទូលដូច្នោះហើយ មានព្រះបន្ទូលទៅនឹងអាចារ្យសេនកៈថា ម្ដេចទៅអាចារ្យ ចូរសំដែងមកវិញទៀតហោង ។ អាចារ្យសេនកៈស្ដាប់ហើយពុំអាចនឹងឆ្លើយតបបានឡើយ ដូចគេមានស្រូវទុកក្នុងឃ្លាំងពេញហើយគេយកចេញខាតអស់ អង្គុយស្ងៀមទ្រមឹងឥតបើនឹងស្រដីតបទៅវិញទៀតបានឡើយ ។ បពិត្រអើយ ! អាចារ្យសេនកៈនោះ ទោះបីអាចនាំហេតុដទៃមកសំដែងនូវគាថាដល់មួយពាន់ក្តី ក៏ពោធិសត្វកើតជាមហោសថនេះ ស្ដេចនឹងសម្រេចផ្ចាញ់គេដោយនូវព្រះប្រាជ្ញាវិសេសហោង ។

ព្រះពោធិសត្វសោតសរសើរនូវព្រះប្រាជ្ញាវិញទៀត ទើបសូត្រជាគាថាដូច្នេះថា :

អទ្ធាបិ បញ្ញាវ សតំ បសដ្ឋា
កន្តា សិរី ភោគរតា មនុស្សា
ញាណញ្ច ពុទ្ធានមតុល្យរូបំ
បញ្ញំ នាច្ចេតិ សិរិមា កទាចិ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោវ សេយ្យោ ន យសស្សី ពាលោតិ ។

បពិត្រមហារាជអើយ ! អ្នកប្រាជ្ញានោះ គឺសប្បុរសទាំងឡាយមានព្រះពុទ្ធជាដើម សឹងសរសើរអ្នកនោះ, មនុស្សផងជាអ្នកកំឡៅ មានតែស័ក្តិយសរបស់ច្រើន ហើយវង្វេងស្រឡាញ់ភោគសម្បត្តិនោះ សឹងជាដំនៀលនៃអ្នកប្រាជ្ញផង ពុំដែលកន្លងអ្នកមានប្រាជ្ញានោះបានឡើយ; ខ្ញុំព្រះអង្គឃើញនូវហេតុនោះហើយ បានជាពោលថា អ្នកមានប្រាជ្ញានោះប្រសើរ, ឯអ្នកអន្ធពាល មានតែយសបរិវារនោះពុំប្រសើរឡើយ ។

ស្តេចទ្រង់ព្រះសណ្តាប់ពាក្យពោធិសត្វទូលនូវប្រការអម្បាលនោះ ហើយ មានព្រះទ័យនោះទ្រង់ព្រះអំណរអរនឹងចម្លើយប្រស្នា ស្តេចក៏បូជាព្រះមហាសត្វនូវទ្រព្យរតនាករ ដូចភ្លៀងបង្អុរចុះដ៏ក្រាស់ហើយ សូត្រជាគាថាដូច្នេះថា :

យន្តំ អបុច្ឆិម្ហា អកិត្តយីនោ
មហោសធំ កេវលធម្មទស្សី
គវំ សហស្សំ ឧសភញ្ច នាគំ
អាជញ្ញយុត្តេ ច រថេ ទស ឥមេ
បញ្ហស្ស វេយ្យាករណេន តុដ្ឋោ
ទទាមិ តេ គាមវរានិ សោឡស ។

មហោសធ ម្នាលមហោសធអើយ ! បាមានប្រាជ្ញាយល់អាថ៌ធម៌ទាំងពួងជាក់ច្បាស់ប្រាកដពេក, ឯយើងទាំងឡាយនេះ នឹងត្រិះរិះគិតនូវអាថ៌ប្រស្នាឯណាដូចចៅនោះពុំបានឡើយ, អញអរនឹងបាឆ្លើយដោះស្រាយអាថ៌ប្រស្នា អញនឹងបូជាចៅនូវគោនោះមួយពាន់ សឹងឧសភពងប្រសើរ, នូវបាដំរី នូវរទេះទឹមដោយសេះអាជានេយ្យនោះដប់, នូវស្រុកប្រសើរនោះដប់ប្រាំមួយ, អញបូជាបាហោង ៗ ស្តេចមានព្រះបន្ទូលអម្បាលនោះហើយ ស្តេចឲ្យអស់ទ្រព្យ នូវស្រុកទាំងនោះមកពោធិសត្វហោង ៗ

វីសតិនិបាតេ សិរិមេណ្ឌកបញ្ហោ និដ្ឋិតោ ។ រឿងស្រដីសិរីមេណ្ឌកបញ្ហា ប្រស្នាមានក្នុងវីសតិនិបាតមិញ ក៏ចប់នូវប្រការអម្បាលនេះឯងហោង ៗ

---

តតោ បដ្ឋាយ ពោធិសត្តស្ស យសោ មហា អហោសិ ។ តំ សព្វំ បញ្ញាយ ឧទុម្ពរទេវី យេវ វិចារេសិ ។

វិនាងឧទុម្ពរទេវីពិចារណាគិតថា ចៅមហាសេដ្ឋ បានអាយុ ១៦ ឆ្នាំ ហើយ, វិឃេសសម្បត្តិចៅមហាសេដ្ឋប្អូនអញមានច្រើន គួរអញនឹងរកប្រពន្ធឲ្យចៅមហាសេដ្ឋ, នាងគិតនូវប្រការអម្បាលនោះហើយនាងទៅទូលព្រះបាទវិទេហរាជ ដោយនូវប្រស្នានោះ ហើយក៏ស្ដេចអនុញ្ញាតឲ្យថា ករេធ្វ ម្នាលនាងឧទុម្ពរទេវីជាអគ្គមហេសីសំឡាញ់អើយ! ចូរនាងរកចុះ, វិនាងឧទុម្ពរនាងដឹងជាស្ដេចអនុញ្ញាតឲ្យហើយ នាងទទួលយកព្រះបន្ទូលដោយនូវហេតុនោះ ហើយនាងលាព្រះមហាក្សត្រវិលមកហើយនាងថា ហៃចៅមហាសេដ្ឋអើយ! អញចង់រកក្មេងស្រីមួយមកឲ្យជាភរិយាបំរើបាហេង ៗ ពោធិសត្វឮហើយគិតថាបើព្រះនាងនឹងរកក្មេងស្រីនោះមកឲ្យជាភរិយាអញ មានកាលគាប់ចិត្តអញ មានកាលពុំគាប់ចិត្តអញ គួរអញទៅស្វែងរកដោយខ្លួនឯងវិញ គិតដូច្នោះហើយឆ្លើយថា បពិត្រព្រះនាងឧទុម្ពរបវរល័ក្ខណ៍អគ្គមហេសីទេពីក្សត្រថ្លៃជាអម្ចាស់ប្អូនអើយ! ប្អូននឹងទៅស្វែងរកដោយខ្លួនឯង, ប្អូននឹងលាអ្នកទៅបានពីរបីថ្ងៃ កុំអម្ចាស់មានព្រះបន្ទូលនឹងព្រះមហាក្សត្រឲ្យជ្រាបឡើយ, បើខ្ញុំទៅរកបានពេញចិត្តខ្ញុំហើយ ខ្ញុំនឹងនាំមកហោងកុំឲ្យព្រួយចិត្តអ្នកជាបងរកឲ្យខ្ញុំឡើយ ៗ វិនាងឧទុម្ពរទេវី នាងស្ដាប់ពាក្យចៅមហាសេដ្ឋដូច្នោះហើយ នាងមានព្រះបន្ទូលថា ហៃបាមហាសេដ្ឋអើយ! ចូរបាទៅរកចុះ ៗ ពោធិសត្វក៏ក្រាបលានាងឧទុម្ពរទៅផ្ទះអាត្មា

ប្រាប់អស់ពួកបរិវារទាំងឡាយឲ្យរៀបប្រដាប់ប្រដាអាត្មា ហើយគៀស ខ្លួនមិនឲ្យអ្នកដទៃស្គាល់បាន ហើយយកនីទៅនូវអស់ប្រការប៉ាក់ជុលនឹង បង្កើតឧបករណ៍នោះហោង, ចៅមហោសថ ក៏ដើរសីហនាទគតាតចេញ ទៅនាទ្វារឯជើងតែម្នាក់ឯងចូលទៅនាស្រុកឧត្តរយវមជ្ឈគ្រាមនោះហោង ។

តទា បន តត្ថ ឯកំ បុរាណសេដ្ឋិកុលំ បរិជិណ្ណំ អហោសិ ។ បពិត្រអើយ! ក្នុងកាលនោះ មាន ត្រកូលសេដ្ឋីចាស់មួយនៅនាស្រុកឧត្តរយវមជ្ឈគ្រាមនោះ ក៏ថយសម្បត្តិជាអ្នកខ្សត់វិញហោង ។ ត្រកូលសេដ្ឋីនោះ មានកូនក្រមុំមួយឈ្មោះ អមរាទេវី ។ នាងនោះមានប្រាជ្ញាប្រកបនូវលក្ខណទាំងពួង ឥតអ្នកឯណានឹងប្រាថ្នាយកជាភរិយាបានឡើយ ជាស្ត្រីមានបុណ្យច្រើន ។ មានកាលថ្ងៃមួយ, នាងក៏ក្រោកឡើងអំពីព្រឹក នាងចំអិនយាគូនឹងយក ទៅជូនឪពុកនាបានស្រែនាយនោះ នាងដើរចេញអំពីផ្ទះទៅដោយផ្លូវ នោះហោង ។ ក្នុងកាលនោះ, ព្រះមហោសថអ្នកប្រាជ្ញ អាចពិត ពិលរមិលមើលទៅយល់នូវនាងអមរាលីលាដើរមកអំពីចម្ងាយ ប្រកបនូវ លក្ខណទាំងក្នុងផ្លូវនោះហើយ ក៏ត្រិះរិះក្នុងព្រះហឫទ័យថា នេះស្រីមាន លក្ខណ, ស្រីនេះ បើខ្ញុំបានមានប្ដីគួរអញយកជាភរិយាឲ្យបំរើ ប្រចាំជើងដៃអញហោង ។ សាបិ តំ ទិស្វា ។ នាងអមរា ទេវីលីលាដើរទៅដោយផ្លូវ ពិតពិលរមិលមើលទៅយល់ចៅមហោសថ

កំពុងដើរលើលាដោយនូវផ្លូវចំពោះមុខដូច្នោះហើយ នាងគិតជញ្ជឹងរំពឹងក្នុងចិត្តថា បុរសនោះមានសុភាពបង្គួរដូច្នោះ ពោះយោបីបើបានមកនៅក្នុងផ្ទះអញ ៗ នឹងបំរើផ្គើចិត្ត ផ្គាប់ចិត្តអ្នកនោះបានហោង ៗ

លំដាប់នោះ, ព្រះមហោសថគិតថា ស្រីនេះមានប្ដីហើយក្ដី ក៏គួរអញដណ្ដឹងស្រីនេះលេងមើលហ៎ះ, ពោះបីបើនាងមានប្រាជ្ញាក្ដី ក៏អញអាចដឹងអាថ៌ប្រស្នាអំពីចម្ងាយឥឡូវនេះហោង, ព្រះមហោសថគិតនូវប្រការអម្បាលនោះហើយ ក៏ក្ដាប់ដៃបង្ហាញទៅនាងអមរា, នាងអមរាដឹងហើយថា អ្នកនេះដណ្ដឹងអញហើយថា សុភាពមានប្ដី ឬឥតប្ដីនៅឡើយ? នាងគិតដូច្នោះហើយ នាងឈរនៅឋាននោះហើយ នាងលាដៃបង្ហាញមកពោធិសត្វវិញហោង ៗ រីព្រះមហោសថអ្នកប្រាជ្ញអាចដឹងជានាងនេះបេះដោះសាអាថ៌ប្រស្នានោះហើយ ក៏ដើរចូលទៅទៀបហើយដណ្ដឹងថា ភទ្ទេ ម្នាលនាងស្រីក្រមុំព្រហ្មចារីអើយ! នាងដើរមកនាងឈ្មោះអ្វី នាងចូរស្រដីប្រាប់បង ដ្បិតបងចង់ដឹងស្គាល់នាងហ៎ះ? ៗ រីនាងអមរាក្ដីហើយឆ្លើយថា សាមិ ម្នាលអ្នកអើយ! រីឈ្មោះអញខ្ញុំឯណា ក្នុងកាលជាអតីត នឹងអនាគតក្ដី ក្នុងកាលបច្ចុប្បន្នឥឡូវនេះក្ដី ឥតអង្គមានឡើយ, រីអំពើនោះគេយកមកជាឈ្មោះនៃអញខ្ញុំដូច្នេះណាអ្នកអើយ! ៗ ព្រះមហោសថស្ដាប់ពាក្យនាងអមរាហើយថា ភទ្ទេ ម្នាលនាងអើយ!

(នៅមានត)

# ផ្នែកអក្សរសាស្ត្រ

## វប្បធម៌ខ្មែរ

## តន្ត្រីជាមែកធាងនៃវប្បធម៌

លោក លី · ធាមតេង

សមាជិកក្រុមអភិបាល សមាគមអ្នកនិពន្ធខ្មែរ

រៀបរៀង

---

យើងបានដឹងមកហើយថា តន្ត្រីក៏ជាមែកធាងមួយយ៉ាងសំខាន់នៃវប្បធម៌របស់ជាតិនីមួយ ៗ ព្រោះតាំងពីដើមរៀងមក តន្ត្រីមិនត្រឹមតែជាគ្រឿងកែកំសាន្តតែម្យ៉ាងទេ គឺជាមេគំនិតមួយក្នុងផ្នែកសិល្បៈ ហើយដែលអ្នកប្រាជ្ញរមែងទុកជាមធ្យោបាយយ៉ាងប្រសើរ ក្នុងការលាតត្រដាងគំនិត, កាយវិការនិងល្បិចឧបាយរបស់លោក ៗ ហេតុនេះហើយបានជានៅសម័យបច្ចុប្បន្ននេះ គេតែងលើកយកតន្ត្រីធ្វើជាមុខជាមាត់នៃប្រទេសក្នុងសម័យបាតុកម្មអន្តរជាតិធំ ៗ ឬក្នុងការប្ដូរផ្លាស់វប្បធម៌រវាងប្រទេសមួយនិងប្រទេសមួយ ៗ បានសេចក្ដីថា បើគេបានពិនិត្យពីតន្ត្រីរបស់ប្រទេសណាមួយឲ្យបានជាក់លាក់ គេនឹងបានស្គាល់ប្រាកដពីអារ្យធម៌ គឺទំនៀមទំលាប់ ការរស់នៅ ប្រពៃណីសេចក្ដីជឿនលឿននិងមនោគតិរបស់ប្រទេសនោះ ៗ

បើយើងពោលមកដូចនេះ យើងត្រូវនឹកវិលមកមើលតន្ត្រីនៃប្រទេសយើងម្តង ៗ យើងឃើញតន្ត្រីខ្មែរមានកំណើតមកជាយូរអង្វែងហើយ តាំងពីគ្រាដែលខ្មែរស្គាល់នាអារ្យធម៌ របស់ខ្លួនមកម្ល៉េះ ៗ ឯការល្អណាស់នៃតន្ត្រីនេះ តែងតែមានដំណើរប្រព្រឹត្តទៅមុខជាដរាប ព្រោះដូចយើងពោលខាងលើហើយថា តន្ត្រីរមែងតែល្អណាស់ទៅតាមចង្វាក់នៃវឌ្ឍនធម៌របស់មនុស្ស ៗ រហូតមកដល់សព្វថ្ងៃ តន្ត្រីខ្មែរតែងតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បរិបូរណ៍ឡើងទៀត សំរាប់ជួយបំពេញសេចក្តីត្រូវការនៃជនជាតិសម័យថ្មីនេះ មានការប្រែផ្លាស់ជាមួយប្រទេសជាដើម ៗ ប្រសិនណាជា យើងឃើញតន្ត្រីយើងមានគោលចារឹក មានលក្ខណសម្បត្តិសមសួនដូចនេះហើយ តើយើងត្រូវមានភារៈក្នុងការរក្សាទុករៀបចំតន្ត្រីជាតិយ៉ាងណាទៀតទេ? យើងឆ្លើយចំពោះសំនួរនេះភ្លាមថា យើងត្រូវមានភារៈប្រាកដណាស់ ក្នុងការរៀបចំថែរក្សាទំនុកសាងតន្ត្រីនេះឲ្យមានសភាពទាន់កាលទាន់សម័យដូចអារ្យប្រទេសនានាដែរ ដ្បិតយើងទុកដាក់ជាស្រេចថា តន្ត្រីជាមែកធាងដ៏សំខាន់នៃវប្បធម៌ជាតិ ៗ ហេតុនេះតន្ត្រីយើងក៏ត្រូវតែមានលក្ខណៈជាខ្មែរពិតប្រាកដដែរ ទោះតន្ត្រីបែបបុរាណក្តី បែបទំនើបក្តី ។ ឧទាហរណ៍ជាក់ស្តែង គឺនៅគ្រាបច្ចុប្បន្ននេះ ដែលប្រទេសជាតិយើងកំពុងតែមានការចំរើនល្អណាស់ ទៅមុខជារៀងរាល់ថ្ងៃ ៗ ពលរដ្ឋខ្មែរកំពុងតែពួតដៃគ្នាកសាងប្រទេសជាតិមានការបំ-

ពេញពលកម្មស្ថាបនាទំនប់ទឹក, លើកផ្លូវថ្នល់, មន្ទីរពេទ្យ, សាលារៀនជាដើម ពោលគឺជាសម័យកសាងប្រកបដោយកាយវិការរហ័សរហួនញាប់ដៃញាប់ជើងប្រុងប្រៀបស្មារតីម៉ឺងម៉ាត់គ្រប់ៗគ្នា ។ រីឯតន្ត្រីទំនើបដែលជាគ្រឿងកំដរបរិយាកាសបច្ចុប្បន្នក៏គួរតែមានសភាពរហ័សរហួន នឹងម៉ឺង-ម៉ាត់ដូចគ្នាដែរ ដើម្បីជាជំនួយជួយរុញច្រានកំឡាំងសាមគ្គីនឹងកំឡាំងពលកម្មស្ថាបនាជាតិរបស់យើង ឲ្យរឹតតែលឿនទៅកាន់សេចក្តីចំរើនថែមឡើងទៀត ។ បានសេចក្តីថា ប្រសិនជាយើងរៀបចំទំនុកច្រៀងឬក្រងជាបទណាមួយ យើងគួរធ្វើបទនោះឬទំនុកនោះឲ្យប្រកបដោយចលនារស់រវើក ពោរពេញទៅដោយភាពស្វាហាប់ មានវិស័យដូចជាគ្រឿងដឹកនាំចិត្តអ្នកស្តាប់ឲ្យស្ទុះ ទៅក្នុងការបញ្ចេញកំឡាំងពលំដើម្បីស្ថាបនាជាតិឲ្យបានទៅជាប្រទេសអារ្យៈមួយ ពេញលេញសមសួនដូចរដ្ឋនានាក្នុងចំណោមរដ្ឋដែលចំរើនល្អលាស់ជាងគេ ។ ត្រង់ចំណុចនេះ យើងឃើញដូចជាការពោលនេះឯងហួសនិស្ស័យបន្តិច ព្រោះថាគ្រាន់តែស័ព្ទសំនៀងតូរ្យតន្ត្រីសោះ ហេតុអ្វីក៏អាចទៅជាគ្រឿងជួយបំប៉នកំឡាំងការកសាងជាតិបាន? ប៉ុន្តែបើយើងរស់ឲ្យសព្វគ្រប់នូវទំហំនៃតន្ត្រី យើងឆ្លើយថា ពុំមែនជាការហួសនិស្ស័យទេ ដ្បិតមនុស្សត្រូវការបញ្ញាស្មារតីឬមនោសញ្ចេតនាសំរាប់រុញជំរុល ការប្រតិបត្តិរបស់បុគ្គលនោះ ៗ ឲ្យទិតទំ ឲ្យឈ្នះឈ្នាតស្រាក់ស្រទេញចាប់ប្រកបកិច្ចការអចិន្ត្រៃយ៍ ៗ

យើងមើលចុះ អ្នកពុំសូវប្រកបដោយបញ្ញា ធ្វើការក៏ពុំសូវចំរើនដែរ ទោះបីប្រឹងខិតខំយ៉ាងណាក៏មិនឈ្នះអ្នកដែលមានបញ្ញាដែរ ។ ត្រង់នេះស្របនឹងពាក្យចំនៀមបុរាណរបស់ខ្មែរមួយ ឃ្លាថា "ចេះដប់មិនស្មើនឹងប្រសប់មួយ" ។ បានន័យ សូម្បីអ្នកចេះប្រាកដប្រជាយ៉ាងណា ហើយខំប្រឹងប្រើកំឡាំងខ្លួនយ៉ាងណា បើការងារដែលខ្លួនធ្វើនោះ ពុំបានយកប្រាជ្ញាមកប្រើជាមួយផងទេ, កិច្ចការនោះឯងពិតជាពុំបានសំរេចផលឆាប់រហ័សដូចអ្នកដែលចេះតែល្មម ៗ ហើយប្រើប្រាជ្ញាផ្សំផងនោះឡើយ ។ រីឯតូរ្យតន្ត្រីដូចយើងពោលខាងលើហើយថា ៖ — ជាប្រដាប់បំប៉នបញ្ញាស្មារតីឬជាគ្រឿងពត់ហាត់នៃមនោសញ្ចេតនារបស់មនុស្ស ។ មនុស្សណាមួយក៏រមែងមានការជាប់ជំពាក់ចិត្តក្នុងតន្ត្រីដែរ ។ ឧបមាថាមនុស្សម្នាក់អួតខ្លួនថាគេពុំចេះស្រឡាញ់តន្ត្រីទេ ពុំចេះស្តាប់ភ្លេងទេ ប៉ុន្តែបើយើងទៅលេងភ្លេងក្បែរអ្នកនោះ ហើយលេងបទណាមួយដែលពីរោះរមើល បើមិនអ្នកនោះដក់ចិត្តស្តាប់មួយសន្ទុះទៅដែរ ប្រសិនជាដេញយើងឲ្យចេញឆ្ងាយពីគាត់ ក៏គង់តែមិនទាន់ដេញភ្លាមៗទេ ទុកចាំតែចប់មួយបទសិនដែរ ទើបដេញជាក្រោយ ។

បើសង្កេតតាមនេះ ឃើញថាមនុស្សរមែងត្រូវការចាំបាច់នឹងសិល្បៈតន្ត្រីសំរាប់ជាគ្រឿងបំប៉នបញ្ញាស្មារតី ឬពត់ហាត់មនោសញ្ចេតនាសិល្បៈតន្ត្រីសំរាប់ជាគ្រឿងបំប៉នបញ្ញាស្មារតី ឬ ពត់ហាត់មនោសញ្ចេតនារៀងៗ

ខ្ទង ៗ បើយល់ពិតដូច្នេះហើយ គប្បីគេ យើងយកសិល្បៈតន្ត្រីនេះធ្វើជាមធ្យោបាយពាត់ហាត់សន្តានចិត្តជនរួមជាតិឲ្យបានជឿនលឿនតែម្តង ៗ ព្រោះបុរាណពាក្យយើងពុំមែនក្លែងគិតដល់រឿងនេះទេ មើលចុះ ភ្លេងខ្មែរបុរាណ មានបទល្អងលោមចិត្តក្នុងការនៀយណាយ (បទសត្វមហោរី, បទប៉ះពា · បទផាត់ជាយ . . មានបទបន្ទុកអនុស្សាវរីយ៍របស់មាតុភូមិ (បទនគរជ, សុរិន្ទខ្នង់ភ្នំ, ក្រពាំងការយ..) ទឹងបទបង្ហាញពីបលនាផ្ទៃអ្នកស្រុកក្នុងពេលប្រកបការងារ (បទខ្មែរប្រូតស្រូវ-បោលចាប, អុំទូក ៗ បទទាំងនេះបើយើងយកមកសង្កត់ឲ្យល្អិតល្អន់ម៉ត់ចត់គ្រប់ឃ្លាគ្រប់ពាក្យ យើងច្បាស់ជាឃើញជាក់ស្តែងអំពីកំឡាំងចិត្តរបស់បុព្វបុរសយើងដែលបង្កប់នៅក្នុងនោះ ៗ

ដោយមានលក្ខណ៍ប្រើនយ៉ាងដូចជាយើងស្រង់ខ្លះ ៗ មកពោលជាឧទាហរណ៍ខាងលើនេះហើយ បានជាយើងសន្និតបានថា "តន្ត្រីជាមែកធាងនៃវប្បធម៌" ហើយដែលយើងពុំគាប់ភ្លេងទុកឲ្យនៅមានដំណើរយឺតជាងគេបានឡើយ ៗ

(នៅមានត)

# ពាក្យខ្មែរប្រែចេញពីបរទេស

## ដោយគណៈកម្មការវប្បធម៌

(តមក)

| | | |
|---|---|---|
| Solanacée | *n. f.* | ឆត្តកុល |
| Ombelle | *n. f.* | ឧច្ឆត្តបុស្ប |
| Convolvulacées | *n. f.* | សំវេលកូល |
| Borraginacées | *n. f.* | សោណ្ឌកូល |
| Kutacées | *n. f.* | ពេឡុក្កុល |
| Composées | *n. f.* | និម្ពកូល |
| Roche | *n. f.* | ថ្ម |
| Roche primitive | | សិលាបុព្វជាតិ |
| Roche cristalline | | សិលាក្រាម |
| Roche éruptive | | សិលាឧទ្គម |
| Roche sédimentaire | | សិលាអវសោទ |
| Sédiment | *n. m.* | អវសោទ, កណ្ដង |
| Sédimentation | *n. f.* | អវសោទកម្ម |
| Granit | *n. m.* | កណសិលា |
| Mica | *n. m.* | មីកា |
| Quartz | *n. m.* | ក្វាត្ស |
| Feldspath | *n. m.* | ហ្វេលស្ប៉ាថ |
| Porphyre | *n. m.* | ប្រភិរ្ស៊ីកា |
| Avaries | *n. f.* | ការខូចខាត |
| Dégâts | *n. m.* | អន្តរាយ |
| Détérioration | *n. f.* | ការរិត |
| Lave | *n. f.* | ភូភល |

(នៅមានត)

# វចនានុក្រមសំស្ក្រឹត.ខ្មែរ

ព្រះមហា ប៉ាន់ - ខាត់ រៀបរៀង

(តមក)

អតិភូមិ ស្រ្តី ភូមិក្រៃលែង, ភូមិប្រសើរ, គោលចុងបំផុត ។

អតិភូមិ គមិ, ទៅកាន់ភូមិក្រៃលែង ។

អតិភូរិ គុ. ដែលច្រើនក្រៃពេក ។

អតិភូបី ជាគុ. ស្អិតស្អាងក្រៃលែង ។

អតិភ្ឫតិ គុ. ដែលនាំទៅនូវភារៈក្រៃលែង ។

អតិភ្ឫត គុ. ដែលមានភារៈធ្ងន់, ដែលធ្ងន់; ដែលពេញ

អតិភៃរវ គុ. ដែលគួរខ្លាចក្រៃលែង ។

អតិភោជន ន បុំ ភោជនក្រៃលែង, ភោជនប្រសើរ ។

អតិមញ្ជុល គុ. ដែលទន់ភ្លន់ក្រៃលែង, ។

អតិមតិ គុ. ដែលមានមតិក្រៃលែង ។ អតិមតិមន្ត, គុ. ដែល
មានមតិក្រៃលែង ។

អតិមទ បុំ. សេចក្តីស្រវឹងក្រៃលែង ។

អតិមធ្យំទិន ន បុំ ថ្ងៃត្រង់ក្រៃលែង, ថ្ងៃត្រង់ជាក់ ។

អតិមនី ជាគុ. ប្រមាថ, មើលងាយ ។

(នៅមានទៀត)

ដើមកំណើតប្រាសាទអង្គរ

លោក ល៊ីហ្វ៊ីណូត៍ រៀបរៀង

ក្រោមការ ជុំ-ម៉ៅ ប្រែជាភាសាខ្មែរ

លោក ប៉ែម-ខឹម ពិនិត្យ

និងកែសម្រួលជាថ្មី

( តមក )

---

គេបានឃើញរូបលោកេស្វរ ១ ទៀតដូចជារូបមុននោះដែរ ប៉ុន្តែដោយរូបនោះស្ថិតនៅទីខ្ពស់ជាងមុននោះ គេក៏បានកាត់ព្រះកេសចេញនៅវេលាដែលគេប៉ាស់មេដំបូលខាងលើ ៗ គេឃើញមានរូបមនុស្សបាក់បែកមួយទៀត ប្រហែលជាព្រះពុទ្ធរូបទ្រង់នាគ រូបឈរជាច្រើនបាក់កំបុតហើយធ្លាក់ទៅជាលិង្គវិញ និងរូបព្រះឥន្ទ្រជិះដំរី ៗ តមកទៀតមានរូបរឿងព្រាហ្មណ៍ដំទង់ម្នាក់ ត្រូវព្រួញស្ដេចទសរថស្លាប់ ប្រហែលជាធ្វើតាមរឿងសាមជាតក ៗ

ក្នុងបណ្ដាខ្លោងទ្វារទាំងអស់ មានខ្លោងទ្វារមួយឆ្លាក់រឿងព្រះឥសូរនៅលើដណ្ដើរមុខ ខាងជើង ៗ ខ្លោងទ្វារនោះធ្វើជារូបព្រះឥសូរ មានព្រះព្រហ្ម និងព្រះនារាយណ៍ លុតជង្គង់ប្រណម្យឆ្វេងស្ដាំ ព្រះឥសូរឈរក្នុងប្រឡោះទ្វារ ដែលមានរនាំង ពីរជាន់ទំលាក់មកខាងក្រោយ ដៃស្ដាំកាន់ផ្គាំ ដៃឆ្វេងកាន់បែបជាពាន ១ ៗ នៅមេទ្វារខាងលើ

គេឃើញមានរូបដីឥចក់ ឬរូបក្រពើ ប្រជុំរូបទាំងអស់ហាក់ដូចទំនងជាធ្វើជារឿងរ៉ាវ មិនមែនជាធ្វើសំរាប់គោរពទេឡើយ លើកលែងតែខ្លោងទ្វារ ១ នេះ ខ្លោងទ្វារទាំងអស់ឯទៀតក្នុងថែវជាន់ទី ២ នោះ សុទ្ធតែឬទុកជាខ្លោងទ្វារខាងពុទ្ធសាសនាទាំងអស់ ។

នៅលើមេដំបូល គេបានឃើញបំណែកព្រះពុទ្ធអង្គ ដែលបាក់បែកកាត់កាយជាច្រើន គឺស្នាមរណ្តៅដែលបន្ទុកព្រះពុទ្ធរូបធ្វើជាកំពូល ៗ គេវាយកំទេចព្រះពុទ្ធរូបទោលទាំងអស់ លើកតែរូបខ្លះដែលធ្វើជាឥសី ៗ មាននៅត្រង់កន្លែងសន្និបាត ១ តូចខាងទិសឦសាន, នោះ រូបទាំងឡាយគេបំផ្លាញកំទេចចេញទាំងអស់ ឯប្រាសាទតូច ១ ដែលជាប់បន្ទប់ខាងត្បូងប្រាសាទធំក៏ដូចគ្នាដែរ ។ ស្នាមដែលនៅសល់លើខ្លោងទ្វារខាងត្បូងនោះ ធ្វើឲ្យយើងសំគាល់បានថា ជាព្រះពុទ្ធរូប ១ អង្គទ្រង់ក្មេង និងរូបលោកេស្វរ ១ អង្គ ឈរនៅលើសសរទើងជញ្ជាំង ៗ តពីកន្លែងមហាសន្និបាតទៅ រូបព្រះពុទ្ធទាំងឡាយដែលបានឆ្លាក់ជាប់នៅនោះ គេបានដុសចេញ ប៉ុន្តែ នៅមើលឃើញច្បាស់ប្រាកដ ហើយនៅលើជញ្ជាំងកំពូលទៀត ក៏ឃើញមានព្រះពុទ្ធរូបជាច្រើន ដែលគេវាយបំបាក់ចេញ ឬឆ្លាក់ទៅជាលិង្គវិញ ។

សួរថាចុះអ្វីខ្លះ ដែលជារបស់សម្រាប់សាសនាព្រះឥស្វរដ៏ពិតប្រាកដនៅក្នុងបន្ទាយបាយ័ននោះ? ឆ្លើយថា ខ្ញុំយល់ថាមានតែរបស់តែ

ប៉ុន្មានដូចមានខាងក្រោមនេះទេ គឺ ១ ជញ្ជាំងថែវខាងក្នុង ឯជញ្ជាំងថែវខាងក្រៅនោះគ្មានធ្លាក់រូបអ្វីទេ, ២ អាស្រម ៣ ឬ ៤, មួយសម្រាប់វិស្ណុ ឬព្រះនារាយណ៍ ក្រៅពីនោះសម្រាប់សិវ ឬ ព្រះឥសូរទាំងអស់ ។ វត្តទាំងប៉ុន្មាននេះ នឹងថាទើបនឹងសាងជាក្រោយប្រាសាទនោះគឺថាបានហើយសេចក្ដីដែលថាទើបសាងជាក្រោយនោះ ជាការពិតប្រាកដណាស់ចំពោះអាស្រម ១ បណ្ដាអាស្រមទាំងប៉ុន្មាន ដែលខ្ញុំទើបនឹងជំរាបខាងលើនេះ ។ អាស្រមនេះស្ថិតនៅខាងក្នុងទីធ្លាសានថែវថ្នាក់ទី ២ ។ បើគេទៅឈរពីខាងមុខអាស្រមនេះ ដែលមានជើងភ្នំកណ្ដាលនៅពីខាងត្បូង នឹងថែវដែលព័ទ្ធជុំវិញពីខាងស្ដាំ នោះគេនឹងឃើញខ្លោងទ្វារ ១ នៅពីខាងមុខចំកណ្ដាលជញ្ជាំង ២ ផ្ទាំង ។ ខ្លោងទ្វារនោះមានរូបសិវគឺព្រះឥសូរ ឯជញ្ជាំងនៅទិសខាងកើតមានរូបលិង្គ ឯជញ្ជាំងនៅជ្រុងខាងលិចវិញនោះ គ្មានធ្លាក់អ្វីសោះ ។ សួរថាតើដោយហេតុអ្វីបានជាយ៉ាងដូច្នេះ? ឆ្លើយថា ដោយហេតុជញ្ជាំងនេះបៀតនឹងប៉ះជល់ជើងភ្នំកណ្ដាល ហើយជាងធ្លាក់គ្មានកន្លែងវាល នឹងលូកដៃធ្លាក់ទៅធ្លាក់បាន ជាភស្តុតាងបញ្ជាក់ឲ្យដឹងថា អាស្រមសម្រាប់សិវនេះទើបនឹងសាងជាគ្រាក្រោយប្រាសាទនោះ នៅលើកន្លែងដែលមិនបានបម្រុងទុកនឹងសាងឡើយ ។

សេចក្ដីត្រង់នេះអាចកើតជាសំនួរថា ចុះប្រាសាទសម្រាប់ព្រះឥសូរ

ស្តេចក៏ឲ្យមានលាយឡំរូបផ្សេង ៗ ខាងពុទ្ធសាសនា ដែលគេឃើញមាននៅជុំវិញកន្លែងសន្និបាត ហើយនឹងរឿងក៏ជាច្រើននៅជាប់នឹងជញ្ជាំងបន្ទប់សន្និបាតនោះផង? ឆ្លើយថា តាមគំនិតខ្ញុំ ការទាំងនេះនឹងយកជាប្រធានមិនបាន ខ្ញុំមិនមែនមិនជឿងទេថា នៅក្នុងស្រុកខ្មែរនេះ មានសាសនាលាយឡំចូលគ្នា ដោយមានគណៈដូចគ្នា ហើយដោយសេចក្តីអនុញ្ញាតអំពីម្ចាស់ផែនដីនឹងសេនាបតី ស្តេចយសោវរ្ម័ន បានសាងប្រាសាទ ២ ប្រាសាទ ១ សម្រាប់សាសនាព្រាហ្មណ៍ ១ ទៀតសម្រាប់ព្រះពុទ្ធសាសនា ។

ស្តេចកជេន្ទ្រវរ្ម័ន គ្រងរាជពីសករាជ ៨៦៦ ទៅដល់ ៨៩០ ត្រូវនឹងគ្រិស្តសករាជ ៩៤៤ ដល់ ៩៦៨ ជាក្សត្រកាន់សាសនាព្រះឥសូរ ។ មានសេនាបតីម្នាក់ដែលកាន់ខាងព្រះពុទ្ធសាសនា បានសាងប្រាសាទសម្រាប់សាសនាព្រាហ្មណ៍ ថ្វាយស្តេច នឹងសាងប្រាសាទសម្រាប់ព្រះពុទ្ធសាសនាសម្រាប់ខ្លួនឯង ។ ចារឹកនៅប្រាសាទព្រះខ័ន បានបញ្ចូលធម៌ព្រះឥសូរនឹងធម៌ព្រះពុទ្ធជាមួយគ្នា ។ ប៉ុន្តែយើងសំគាល់បានថា ការចូលគ្នានេះ គឺចូលគ្នាតែដោយសំដីមិនបានជាចូលដល់ទៅមេវិហារជាមួយគ្នានោះទេ ។ ព្រះមហាក្សត្រិយ៍បានសាងវិសន្និបាតទាំងឡាយ សម្រាប់ព្រះផ្សេង ១ មានសម្រាប់ព្រះពុទ្ធផង ឯសាសនាដែលនៅជិតគ្នា តែមិនមែនសត្រូវនឹងគ្នា មានការស្រមជាច្រើនផ្សេងពីគ្នា

នៅក្នុងវិហារជាមួយបាន ។ ប៉ុន្តែ បើស្តេចកាន់សាសនាព្រះឥសូរ បានសាងប្រាសាទ ១ សម្រាប់លិង្គ ជាអ្នកទ្រទ្រង់នៃនគរ ហើយរៀបតុបតែងទ្វាររូបព្រះពុទ្ធ និងរូបទេពធិតាជុំវិញជាច្រើនទុកជារបស់គោរពផងទៀត នោះឃើញថាជាការពិបាកនឹងគិតនឹងនាំឲ្យមានការសង្ស័យជាច្រើន ។

យើងសូមទុកសេចក្តីសង្ស័យនេះ មួយអន្លើសិន ហើយយើងបែរមកពិចារណាសួរថា តើប្រាសាទបាយ័នមិនមែនសាងសម្រាប់ពុទ្ធសាសនាជាមុន ៗ ទើបបានមកជាកន្លែង សម្រាប់សាសនាព្រះឥសូរ ទេឬអ្វី? ការត្រង់នេះយើងពិបាកនឹងឆ្លើយណាស់ ព្រោះហាក់ដូចជាឃ្លាតពីសេចក្តីដែលគេធ្លាប់ជឿ ៗ មក ។

ដូច្នេះ, យើងសូមបញ្ជាក់ ហើយពិចារណាយ៉ាងនេះថា ប្រសិនបើប្រាសាទកណ្តាលនៃទីក្រុងនោះ ជាប្រាសាទសម្រាប់ព្រះពុទ្ធសាសនាហើយ តើទីក្រុងទាំងមូលនោះ កាន់ព្រះពុទ្ធសាសនាដែរឬទេ ។

បើឆ្លើយឲ្យត្រូវនឹងសំនួរនេះ គួរគប្បីពិចារណាដល់ទីឋានដែលមានជាប្រធាន នៅក្នុងក្រុងនោះ គឺទ្វារនឹងកំផែងជុំវិញ ។ សួរថាចុះតើទ្វារនោះនឹងឲ្យយើងបានដឹងការយ៉ាងណាខ្លះ? ឆ្លើយថាខ្លោងទ្វារទាំងឡាយនោះបាក់បែកអស់ទៅហើយ នៅសល់តែបំណែកមួយគង់នៅ ៗ ត្រង់ទ្វារជ័យ ។ បំណែកនោះឃើញជាកងចង្កេះឆ្លងនឹងក្បាលរូបមនុស្ស ៤ ឈរ

នៅកណ្ដាលរូបហោះឯទៀតជាច្រើន ។ លុះធៀបរូបនេះទៅនឹងរូបឯទៀត ដែលមានភាពដូចគ្នា នាំឲ្យសំគាល់បានថា រូបនេះជារូបលោកេស្វរ ។

បន្ទប់ខាងលើនៃទីដែលហៅថា គោបុរនោះ មានខ្លោងទ្វារបន្តបន្ទាប់ រូបទាំងអស់ ឃើញមានសល់រូបខ្លះដែលគង់នៅ គឺសុទ្ធតែជាព្រះពុទ្ធរូបទ្រង់ក្អែន ។

ឥឡូវនេះបើយើងឡើងទៅលើបន្ទាយក្រៅ ហើយដើរជុំវិញមើលទៅប្រាសាទជ្រុងទាំងបួន នោះយើងគ្មានសង្ស័យអ្វីសោះរូបលោកេស្វរធំ ៗ នឹងលេចឡើងដេរដាសនាំឲ្យយើងស្គាល់បានដោយងាយ ។

ឯសេចក្ដីយល់ឃើញនោះយ៉ាងដូច្នេះ គឺថាលោកេស្វរនោះជារូបទេវតា ដែលមានដៃជើងច្រើនទៅអង្គរធំ ហើយអង្គរធំនេះ ដែលគេស្មានថាសាងសម្រាប់សាសនាសិវៈជាដកបមកនោះ កាលវេលាសាងនោះ គេសាងសម្រាប់ពុទ្ធសាសនាទេ ។

សេចក្ដីយល់ឃើញនេះ ខុសគ្នាយ៉ាងធំ នឹងគំនិតដែលធ្លាប់ជឿមក ហើយដែលយើងត្រូវតែរកសំអាងអំពីសេចក្ដីយល់ឃើញនេះ ដោយរករឿងប្រហែលគ្នាមកអធិប្បាយ គឺយើងបានដឹងថាមានប្រាសាទ ១ ផ្សេងទៀត មានបែបផែនប្រហែលនឹងអង្គរធំដែរ ដែលហៅថាប្រាសាទបន្ទាយឆ្មា ។

ប្រាសាទបន្ទាយឆ្មាស្ថិតនៅខាងជើងបំផុត នៃទីរួមខេត្តបាត់ដំបង

នៅលើដើមភ្នំដងរែក គឺជាប្រាសាទមួយ ដែលបាក់បែកខ្ទេចខ្ទាំជាងគេ ហើយទីក្រុងស្តេចប្រហែលជាផុតត្រឹមប្រាសាទនេះ ។ លោកគ្រោស្លីយេ បានពិនិត្យសព្វគ្រប់ទៅឃើញថា ប្រាសាទនេះប្រហែលពិតជារបស់ស្តេចជយវរ្ម័នទី ២ គឺប្រាសាទអមរេន្ទ្របុរៈដែលសាងក្នុងសករាជ ៨០០ ក្នុងពាក់កណ្តាលឆ្នាំ ៩០០ នៃគ្រិស្តសករាជ ។

បើយើងពិនិត្យបន្ទាយឆ្មា តាមទស្សនៈខាងសាសនា នោះយើងនឹងស្គាល់មួយរំពេចនៅពេលដែលក្រឡេកទៅចំប្រាសាទ គឺដំបូលទាំងអស់មានបន្ទុបកំពូលថ្មហើយមានរចនារូបអមព្រះពុទ្ធពីសង្ខាង គឺរូបព្រះពុទ្ធទ្រង់ភ្នែនក្នុងក្បាំងដែលគេលកខ្លួន ។ នៅគ្រប់តែសសរទាំងអស់នោះ មានរចនាជារូបស្រ្តីទេពអប្សរ នឹងព្រះពុទ្ធរូបគ្រប់កន្លែង ។ គេបានឃើញនៅមេទ្វារខាងលើ រឿងរ៉ាវទាំងឡាយរបស់ព្រះពុទ្ធ មានរឿងត្រង់ព្រះអង្គចេញពីនគរទៅទ្រង់ផ្នួស ឬត្រង់គេគោរពព្រះពុទ្ធជាដើម ។ នៅជញ្ជាំងខាងលិច ប៉ែកខាងត្បូង នៅជញ្ជាំងថែវនោះ មានឆ្លាក់រូបលោកេស្វរ ៨ យ៉ាង, មានកំពស់ប្រហែល ២ ម៉ែត្រ ។

ក្រៅពីគេបានរកឃើញក្នុងប្រាសាទនោះ រូបពោធិសត្វមួយអង្គ នឹងព្រះពុទ្ធរូប ២ អង្គ ។

បញ្ចប់សេចក្តីទៅឃើញថា រូបទាំងប៉ុន្មានដែលមាននៅប្រាសាទនោះ ជារូបក្នុងព្រះពុទ្ធសាសនាទាំងអស់ លើកតែកន្លែងមួយចេញ គឺ

បន្ទប់ដែលមានក្រឡាខ្វែង ៤ ជ្រុង នៅខាងមាត់ទ្វារចូលទៅកំផែងខាងក្នុង ៗ ខ្លោងទ្វារមួយនៃបន្ទប់នោះមានឆ្លាក់ជារឿងព្រះឥសូរ គឺរូបព្រះឥសូរ ដែលមានពួកព្រាហ្មណ៍ជាអ្នកគោរព និងព្រះវិស្ណុ ៗ ឯខ្លោងទ្វារឯទៀតនោះមានរូបមិនប្រាកដ ៗ ប៉ុន្តែ វិមាននេះដែលគេឃើញមានក្នុងបំណោមប្រាសាទធំ ៗ ឯទៀតនោះ ហាក់ដូចជាមានភាពជាគេមិនពប់អាន ហើយហាក់ដូចជាខុសពីប្រាសាទឯទៀត ដែលជាប្រាសាទកសាងឡើងសម្រាប់សាសនាដែរ ៗ

ម្យ៉ាងវិញទៀត ក្រៅពីរូបលោកេស្វរទាំង ៨ រូបចម្លាក់នៅលើថែវទាំងឡាយគ្មានឡើយ គឺមានតែរឿងចម្បាំងជាក្បួនហែ និងរឿងពាំរបស់ស្ដេច ៗ គេឃើញមានរឿងព្រាហ្មណ៍អង្គុយគោរពលិង្គ ១ ដែរ ប៉ុន្តែ រឿងនេះគ្រាន់តែតុបតែងទៅជាគំនូរប៉ុណ្ណោះទេ និងយកជាការឲ្យដឹងថា អ្នកកសាងគោរពរូបនេះក៏ទេដែរ ៗ

ដូចេះក្នុងទីនេះ យើងឃើញរូបព្រះពុទ្ធទាំងអស់ ដែលមានសល់នៅឯអង្គរធំ និងរូបទាំងឡាយ ដែលពួកអ្នកគោរពរូបនៅអង្គរបានដំនឹងញញួ គោះបោល និងធ្វើឲ្យខុសរូបកងដើម ៗ ក្នុងក្រុងទាំងពីរនេះគេឃើញតែរូបលោកេស្វរទេ ដែលតាំងនៅក្នុងកន្លែងកិត្តិយស គឺរូបលោកេស្វរនេះលេចឡើងជាចៅហ្វាយនៃទីក្រុងនោះ ៗ អម្រេន្ទ្របុរៈនិងយសោធរបុរៈជាទីក្រុងពីរមានភាពដូចគ្នា ហើយទីក្រុង ១ នៅមានទំនង

ជាទីក្រុងសម្រាប់ពុទ្ធសាសនា ឯទីក្រុង ១ ទៀតនោះបាត់ភ័ស្តុតាងអស់ខ្លះ ទៅហើយ ។ សេចក្ដីដែលថាដូចគ្នានេះមានយ៉ាងពិតប្រាកដ ដូចជា ក្បាច់ចម្លាក់កំពូលមុខបួន ខឿនទេវរូបនាគ ទឹងនៅខាងកើតទីក្រុងមានស្រះ ធំ ១ រាងបួនជ្រុង ឯផែនទីក៏គ្មានការប្លែកអ្វីឲ្យជាសំខាន់ដែរ គឺគ្រាន់តែ ប្លែកថា ក្រុងអង្គរធំនោះមានទំហំធំជាងបន្ទាយឆ្មា ២ ដង ហើយ ១ ទៀត ឯសីមានៃអង្គរធំនៅក្នុងកំផែងជុំវិញ ឯសីមានៃបន្ទាយឆ្មាវិញនោះ ស្ថិត នៅចន្លោះកំផែង ទឹងដីទួលដែលលើកសម្រាប់ការពារក្រុងពីខាងក្រៅ ៗ ក្រៅអំពីនេះ អង្គរធំជាប្រាសាទមានភាព ដូចគ្នាសុទ្ធនឹងបន្ទាយឆ្មា ជា ក្រុងមួយយ៉ាងធំ យ៉ាងត្រឹមត្រូវតាមក្បួនខ្នាត ដែលបញ្ជាក់យ៉ាងពិតអំពី អាណាចក្រដ៏ធំទូលាយរបស់ម្ចាស់ផែនដី ទឹងអំពីរបៀបតាក់តែងនឹងរចនា ក្រុង ប៉ុន្តែ របៀបកសាង របៀបតុបតែងទីក្រុងមានភាពមិនខុសគ្នាប៉ុន្មាន អំពីបែបភាពទីក្រុងជាន់មុន ៗ ឡើយ ។ ប៉ុន្តែយើងត្រូវកត់សំគាល់មួយ ចំណែកទៀតថា មានការប្លែកបន្ទាប់បន្សំ ១ ទៀត តែការប្លែកនេះមិននាំឲ្យ មានការប្រែប្រួលអ្វីទេ គឺថាបន្ទាយឆ្មាមានប្រាសាទតូច ១ ប្លែកណាស់ ដែរ ឯអង្គរធំវិញ គ្មានប្រាសាទតូចនេះឡើយ ប៉ុន្តែប្រាសាទតូចនេះ ឃើញមាននៅក្នុងប្រាសាទធំៗ ជិតទីនោះ ដែលសាងក្នុងគ្រាជាមួយគ្នា ៗ បានជាខ្ញុំនិយាយត្រង់កន្លែងនេះដោយពិស្ដារបន្តិច ព្រោះសំណង់របៀប នេះជាសញ្ញាសំគាល់មួយដ៏សំខាន់ក្នុងពង្សាវតារ ហើយម្យ៉ាងទៀតព្រោះ

ខ្ញុំបង់ស្មើសេចក្ដីយល់ឃើញថ្មីមួយចំពោះរឿងប្រាសាទនេះ ។

ប្រាសាទតូច ៗ ទាំងនេះមានបណ្ដោយពី ១២ ទៅ ១៥ ម៉ែត្រ សាងពីថ្មភក់និងថ្មបាយក្រៀមមានសភាពក្រាស់ធ្ងន់ៗ ។ ប្រាសាទនេះចែកជា ៣ ចំណែក ខាងកើត មានយ៉ នៅកណ្ដាលមានបន្ទប់វែង ១ និងខាងលិចមានប៉មមួយ សាងឧទ្ទិសដល់លោកេស្វរដូចមានខ្លោងទ្វារជាសំអាងស្រាប់ ។ បន្ទប់វែងនោះមានពិតាន ១ សំគាល់ឃើញពីខាងក្រៅនូវដំបូលកណ្ដាល ១ និងថែវសង្ខាង ២ ឯពីខាងក្នុង គេសំគាល់ឃើញមានស្នាមខ្ពស់តាបហាក់ដូចជាគេបានបំបាត់សសរ ២ ជួរចោល ហើយរំលំប់ជ្រុងចេញ ។ គួរកត់សំគាល់ថា លើកតែត្រង់កន្លែងព្រះបាទពិធូចេញ-បន្ទប់នេះទទួលពន្លឺតែពីទិសខាងត្បូង ឯជញ្ជាំងខាងជើងងងឹតសូន្យឈឹង ហើយគ្រាន់តែមានធ្វើបែបជាបង្អួចបញ្ឆោតប៉ុណ្ណោះ ។

សព្វថ្ងៃនេះ គេបានរកឃើញប្រាសាទដូច្នេះ ១៥ គឺប្រាសាទព្រះខ័នទាំងពីរ តាព្រហ្ម បឹងមាលា និងបន្ទាយឆ្មា ឯប្រាសាទឯទៀតនោះ ស្ថិតនៅតាមបណ្ដោយផ្លូវធំ ២ នៃស្រុកខ្មែរចាស់ គឺជាផ្លូវដែលចេញពីអង្គរធំទាំង ២ ហើយ ១ ឆ្ពោះទៅខាងកើតគឺទៅព្រះខ័ន ១ ទៀត ឆ្ពោះទៅទិសពាយ័ព្យតម្រង់ទៅភិមៃ ។

តាមធម្មតាប្រាសាទទាំងនេះសង់នៅឆ្ងាយពីគ្នាចំនួនពី ១៥ ទៅ ២០ គីឡូម៉ែត្រ ហើយស្ថិតនៅពីខាងជើងផ្លូវជាដរាប ជាការបញ្ជាក់ឲ្យដឹងថា

ប្រាសាទទាំងនេះទទួលពន្លឺតែពីទិសខាងត្បូង ។ គេសាងប្រាសាទទាំងនេះតាមការប្រែប្រួលនៃផ្លូវ ទុកសម្រាប់អ្នកដំណើរ ។ គេមិនអាចពោលថា ប្រាសាទនេះមិនមែនកសាងសម្រាប់អ្នកដំណើរទេ ហើយបើសិនជាគេគិតថា ប្រាសាទទាំងនេះសាងសម្រាប់លោកេស្វរ ហើយពោធិ-សត្វនេះជួនកាលមាននាមថា លោកេស្វរនៃមន្ទីរពេទ្យ (អរោគ្យសាលី) នោះគេនឹងយល់ថាប្រាសាទដែលសាងរាយតាមផ្លូវធំ ៗ នោះជា មន្ទីរព្យាបាលរោគ គឺអរោគ្យសាលា សម្រាប់បូជនីយស្ថានដែលធ្វើដំណើរទៅកាន់ប្រាសាទដ៏ល្បី ៗ ឈ្មោះ ប្រហែលជាទៅកាន់ប្រាសាទនៃលោកដ៏មានឥទ្ធិឫទ្ធិអាចកំចាត់បង់នៅទុក្ខបាន ។ បើប្រសិនជាប្រាសាទទាំងនោះសាងសម្រាប់ឧបត្ថម្ភមនុស្សជម្ងឺមែន ។ នោះគេគ្មានសង្ស័យអ្វីឡើយដែលឃើញប្រាសាទទាំងនេះនៅក្នុងកំពែងក្រៅឆ្ងាយអំពីទីប្រជុំ ព្រោះកុំឲ្យសៅហ្មងដល់សេចក្ដីបរិសុទ្ធិ ។

ទោះជាយ៉ាងណាក៏ដោយ ដោយយើងមានការលំបាក នឹងរកពាក្យហៅប្រាសាទទាំងនោះឲ្យចំប្រាកដ ហើយដោយប្រាសាទនោះមានឈ្មោះផ្សេង ៗ ឯពាក្យដែលគេធ្លាប់ហៅថាប្រាសាទគំរូទ័ពជ័យ ៗ នោះហាក់ដូចជាមិនមែនជាឈ្មោះពិតប្រាកដរបស់ប្រាសាទនោះឡើយ ដូច្នេះយើងសូមសន្មតកំណត់ហៅប្រាសាទនេះថា អរោគ្យសាលាវិញ, ប៉ុន្តែ បើថ្ងៃក្រោយគេរកភស្តុតាងឃើញពិតប្រាកដ អំពីឈ្មោះនៃប្រាសាទទាំងនោះយើង

ទីងយកឈ្មោះជាក្រោយមកជំនួសវិញដូច្នេះ បន្ទាយឆ្មាមាន អគ្នេយ្យ-សាលា ១ ឯអង្គរធំគ្មានទេ ព្រោះប្រាសាទដ៏តូចដូច្នេះ មិនសមនឹងសេចក្តីត្រូវការនៃទីក្រុងដ៏ធំឡើយ ។ ប៉ុន្តែ គេឃើញមានអគ្នេយ្យសាលានេះក្នុងប្រាសាទផ្សេង ១ ជិតទីនោះ គឺនៅប្រាសាទតាព្រហ្ម ប្រាសាទព្រះខ័នទីងក្នុងប្រាសាទមួយទៀតនៅជាប់ពីគេទៅក្នុងព្រៃខាងជើងក្រុង គឺប្រាសាទផ្លូវ ។ តាមការសង្កេតទូទៅគេអាចសំគាល់បានថា ប្រាសាទបន្ទាប់បន្សំនេះជាលក្ខណៈពិសេសមួយនៃប្រាសាទទាំងឡាយ ដែលកសាងក្នុងជំនាន់ដែលយើងអាចហៅថា ជំនាន់សិល្បៈបាយ័ន ហើយប្រាសាទនេះនឹងត្រូវគេពិនិត្យជាខាងក្រោយទៀត នៅវេលាដែលគេនឹងពិនិត្យរឿងក៏ដែលទាក់ទងនឹងប្រាសាទដែលសាងក្រោយ ១ ដូចប្រាសាទព្រះខ័នខាងកើតទីងបឹងមាលា ។

(នៅមានត)

# កណ្ឌទី ៤៥

ទុកញ៉ាបុលកដសេនា គួ-កិង ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលចំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

## សាមកុកខ្សែ ៤៥

តាំងពីទៀវឡុងបាច់ទៀវហិមបាន ឡោភីស្រីទៀវហ៊ុយទៅវាយស្រុកចុំឡេងបានហើយ គួមអ៊ូទទួលយកអាសាទៅវាយស្រុកទៀងសាបែកបានបាងគុង នឹងអ៊ីវបរៀនស៊ុនគួនបារាំង នឹងទៀវស៊ានទៀវឡៅគីស្លាប់ ឡោសុកទៅវាយយកស្រុកកេងជីវពីឡៅពី ខុងបេង ។

ខុងបេងសួរថា ហេតុម្តេចបានចងទៀវហមទុកដូច្នេះ ទៀវហម ក៏អធិប្បាយសេចក្តីឲ្យខុងបេងស្តាប់គ្រប់ប្រការ ខុងបេងក្តុដូច្នោះក៏ឲ្យ ស្រាយចំណងទៀវហមចេញ ហើយនិយាយនឹងដូឡុងថា ទៀវហម ពប់អានអ្នកដោយស្មោះត្រង់ បានជាលើកបងថ្លៃឲ្យជាភរិយាអ្នក នោះក៏ ឃើញថា ជាការគាប់ប្រសើរ ហេតុអ្វីអ្នកត្រឡប់ទៅខឹងសម្បានឹងគេវិញ ដូឡុងថា ទៀវហមនឹងខ្ញុំបានពប់អានគ្នាដោយបាននាំរឿងក៏វឃើញថា

សែស្រឡាយជាមួយគ្នា គួរប្ដីទៀវហាមមកលើកបង់ថ្លៃឲ្យខ្ញុំបាទនោះ មិនគួរសោះ ព្រោះនាងនោះជាស្រីមេម៉ាយ នឹងបង្ខំឲ្យគេមានប្ដីក៏ខុសទៅ ប្រការមួយខ្ញុំបាទ ក៏នៅមិនទាន់ទុកចិត្ត ព្រោះទៀវហាមនឹងខ្ញុំបាទទើបតែនឹងស្គាល់គ្នា ឡាចនឹងប្រើជាកលឧបាយយ៉ាងណាក៏មិនដឹង ឯការដែលលោកប្រើមកជាមុខក៏នឹងខូចទៅ ប្រការមួយ ឡៅពីជាចៅហ្វាយនាយកំពុងព្រួយចិត្តនឹងរិះគិតធ្វើការអ្វី ៗ ពុំទាន់ឃើញមុខបាទយ៉ាងណា ប្រាថ្នានឹងទំនុកបំរុងផែនដីក៏ពុំទាន់សម្រេច ឡៅពីទៅដេកធ្វេចភ្នែកមិនជិតជាប្រក្រតី ដែលខ្ញុំបាទនឹងមកយកស្រីជាភរិយានោះ ឃើញថាមិនគួរសោះប្រៀបដូចជាផ្ទិនមុនដណ្ដាំ មនុស្សទាំងពួងក៏ចាំតរបាននិន្ទា ៗ

ឡេវពីឮដូច្នោះក៏និយាយនឹងដូឡុងថា ការក្បុនស្រុកចារ៉ុយអៀងក៏សម្រេចហើយ យើងនឹងរៀបចំឲ្យបានគ្នាជាភរិយាស្វាមីតាមពាក្យទៀវហាមទៅចុះ ដូឡុងថា ដែលលោកនឹងឲ្យខ្ញុំបាទយកស្រីមេម៉ាយនោះមិនគួរ ព្រោះត្រូវស្រីក្រមុំពេញផែនដី ប្រការមួយ ខ្លួនលោកក៏តាំងទំមិនទាន់ប្រាកដនៅឡើយ នឹងប្រញាប់ទៅយកភរិយានោះ ខ្ញុំបាទមិនព្រមទេ ឡៅពីឮដូច្នោះ ក៏សរសើរដូឡុងថា ជាមនុស្សមានសេចក្ដីសត្យកតញ្ញូណាស់ ទើបយកមាសប្រាក់ឲ្យជាបំណាច់រង្វាន់ដូឡុងជាច្រើន ទើបយកត្រាសម្រាប់ការនោះប្រគល់ឲ្យទៀវហាមធ្វើជាចៅហ្វាយស្រុកដូចដែល ៗ

ទៀវហ៊ុយឃើញដូច្នោះ ក៏និយាយនឹងខុងបេងថា ដូឡុងបានយក

អាសាមានសេចក្តីគាប់ប្រសើរហើយ ឥឡូវខ្ញុំបាទនឹងសុំទាហាន ៣ ពាន់ លើកទៅវាយយកស្រុកប៉ុឡេង ចាប់យកខ្លួនកិមសួនមកជូនលោក នឹងបានជាសេចក្តីគាប់ប្រសើរខ្លះផង ខុនបេងក៏និយាយនឹងទៀវហ៊ុយថា កាលដូច្នេះ ទទួលយកអាសាមកធ្វើការនេះ បានសរសេរសំបុត្រសញ្ញាទុកឲ្យយើង ចុះខ្លួនទៅវាយស្រុកប៉ុឡេងគ្រានេះ មានតែត្រូវសរសេរសំ-បុត្រសញ្ញាទុកឲ្យយើងសិន ទើបបានទៀវហ៊ុយក៏តាំងសរសេរសំបុត្រសញ្ញាទុកឲ្យខុនបេងថា ខ្ញុំបាទនឹងសុំយកអាសាទៅវាយស្រុកប៉ុឡេងចាប់ខ្លួនកិមសួនឲ្យបាន បើមិនបានដូចសញ្ញានេះទេ ក៏ឲ្យកាត់ក្បាលខ្ញុំបាទវិញចុះ ហើយទៀវហ៊ុយក៏លាខុនបេងនាំទាហាន ៣ ពាន់ ស្រូតលើកទៅដល់ស្រុកប៉ុឡេង ទើបឲ្យតាំងបន្ទាយមាំមួនខាងក្រៅស្រុក ។

ឯកិមសួនចៅហ្វាយស្រុកដឹងថា ទៀវហ៊ុយលើកទ័ពមក ក៏រៀបបំរុងសេនាទាហានទុកព្រម ដើម្បីនឹងលើកចេញមកច្បាំង ខុនជីទប្រឹក្សាក៏និយាយនឹងកិមសួនថា ដែលលោកនឹងលើកចេញទៅតស៊ូនឹងទៀវហ៊ុយនោះមិនគួរ ព្រោះឡៅពីជាពូជព្រះកដវង្សព្រះចៅហៀនតេ ហើយមានជម្រះប្រាជ្ញាតាំងចិត្តក៏ល្អសុភាពនឹងអាណាប្រជានុរាស្ត្រទាំងពួង ឯទៀវហ៊ុយដែលជាប្អូនឡៅពីលើកទ័ពមកគ្រានេះ ក៏ជាមនុស្សមានកំឡាំងខ្លាំងពូកែណាស់ មុខជាយើងតស៊ូមិនបាន សូមឲ្យលោកចេញទៅចំណុះចុះចូលនឹងទៀវហ៊ុយតែម្តងទៅចុះ ទើបបានសេចក្តីសុខតទៅ ។

កិមសួនឮដូច្នោះក៏ខឹងណាស់ ឆ្លើយតបទៅខុនដីថា ខ្ញុំនេះគិតជាកលសឹកឬ? បានជានិយាយតូលទៅទាន់ទៀវហ៊ុយ ជាផ្លូវគោតញញើតដូច្នេះ ហើយក៏បង្គាប់ទាហានឲ្យយកខ្ញុំខុនដីទៅសម្លាប់ ទីប្រឹក្សានឹងទាហានទាំងពួងក៏និយាយយល់ទាស់ថា ការដែលទ័ពធ្វើសឹកសង្គ្រាមជាធំលោកមិនទំគិត មកទាស់ចិត្តដោយពាក្យទីប្រឹក្សាដំពបប៉ុណ្ណេះមិនគួរទេ សុំឲ្យលោកលើកទោសម្ដងទៅចុះ កិមសួនឮដូច្នោះក៏រសាយកំហឹង ឲ្យលើកខុនដី ហើយកិមសួនក៏រៀបចាត់ចែងសេនាទាហានលើកចេញទៅចម្ងាយផ្លូវពីស្រុកប្រហែល ២០០ សិន (៨ គ.ម.) ប្រទះនឹងកងទ័ពទៀវហ៊ុយលើកមកក៏បញ្ឈប់ទាហាន ទៀវហ៊ុយជិះសេះកាន់លំពែងចេញមកឈរនៅមុខទ័ព ហើយស្រែកសួរថា នរណាចេញមកតស៊ូនឹងយើង កិមសួនឮដូច្នោះក៏ងាកទៅសួរទាហានទាំងអស់ថា នរណាទទួលយកអាសាចេញទៅតស៊ូនឹងទៀវហ៊ុយគ្រានេះបាន ទាហានទាំងអស់ក៏ស្ងៀមខ្លាចថ្វីដៃទៀវហ៊ុយនៅស្ងៀមទាំងអស់គ្នា កិមសួនឃើញទាហានទាំងអស់ស្ងៀមដូច្នោះក៏បរសេះចេញទៅតយុទ្ធនឹងទៀវហ៊ុយ ទៀវហ៊ុយឃើញកិមសួនចេញមក ក៏ស្រែកគំហកដោយសំឡេងខ្លាំង កិមសួនស្ទាំងកាំងភ័យតក់ស្លុតក៏បំបាយសេះរត់ថយមកក្រោយចូលទៅក្នុងស្រុកវិញ ទៀវហ៊ុយក៏លើកទាហានដេញជិតជាប់ទៅដល់កំផែង ខុនដីនឹងទាហានដែលនៅក្នុងស្រុកនោះ គ្រាន់តែឃើញកិមសួនបែកទ័ពត្រឡប់រត់ពីទៀវហ៊ុយមក

ជិតដល់ទ្វារក៏ម្នីម្នាយកធ្នូមកបាញ់ចម្រុះចេញទៅ កិមសួនភ័យណាស់ ក្រឡេកទៅឃើញខុនដីឈរពីលើសេះ ស្រែកថា យើងបាននិយាយហាមឃាត់អ្នកឯងៗ មិនព្រមស្តាប់យើងតាំងពីដំបូង ត្រឡប់រករឿងគិតសម្លាប់យើងវិញ ឥឡូវពួកអ្នកស្រុក ក៏ស្ម័គ្រចិត្តទៅនៅនឹងឡៅពីទាំងអស់គ្នាហើយ ខុនដីក៏យកធ្នូបាញ់ទៅត្រូវមុខកិមសួនធ្លាក់ពីលើសេះ ទាហានទាំងអស់ឃើញដូច្នោះ ក៏ចង់បានសេចក្តីគាប់ប្រសើរនាំគ្នាស្ទុះទៅប្រហារជីវិតកាត់ក្បាលកិមសួនយកទៅជូនទៀវហ៊ុយ ។

ខណៈនោះខុនដីក៏ឲ្យបើកទ្វារស្រុក នាំទាហានទៅគំនាប់ទៀវហ៊ុយៗមានអំណរណាស់ នាំខ្លួនខុនដីទៅជួបឡៅពីខុនបេងឯស្រុកហ៊ុយអៀងហើយស្នើសេចក្តីគាប់ប្រសើរខុនដីជាច្រើន ឡៅពី, ខុនបេងក៏សោមនស្សណាស់នាំគ្នាលើកកងទ័ពត្រឡប់ទៅស្រុកប៉ិឡេង ហើយឡៅពីក៏ប្រគល់ត្រាសម្រាប់ការឲ្យខុនដីធ្វើចៅហ្វាយស្រុក ឡៅពីខុនបេងក៏ប្រើទាហានកាន់សំបុត្រទៅឲ្យគួខស៊ូឯស្រុកកេងជីវ ក្នុងសំបុត្រនោះសេចក្តីថា យើងលើកទ័ពទៅវាយបានស្រុកឡេងឡេង, ដូច្នេះលើកទៅវាយយកស្រុកហ៊ុយអៀងបាន, ទៀវហ៊ុយ លើកទៅវាយយកស្រុកប៉ិឡេងបានទៀតខ្លួនយើងនឹងសេនាទាហានទាំងអស់គ្នា ក៏សុខសប្បាយគ្មានអន្តរាយដោយហេតុអ្វីទេ ។

គួខស៊ូដឹងក្នុងសំបុត្រដូច្នោះ ក៏ធ្វើសំបុត្រតបទៅឡៅពីវិញ សេចក្តី

ថាខ្ញុំបាទគួនអ៊ួ សូមគំនាប់មកដល់អ្នកជាបងបានជ្រាប ព្រោះខ្ញុំបាទដឹងថា អ្នកជាបងបានសេចក្ដីសុខសប្បាយនោះ ខ្ញុំបាទត្រេកអរណាស់, ឯស្រុកហ៊ុយអៀន ស្រុកប៊ុឡេងនោះ ដូឡុងនឹងទៀវហ៊ុយ ទៅវាយបានអស់ហើយ នៅសល់តែស្រុកទៀងសា ១ មិនទាន់បំណុះចុះចូលនៅឡើយ ខ្ញុំបាទជាអ្នកមានសតិបញ្ញានឹងកំឡាំងតិច សុំទទួលយកអាសា ទៅវាយយកស្រុកនោះឲ្យបាន ទាហានក៏នាំសំបុត្រទៅដល់ឡៅពី ៗ ទទួលមើលដឹងសេចក្ដីមានអំណរណាស់ ទើបប្រើទៀវហ៊ុយៈទៅនៅឈរក្សាស្រុកគេងជីវ ហើយឲ្យប្រាប់គួនអ៊ួស្រួតទៅជួបនឹងឡៅពីឯស្រុកប៊ុឡេង ៗ

លុះគួនអ៊ួទៅដល់ ខុងបេងក៏កែងនិយាយថា កាលដូឡុងនឹងទៀវ-ហ៊ុយលើកទ័ពទៅវាយបានស្រុកហ៊ុយអៀងនឹងស្រុកឡេងនោះ ក៏យកទាហានទៅតែម្នាក់ ៣ ពាន់ ឯស្រុកទៀងសានោះ ពីដើមជាស្រុកបំណុះស្រុកគេងជីវ ឡៅពៀវឲ្យឡៅកួនជាក្មួយទៅធ្វើចៅហ្វាយស្រុក ដល់ឡៅពៀវស្លាប់ទៅ ស្រុកទៀងសាក៏ទៅឡើងស្រុកហ៊ូតោវិញ ចូធ្លូតាំងឲ្យហ័នហៀនជាធំឈររក្សាស្រុកនោះ ហ័នហៀននោះ ជាមនុស្សល្ងង់អ័ប្បឥតប្រាជ្ញា នឹងធ្វើការអ្វីមិនពិគ្រោះពិចារណា មានតែគំរាមគំហែងបណ្ដារាស្ត្រឲ្យបានសេចក្ដីក្ដៅក្រហាយ រាស្ត្រទាំងឡាយប្រែចិត្តឥតគោរពខ្លាចស្រឡាញ់ តែវេលានេះ នៅបាម្ដែទាហានឯកម្នាក់ឈ្មោះហាងតុង ពួកស្រុកឡាំអៀងអាយុប្រហែល ៦០ ឆ្នាំហើយ មានកំឡាំងខ្លាំងពូ

តែណាស់តាំងដើមជាចាហានទៀតកូន ៗ ចេញពីភជការទៅ ហង់គុនក៏ស្ម័គ្រទៅនៅធ្វើការនឹងហ៊ានហៀន ដែលអ្នកនឹងលើកទ័ពទៅយកស្រុកទៀនសាគ្រានេះ ត្រូវតែយកចាហានទៅឲ្យច្រើនទើបបាន ព្រោះហង់គុនខ្លាំងពូកែណាស់ ៗ

គួនអ៊ីពុដ្ឋប្តោះ ក៏គិតមានះក្នុងចិត្តថា ខ្ញុំបាទនឹងខ្លាចអ្វីថៃហង់គុននោះព្រោះជាមនុស្សចាស់ទៅហើយ ខ្ញុំបាទសុំយកតែចាហានស្ម័គ្រប័ក្ខពួកខ្ញុំបាទ ៥០០ លើកទៅវាយយកស្រុកទៀនសា កាត់យកក្បាលហ៊ានហៀននឹងហង់គុនមកជូនលោកឲ្យបាន ខ្សាពីក៏និយាយនឹងគួនអ៊ីថា ប្អូនឯងកុំអាលមើលងាយប្រមាថហង់គុនប្តោះ ពោះបើគេចាស់ក៏មែន តែមានកំឡាំងខ្លាំងពូកែណាស់ ដែលប្អូននឹងយកចាហានទៅតែ ៥០០ នោះបង់នៅមិនពាន់ទុកចិត្តសោះ ក្រែងថូស់ការនឹងគេទេដឹង ៗ

គួនអ៊ីពុដ្ឋប្តោះ ក៏មិនសុំយកចាហានថែមទៀត កុំឲ្យខុសនឹងពាក្យដែលថារួចហើយ គួនអ៊ីក៏លាខុងបេងនឹងខ្សាពីលើកចាហាន ៥០០ ចេញទៅ លុះគួនអ៊ីទៅខុងបេងក៏និយាយនឹងខ្សាពីថា គួនអ៊ីលើកពលទៅគ្រានេះ ឃើញថាមើលងាយប្រមាថហង់គុនណាស់ ខ្លាចក្រែងថូស់ការត្រូវយើងលើកចាហានជាជំនួយជូនទៅទៀត ខ្សាពីយល់ព្រមផងក៏រៀបចាត់ចែងចាហានលើកចេញទៅតាមគួនអ៊ីជាមួយនឹងខុងបេង ៗ

ឯហ៊ានហៀនចៅហ្វាយស្រុកទៀងសា លុះដឹងថាគួនអ៊ូលើកទ័ពមក ក៏ប្រឹក្សានឹងហង់ត្រុងថា អ្នកនឹងជួយរិះគិតការពារប្រការម្ដេច ហង់ត្រុងឆ្លើយថា លោកកុំព្រួយអ្វីឡើយ នឹងខ្លាចអ្វីចំពោះគួនអ៊ូប៉ុណ្ណោះ ទោះបីគួនអ៊ូលើកទាហានមកប៉ុន្មានពាន់ ក៏នឹងស្លាប់ដោយគ្រឿងកៅទ័ណ្ឌទឹងដាវដងខ្ញុំមិនខាន អៀវឡេងនាយទាហាន ក៏និយាយនឹងហ៊ានហៀនថា ដែលនឹងចេញតស៊ូនឹងគួនអ៊ូនោះ មិនត្រូវឲ្យក្ដៅរំជួលទៅដល់ហង់ត្រុងជាធំឡើយ សូម្បីតែត្រឹមខ្លួនខ្ញុំបាទក៏នឹងអាចចេញទៅចាប់ខ្លួនគួនអ៊ូឲ្យបាន ហ៊ានហៀនឮដូច្នោះក៏អរណាស់ប្រគល់ទាហាន ១ ពាន់ឲ្យអៀវឡេង ៗ ក៏លើកទា-ហានចេញពីស្រុកទៅ ចម្ងាយផ្លូវប្រហែល ៥០០ សិន (២០គ ម) ទន្ទួលគួនអ៊ូលើកទ័ពមកប្រទះគ្នា អៀវឡេងក៏ញាក់សេះស្ទុះទៅមុខទាហាន គួនអ៊ូឃើញដូច្នោះ ក៏បំផាយសេះដេញចូលទៅប្រយុទ្ធគ្នានឹងអៀវឡេងបាន ៣ ក្បួន គួនអ៊ូក៏យកដាវកាប់ត្រូវអៀវឡេងធ្លាក់ពីលើសេះស្លាប់ ហើយក៏ដេញកាប់សម្លាប់ទាហានអៀវឡេងទៅទល់នឹងជើងកំផែង ហ៊ានហៀនឃើញដូច្នោះ ក៏តក់ស្លុតន្ទតចិត្តទើបឲ្យហង់ត្រុងលើកទាហាន ៥០០ ចេញទៅប្រយុទ្ធគ្នានឹងគួនអ៊ូ ៗ ឃើញហង់ត្រុងជិះសេះលើកទាហានចេញមកក៏ស្រែកសួរថា អ្នកនេះឬឈ្មោះហង់ត្រុង ៗ ឆ្លើយថា អ្នកស្គាល់ឈ្មោះយើងហើយ ហេតុម្ដេចមកសួរធ្វើអ្វីទៀត អ្នកមិនខ្លាចសេចក្ដីស្លាប់ឬទេ ? គួនអ៊ូតបថា យើងលើកទ័ពមកប្រាថ្នានឹងយកក្បាលអ្នកឯង

ហងគុងនឹងចំណាស់ ញាក់សេះចូលប្រយុទ្ធនឹងគួនអ៊ីបាន ១០០ ជើង នៅមិនទាន់ចាញ់ឈ្នះ ហាន់ហៀនក៏ឈរមើលលើស៊ើនបន្ទាយ ហើយឃើញហងគុងច្បាំងនឹងគួនអ៊ីយូរណាស់ គិតខ្លាចថា ហងគុងជាកំឡាំងតិចក្រែងចុះសកាននឹងគួនអ៊ី ក៏ឲ្យគេឃោះហៅហងគុងឲ្យនាំទាហានត្រឡប់ចូលក្នុងផ្ទះវិញ ។

ឯគួនអ៊ីលើកទាហានត្រឡប់ចូលបន្ទាយ ហើយគិតថា វេលាថ្ងៃនេះយើងច្បាំងនឹងហងគុងដល់ ១០០ ជើងហើយ ក៏នៅមិនទាន់ចាញ់ឈ្នះគ្នា វេលាព្រឹកស្អែកយើងនឹងប្រើកលឧបាយបញ្ឆោតហងគុងយកជ័យជំនះឲ្យខាងតែបាន លុះវេលាព្រឹកឡើង គួនអ៊ីក៏លើកទាហានចូលទៅជើងកំផែងហើយស្រែកហៅហងគុង ហាន់ហៀនឮដូច្នោះក៏ឲ្យហង-គុង លើកទាហានចូលទៅដល់ជើងកំផែង ហើយស្រែកហៅហងគុង ហាន់ហៀន ៗ ឮដូច្នោះក៏ឲ្យហងគុង លើកទាហានចេញទៅច្បាំងនឹងគួនអ៊ីបាន ៥០ ជើងគួនអ៊ីក្លែងធ្វើជាចាញ់ទាញសេះរត់ទៅក្រោយ ហងគុងក៏ដេញបណ្តោយតាមទៅសេះនោះក៏ភ្លាត់ជើង ហងគុងក៏ធ្លាក់ពីលើខ្នងសេះដួលសន្ធប់អាវុធក៏ បុកផុតពីដៃ គួនអ៊ីត្រឡប់មក ឃើញលើកដាវឡើងនឹងកាប់ក៏ត្រឡប់ចិត្តគិតឃើញថា យើងបានចេញពាក្យថាទុក បើនរណាគ្មានអាវុធនៅដៃ មិនត្រូវធ្វើឲ្យអន្តរាយ ឥឡូវហងគុងដួលសន្ធប់ចុះជ្រុះអាវុធអស់ពីដៃ បើនឹងសម្លាប់ឲ្យខ្សោយក៏មិនគួរ គួនអ៊ីក៏និយាយនឹងហងគុងថា

គ្រានេះយើងទុកអាយុឲ្យអ្នក ៗ ចូរត្រឡប់វិលទៅស្រុកវិញចុះ យកសេះឯទៀតចេញមកតស៊ូនឹងយើងទៀត ។

ហង់តុងឮដូច្នោះក៏ក្រោកឡើងជិះសេះ នាំទាហានចូលទៅក្នុងស្រុកវិញ ហ័នហៀនក៏សួរហង់តុងថា ហេតុម្ដេចបានជាអ្នកធ្លាក់ពីលើសេះ!? ហង់តុងថាសេះនេះមិនធ្លាប់ជិះចេញចំបាំងមកយូរហើយ បានជាភ្លាត់ជើងឲ្យធ្លាក់ដូច្នេះ ហ័នហៀនក៏ថា អ្នកធ្លាប់មានថ្វីដៃខ្លាំងពូកែ បើជាបាញ់នឹងធ្នូវិញក៏គ្មាននរណាស្មើបាន ហេតុម្ដេចអ្នកមិនយកធ្នូបាញ់គួនអ៊ូ ហង់-តុងថា ក្នុងថ្ងៃនេះចំបាំងជាប់ដៃគ្នា ដាច់ដកបមក បើនឹងវិលមកយកធ្នូក៏មិនទាន់ការ ពេលព្រឹកស្អែកខ្ញុំនឹងធ្វើជាចាញ់ ឲ្យគួនអ៊ូដេញមកដល់ជើងកំផែងស្រុក ហើយនឹងយកធ្នូបាញ់គួនអ៊ូឲ្យបាន ។

ហ័នហៀនក៏យកសេះដែលជិះនោះឲ្យហង់តុង ៗ ក៏ត្រឡប់ទៅកាន់ទីគេហស្ថាន ទើបរិះគិតថា ឮល្បីគេនិយាយថា គួនអ៊ូនេះមានសេចក្ដីស័ត្យពិតត្រង់ ឃើញច្បាស់ប្រាកដមែន គឺគួនអ៊ូទុកអាយុជីវិតយើង មានគុណដល់យើងខ្លាំងណាស់ ពេលព្រឹកស្អែកបើយើងនឹងយកធ្នូបាញ់សម្លាប់គួនអ៊ូវិញក៏ពុំគួរ តែបើយើងមិនបាញ់ ហ័នហៀនក៏នឹងយកទោសយើង ហង់តុងគិតវិតក្កដូច្នេះទើបស្ទើរដេកមិនលក់ លុះព្រឹកឡើងមានទាហានចូលមកប្រាប់ថា គួនអ៊ូជិះសេះមកបញ្ឈរចាំចំបាំងនឹងលោកនៅជិតជើងកំផែង ហង់តុងឮដូច្នោះក៏ឡើងសេះនាំទាហានចេញពីក្នុងស្រុកទៅ ។

ឯគួនអ៊ូក៏គិតមើលឆ្ងាយប្រមាថ ប៉ងទឹងយកជ័យជំនះឲ្យបាន លុះឃើញហងគុងលើកទាហានចេញមក ក៏បរសេះចូលទៅច្បាំងនឹងហងគុងបាន ៣០ ភ្លែង ហងគុងធ្វើជាចាញ់ទាញសេះរត់ទៅក្រោយ គួនអ៊ូក៏បំផាយសេះបណ្ដោយតាមហងគុងទៅ ហងគុងក្រឡេកមើលមកក្រោយក៏យកដងធ្នូដំឡើងខ្សែ តែមិនបានយកព្រួញបាញ់ ១ តែទទេដល់ ២ ដង គួនអ៊ូចាំរង់ក៏មិនឃើញព្រួញទៅដល់តែតែមានចិត្តកំរើបខ្លាំងឡើងទៀត ទើបបំផាយសេះទៅដល់ទឹមស្មាគ្នា ហងគុងរត់ទៅដល់ដើងកំផែងឃើញគួនអ៊ូជិតចូលមក ក៏យកខ្សែដំឡើងធ្នូដាក់ព្រួញបាញ់ដម្រង់តែរំកាយមួកគួនអ៊ូ ១ ភ័យស្លុតក៏ត្រឡប់សេះវិលមកបន្ទាយវិញ ហងគុងក៏ចូលទៅក្នុងស្រុក គួនអ៊ូក៏គិតថា ពុល្បីគេនិយាយថា ហងគុងប៉ិនប្រសប់បាញ់ធ្នូណាស់ ក៏ឃើញមែនប្រាកដ វេលាថ្ងៃនេះប្រហែលហងគុងគិតដល់គុណយើង ដែលយើងទុកអាយុជីវិតមិនសម្លាប់ បានជាបាញ់ធ្នូឲ្យត្រូវតែរំកាយ កយើង ។

(នៅមានត)

# រឿងមនុស្សពិតប្រែប្រួល

## យួនបណ្ណាស្រុក ប៊ូ-ប៉ូ រៀបរៀង

(តមក)

ពេលនោះ ជាផ្លូវប្រាំងកំពុងសោះ មិនដែលមានភ្លៀងលើមទេ ប៉ុន្តែ ដោយសារអំណាចព្រះរាជកុមារព្រះជន្ម ១៦ ឆ្នាំ បានជួបនឹងស្រីក្រមុំអាយុ ១៦ ឆ្នាំ ស្មោះតែបរិសុទ្ធមិនធ្លាប់ស្គាល់កាមរសដូចគ្នា ក៏បណ្ដាលហេតុជាអស្ចារ្យយ៉ាងក្រៃលែង ក្ដៅក្រហាយដល់វេលាហកទៅ-ត(១) បង្អុរភ្លៀងរំលាយយ៉ាងធំ កើតជាមេឃមីរងងឹតអ័ព្ទផ្សែងចាក់ភ្នែកមិនយល់ ផ្គរខ្ទរលាន់ឮត្រាំត្រែងសម្រែងខ្ទរខ្ទារបណ្ដើររណ្ដំញាប់ផ្ទាន់ ខ្យល់ព្យុះសង្ឃរាបោកបក់បាក់មែកព្រឹក្សាជ្រុះស្លឹកផ្ការាសាយពាសពេញផ្លូវពេញស្រុកភូមិ សត្វបក្សាផងតាំងពួងកំភ្លុងតែដេកលក់ក្នុងទ្រនំ ស្រាប់តែភ្ញាក់ផ្អើលភិតភ័យស្រែកកកកាកទ្រហឹងអឺងកងលើមែកក្រៅ ហើរឆ្វេឆ្វាទៅមកកេគ្នីគ្នា ។ ឯពួកមនុស្សម្នាក្នុងជំរើដែលស្ទើរនាំគ្នាគេជ្រកពួនអស់ព្រោះខ្លាចទទឹកភ្លៀង ។ ចំណែកពួកគេឡាះ ១ អ្នកនៅចាំកាលប់អ្នកព្រះរាជកុមារកង្ក្រោយហូរនោះ ក៏ភិតភ័យស្រវាំងកាំង ភ្នែកស្ងួនគ្រប់គ្នាតែបូលដេកក្នុងជំរោកភ្លៀងខ្លួន ។ ស្រីក្រមុំពីរនាក់ដែលជូនខាងនាងទៅនោះល្លុះឃើញនាងនឹងព្រះរាជកុមារចូលទៅក្នុងបន្ទប់តែពីរនាក់ផ្ទាល់ បទទ្វារ

---

(១) [illegible] វេលាហកទេវតា ។

ដិតឈឹងមិនចេញមកវិញដូច្នោះ ក៏នាំគ្នាចុះពីប្រាសាទដើរយ៉ាងលឿនទៅផ្ទះពល់ខ្លួន ៗ ភ្លៀងចាប់ធ្លាក់តាំងពីពេលដិតពាក់កណ្ដាលអធ្រាត្ររហូតដល់ភ្លឺច្បាស់ព្រះអាទិត្យរះទើបរាំងជ្រះស្រឡះ ៗ

លុះព្រឹកព្រាងស្រាងព្រះសុរិយា ព្រះអធិត្តកន្ធកុមារ បានស្គាល់តាមរសជាក់លាក់លែងសន្ទិះសន្ស័យ ទ្រង់បើកទ្វារបន្ទប់យាងចេញមកខាងក្រៅ ត្រាស់បណ្ដេញប្រុស ៗ អ្នកគាល់បំរើឲ្យចុះចេញពីប្រាសាទអស់ លែងឲ្យមានប្រុសនៅជាមួយដល់ម្នាក់ ឲ្យសុទ្ធតែពួកស្រី ៗ ទៅនៅគាល់បំរើវិញ កើតព្រះទ័យប្រចណ្ឌនាងនាងយ៉ាងខ្លាំង មិនឲ្យនាងចេញក្រៅប្រាសាទសោះ ហាមប្រាមពួកប្រុស ៗ មិនឲ្យអ្នកណាចូលទៅជិតនាងនាងឡើយ ដោយប្រទ័យប្រតិព័ទ្ធស្នេហាស្រឡាញ់នាងនាងជ្រុលពេក ទាល់តែកាន់ដាវដាប់ទឹងព្រះហស្ដចេញទៅឈរកណ្ដាលថ្នល់មុខប្រាសាទ ចាំដេញកាប់ប្រុស ៗ ដែលដើរមកតាមផ្លូវនោះដោយមិនបានដឹងរឿងរ៉ាវនោះសោះ ៗ ពួកប្រុស ៗ ខ្លាចរអាគ្រប់គ្នាខ្សឹបខ្សាវប្រាប់គ្នាតៗ ទៅមិនឲ្យដើរតាមផ្លូវកាត់មុខប្រាសាទព្រះរាជកុមារឡើយ ៗ

ដំណឹងនេះលេចឮខ្ទរសាយភាយទូទៅពេញទាំងព្រះនគរ ជ្រួតជ្រាបរហូតដល់ព្រះបាទព្រហ្មទត្តជាព្រះវររាជបិតា ៗ ព្រះមហាក្សត្រិយ៍ទ្រង់ស្លុតព្រះរាជហឫទ័យគ្រវីព្រះសិរលាន់ព្រះឧស្ឋថា ឃើអើ ! បិត្តកុមារនេះចំ-ឡែកណាស់តើ កាលនៅក្មេងតាំងពីកើតមកក្លាមស្អប់ស្រីណាស់ មិន

ព្រមឲ្យស្រីបីពពាល់ត្រូវសាច់ខ្លួនទេ គ្រាន់តែឃើញរូបស្រី ឬ ឮសំឡេងស្រីក៏មិនបានដែរ បេះតែស្រែកយំលួងមិនស្ងៀមសោះ ដោយហោចទៅសូម្បីមាតាបង្កើតរបស់ខ្លួនក៏កាន់បីមិនបានផង ឥឡូវនេះបែរជាប្រែផ្លាស់ចិត្តលែងស្អប់ស្រីហើយ ស្រឡាញ់ស្រីយ៉ាងខ្លាំងទៅវិញ ពាល់តែបណ្តេញប្រុសៗ ចេញអស់លែងឲ្យមានប្រុសម្នាក់នៅជាមួយ សូម្បីគ្រាន់តែប្រុសណាដើរកាត់មុខប្រាសាទក៏មិនបាន កាន់ដាវឈរនៅកណ្តាលផ្លូវចាំដេញកាប់ប្រុស ៗ ដែលគេដើរទៅតាមផ្លូវនោះ បើកូននេះវិបលាសចិត្តវង្វេងឈ្លក់នឹងស្រីដល់ម្ល៉េងហើយ តើអញនឹងឲ្យសោយរាជ្យដូចម្តេចកើត ត្រូវតែបណ្តេញវាឲ្យចេញផុតពីនគរទៅ កុំឲ្យវាធ្វើបាបប្រុស ៗ ផងកុំឲ្យខ្មាសគេផង ទ្រង់ព្រះចិន្តាដូច្នេះហើយក៏ត្រាស់ប្រើរាជបុរសឲ្យទៅបណ្តេញព្រះរាជកុមារចេញ ។

ឯព្រះរាជកុមារមិនហ៊ានរើងទទឹងព្រះរាជឱង្ការ នាំនាងនាដចុះចេញពីប្រាសាទយាងសំដៅឆ្ពោះទៅឯព្រៃហិមពាន្ត សង់អាស្រមនៅក្បែរឆ្នេរស្ទឹងគង្គាជិតមាត់សមុទ្រ នៅជាគេទយកពសទាំងពីរនាក់ មិនបានបួសជាគេងតាបសឬសីទេ ។ ព្រះរាជកុមារមិនឲ្យនាងនាដចេញដើរទៅទីឯណាឆ្ងាយពីអាស្រមសោះ ឲ្យនៅស្ងួដណ្តាំតែក្នុងអាស្រមប៉ុណ្ណោះ ឯព្រះអង្គឯងតែងចេញទៅស្វះស្វែងរក ផ្លែឈើមើមឈើយកមកចិញ្ចឹមប្រពន្ធមិនឲ្យអត់ឃ្លាន ។

លុះនៅក្នុងព្រៃយូរមក ថ្ងៃមួយ ព្រះរាជកុមារចេញទៅរកផ្លែឈើក្នុងព្រៃឆ្ងាយ បាត់ទៅតាំងពីព្រលឹម គ្រានោះ មានតាបសមួយអង្គអាស្រ័យនៅកោះមួយនាកណ្ដាលសមុទ្រ បានឈានហោះហើរតាមផ្លូវអាកាសក្នុងទឹកមកបេះផ្លែឈើឯត្រើយសមុទ្រ លុះហោះមកជិតអាស្រមនាងនាងបានឃើញផ្សែងភ្លើងហុយឡើងទៅលើអាកាស ក៏ចុះមកឈរនៅនាមុខអាស្រម ៗ ឯនាងនាងកំពុងតែអង្គុយស្ងួដណ្ដាំ ក្រឡេកឃើញតាបសនិមន្តឡើងទៅគង់ក្នុងអាស្រម និយាយសំណេះសំណាលសាកសួរសុខទុក្ខផ្សេង ៗ ហើយក៏កើតចិត្តជំរេកត្រេកត្រអាលនឹងតាបសដោយកាមរស ទើបនាងនាងធ្វើឫកពាបញ្ចេញកលមាយាស្រីឲ្យតាបសឃើញ ៗ តាបសទ្រាំអត់មិនបានដាច់ឈានក្នុងពេលនោះ ហើយសម្ងំនៅក្នុងអាស្រមជាមួយនាងនាងតាំងពីព្រឹករហូតដល់ថ្ងៃរសៀលជាប់ចិត្តប្រតិព័ទ្ធនឹងនាងនាងដើរចេញមិនរួចដោយសារខានជួបជិតស្រីជាយូរឆ្នាំហើយ ៗ

លុះដល់ថ្ងៃរសៀល តាបសក្រឡេកមើលទៅមុខសាលា ឃើញព្រះរាជកុមារយាងមកពីចម្ងាយលឹម ៗ ក៏ភិតភ័យចុះពីលើសាលាក្ដាមរត់សំដៅឆ្ពោះទៅរកមាត់សមុទ្រយ៉ាងលឿន ៗ ព្រះរាជកុមារទតឃើញតាបសរត់លឿនដូច្នោះនឹកថា តាបសនេះប្រហែលជាមកស្រឡាញ់ដេកជាមួយប្រពន្ធអញហើយ បានជាគ្រាន់តែឃើញអញគេចរត់យ៉ាងប្រញាប់ដូច្នេះ ទើបស្ទុះទៅយកដាវពីអាស្រមដេញតាមតាបសស្ទឹតទៅ ៗ

ឯតាបសតែទៅដល់មាត់សមុទ្រលោតឡើង ប្រុងនឹងហោះឆ្លងទៅឯកោះរបស់ខ្លួន ប៉ុន្តែ ហោះមិនរួចក៏ធ្លាក់ក្តុងទៅក្នុងទឹកសមុទ្រព្រោះដាច់ឈានទៅហើយ ព្រះកុមារតាមទៅទាន់ឃើញតាបសឈរក្នុងទឹកដូច្នោះគិតថាឲ្យតាបសនេះកាលមកពីកោះកណ្តាលសមុទ្រនោះ ប្រហែលជាហោះមកដោយកំឡាំងឫទ្ធិរបស់ឈាន លុះមកជួបជិតប្រឡូកប្រឡំនឹងស្រីក៏ដាច់ឈានហោះទៅវិញលែងរួច បានជាធ្លាក់ទឹកយ៉ាងនេះ ណ្ហើយចុះគួរតែអញអាណិតតាបសនេះកុំធ្វើបាប ព្រោះចិត្តអញក៏ស្រឡាញ់ស្រីដូចចិត្តតាបសដែរ គួរតែអញរំលឹកខ្លួនតាបសនេះវិញចុះ លុះទ្រង់ព្រះចិន្តាដូច្នោះហើយ ក៏ត្រាស់ទៅរកតាបសថា បពិត្រលោកដ៏ចំរើន លោកកុំគិតភ័យខ្លាចខ្ញុំថ្វីឡើយ ធម្មតាស្រីតែងធ្វើឲ្យប្រុសវិលវល់ខ្វល់ខ្វក់ដោយកាមគុណជាប់ជានិច្ច ដ្បិតស្រីមានកលមាយាច្រើនណាស់គ្មានទីបំផុតទេ ដូចពាក្យចាស់ទុំបរមបុរាណលោកសំដែងទុកមកថា ធម្មតាស្រីមានមាយាដូចថ្ងៃបណ្តើរកូន ប្រុសមានទុក្ខសោកពេកភ័យចង្រៃអន្តរាយមកពីសេពគប់ស្និទ្ធស្នាលនឹងស្រី, ស្រីជាចំណងចងប្រុសទុកក្នុងផ្ទះ, ស្រីជាអន្ទាក់របស់សេចក្តីស្លាប់, ស្រីមានរូបកងកាយដូចគោហាជាទីសំណាក់អាស្រ័យប្រុសណាសេពគប់ស្និទ្ធស្នាលវង្វេងស្មារតីទៅតាមស្រី ប្រុសនោះឈ្មោះថាជាអ្នកឥតធម៌ : មួយទៀត ស្រីតែងធ្វើប្រុសអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរឲ្យខូចធម៌ តែងធ្វើប្រុសឲ្យលិចលង់នៅក្នុងវាលវដ្តសង្សារ អ្នកប្រាជ្ញកាល

បើបានដឹងយ៉ាងនេះហើយ គួរតែខំចៀសរកឱ្យឆ្ងាយអំពីស្រី មិនគួរសេពគប់ផ្គេកផ្គិតស្និទ្ធស្នាលរំនួនឈ្មប់ចិត្តនឹងស្រីទេ ដ្បិតស្រីបើសេពគប់នឹងប្រុសណាដោយចិត្តស្រឡាញ់រូបកាយប្រុសនោះក្តី ដោយចិត្តចង់បានមាសប្រាក់ទ្រព្យសម្បត្តិពីប្រុសនោះក្តី តែងបំផ្លេចបំផ្លាញប្រុសនោះឱ្យវិនាសយ៉ាងឆាប់រហ័ស ប្រៀបដូចភ្លើងដុតកំទេចសម្រាម ឱ្យឆេះខ្ទេចអស់រលីងទៅក្សាម ៗ ដែរ នេះសំដៅយកស្រីអាក្រក់ស្រីខាតលក្ខណ៍តែម្យ៉ាង ឯស្រីល្អគ្រប់លក្ខណ៍វិញ មិនមែនបំផ្លាញប្រុសដូច្នោះទេ មានតែជួយទំនុកបម្រុងយ៉ាងប្រុសស្មោះត្រង់នឹងប្តីណាស់ ទុកជាដល់ស្លាប់ខ្លួនក៏មិនក្បត់ប្តីដែរ សមដូចសុភាសិតមួយបទថា "...ដូះចិត្រស្រណុកណា ដ្បិតលក្ខណ៍ស្រីជា" នឹងមួយបទទៀតថា " សំណាបយោងដី ស្រីយោងប្រុស " ។

តាបសឈរកេងទឹកស្តាប់នូវពុទ្ធព្រះរាជកុមារថាប់ហើយ កើតសេចក្តីសង្វេគស្លុតចិត្តបំរើនឈានឱ្យកើតឡើងវិញ ហើយហោះទៅឯកោះជាលំនៅរបស់ខ្លួនឮដ៏គ្រានោះឯង ។

ចំណែកព្រះរាជកុមារកាលបើឃើញតាបស ហោះឡើងពីទឹករូបអណ្តែតត្រសែរទៅតាមអាកាសដូច្នោះ ក៏នឹកពិចារណាថា តាបសនេះចេះចំរើនឈានហោះទៅរួច ឯខ្លួនអញត្រូវតែលះបង់ស្រីចេញ ហើយខំចំរើនឈានឱ្យបានកើតដូចជាតាបសដែរ ទ្រង់ព្រះចិន្តាយ៉ាងនេះ រួច

ត្រឡប់ទៅអាស្រមវិញហៅនាងនាដមកប្រាប់ថា បងគ្មានចិត្តអាក់អន់អ្វី នឹងប្អូនទេការដែលប្អូនធ្វើខុសនឹងបងដូចម្តេច ក៏បងគ្មានចិត្តប្រកួតប្រកាន់ដែរ ប៉ុន្តែពេលនេះបងសូមលាកម្លាពៀវនឹងប្អូនហើយ ដ្បិតចិត្តបងចង់បួសជាតាបសឫសីនៅក្នុងព្រៃនេះរហូតដល់ស្លាប់ បងលែងទៅនៅក្នុងស្រុកទេសវិញហើយ ចូរនាងវិលទៅនៅស្រុកមានប្តីទៀតចុះ ។ នាងនាដឮដូច្នោះ មានចិត្តអាឡោះអាល័យព្រះរាជកុមារណាស់អង្វរសុំនៅជាមួយគទៅទៀតរហូតអស់ជីវិត ។ ព្រះរាជកុមារមិនព្រមឲ្យនាងនៅ ប្រាប់ថាប្អូននៅជាមួយបងមិនបានទេ ព្រោះនាំឲ្យបងខ្វល់ចិត្តណាស់ ចំរើនឈានមិនកើត ប្រាប់រួចជូននាងនាដឲ្យទៅនៅស្រុកកំណើតរបស់ខ្លួនវិញ ហើយត្រឡប់មកអាស្រមបួសជាតាបសឫសីចំរើនឈាន មិនយូរប៉ុន្មានក៏បានសម្រេចដូចប្រាថ្នា លុះធ្វើកាលកិរិយាក្ស័យជីវិតហើយបានទៅកើតនៅឋានព្រហ្មលោកដោយអំណាចឈាន ។

ព្រះរាជកុមារតាបសនោះ គឺជាព្រះសម្មាសម្ពុទ្ធម្ចាស់យើង កាលព្រះអង្គនៅជាព្រះពោធិសត្វនៅឡើយ ។

អ្នកតាកើត–និយាយរឿងបុរសស្អប់ស្រីចប់ហើយ ប្រាប់កូនថា ឯងស្តាប់រឿងនេះឲ្យច្បាស់ចុះ អម្បាលព្រះរាជកុមារ ជាអង្គព្រះបរមពោធិ-សត្វផង មើចក៏នៅតែមានចិត្តប្រែប្រួលមិនទៀងភាត់ដែរ ម្តងថាស្អប់ណាស់ ម្តងថាស្រឡាញ់ណាស់ ឯតាបសៈសាគទៀតជាអ្នកបួសត្រឡាំង

ចំរើនឈានហោះហើរដើរលើអាកាសបាន គ្មានចិត្តសប្បាយរីករាយក្នុងលោកិយសោះ ម៉េចក៏គង់តែដាច់ឈានដោយសារជួបប្រទះនឹងស្រីដែរ ហើយលោកនៅព្រៃហិមពាន្តឆ្ងាយដាច់ស្រយាលពីស្រី ៗ ផង ចំណង់បើឯងនៅក្នុងស្រុកភូមិជាមួយមនុស្សប្រឡូកប្រឡំនឹងស្រី ៗ គរគោកយ៉ាងនេះ ក្រែងឯងស្ទុះមិនរួច ធ្ងន់មិនផុតពីក្បិនស្រី ត្រូវឯងទៅដេកគិតស្ទួរដេញដោលចិត្តខ្លួនឲ្យជាក់លាក់សិន បើថាមុខជាគេចមិនរួចពីយកប្រពន្ធទេ គប្បីយកពីក្មេងឲ្យហើយទៅកុំចាំចាស់ ដូចភាសិតមួយបទថា " ចូលព្រៃទាន់ព្រឹក សឹកទាន់នៅក្មេង " ។

ជីប្រែ – ទេពុ ! ចិត្តខ្ញុំដាច់ស្រេចហើយ ពុកុំបង្ខំខ្ញុំពីរឿងប្រពន្ធកូននោះ ម៉ែថាចាំរើសរកកូនគេអ្នកមានពូជល្អឲ្យខ្ញុំ ៗ ក៏នៅតែមិនព្រមយកដែរ ព្រោះខ្ញុំសំគាល់ថាស្រីទាំងអស់សុទ្ធតែចិត្តវៀច មានកលល្បិចមាយាច្រើនណាស់ ដេញពុតមិនទាល់សោះ គ្មានត្រង់ម្នាក់ទេ ។

អ្នកតាកើត - ចុះម៉េចក៏ឯងដឹង ? បើឯងមិនដែលសេពគប់នឹងស្រីណាសោះ ។

ជីប្រែ– បាទ ! ខ្ញុំមិនដែលស្និទ្ធស្នាលនឹងស្រី ៗ មែន ប៉ុន្តែ កាលខ្ញុំកំពុងរៀន ខ្ញុំបានមើលសៀវភៅមួយដែលគ្រូកនម្នាក់ឲ្យខ្ញុំ ក្នុងសៀវភៅនោះនិយាយអំពី ៖

(នៅមានត)

# ភូមិសាស្ត្រសេដ្ឋកិច្ចប្រទេសឥណ្ឌា

លោក រ៉ូហ្សឹមបែរត៍ អតីតសាស្ត្រាចារ្យនៃមហាវិទ្យាល័យច្បាប់ រៀបរៀង

ក្នុងឆ្នាំ ១៩៥៩ លោក ញ៉ែម-ទឹម នៅក្រសួងធម្មការប្រែជាភាសាខ្មែរ

---

ប្រទេសឥណ្ឌាមានផ្ទៃដីជាង ៤ លានម៉ែត្រក្រឡា ។ កាលពីឆ្នាំ ១៩៤៧, ប្រទេសនេះបានត្រូវបែងចែកជារដ្ឋពីរ: មួយហៅថាប៉ាគីស្ថង់, មួយទៀតគឺសហភាពឥណ្ឌា ។ ការបែងចែកនេះបណ្តាលមកពីសាសនា ។

## លក្ខណៈនៃប្រទេស

ប្រទេសឥណ្ឌាទាំងមូលចែកជាបីចំណែក:

ក)- ខាងជើង: មានជួរភ្នំធំមួយហៅថា ហិមាល័យ (ហិមពាន្ត) ។ ជួរភ្នំនេះមានបណ្តាយ ១.៥០០ គ.ម., ទទឹង ៤០០ គ.ម., ហើយមានកំពូលដ៏ខ្ពស់ក្រៃលែង ។ កំពូលដែលខ្ពស់ជាងគេហៅថា ម៉ុងអេវើរេស្ត៍ (Mont Everest) ៨.៨៤០ ម. ។

ខ) ខាងត្បូង: មានឧបទ្វីបមួយ (Péninsule) យ៉ាងធំហៅថា ដេកង់ (Deccan) ។ គឺជាតំបន់ដីដ៏ចាស់យូរលង់មកហើយ ។ ត្រូវទឹកបក់បោកបាក់បែកតាំងពីបឋមសម័យ ។ ឧបទ្វីបនេះបានរៀនចូលមកប៉ះនឹងទ្វីបអាស៊ី ។ ផ្ទាំងថ្មនៅទីនោះ គឺជាផ្ទាំងថ្មមានឫសកែវដូចគ្នានឹងផ្ទាំងថ្មដទៃណា ។ ប៉ុន្តែ ឧបទ្វីបដែលហៅថាដេកង់នោះបានដុះឡើងវិញនៅក្នុងយុគទីបី តែមិនកើបស៊ោទេ គឺខ្ពស់សងខាងហើយទាបកណ្តាល ។

ជ្រុងខាងលិចខ្ពស់ជាងជ្រុងខាងកើតជាច្រើន ។ ជ្រុងទាំងសងខាងនេះហៅថាហ្គាត (ghâtes: គឺភ្នំនៃឧបទ្វីបដេកង់) ។ នៅខាងទិសពាយ័ព្យនៃដេកង់មានបាតុភូតភ្នំភ្លើងមួយ ដែលញាំងឲ្យដីនៅជិតនោះឲ្យមានដីជាតិយ៉ាងសំខាន់ ។

គ)- នៅចំកណ្ដាលប្រទេសឥណ្ឌា : គឺជាវាលល្បប់មួយយ៉ាងធំ ដែលមានទន្លេធំពីរគឺ អាំងឌុស និងគង្គា បានហូរបាក់បំពេញ ។ ដីវាលនោះរាបស្មើ, គ្មានអ្វី ៗ លូតខ្ពស់ឡើយ ហើយប្រកបដោយដីជាតិផង ។

ប្រទេសឥណ្ឌាមានធាតុអាកាសអាស្រ័យដោយខ្យល់រដូវ ។ ខ្យល់រដូវនេះជាបាតុភូតមួយយ៉ាងសំខាន់ បណ្ដាលមកពីធាតុអាកាសខុសគ្នានៅលើទ្វីបអាស៊ី និងនៅលើមហាសាគរឥណ្ឌា ។ នៅវស្សានរដូវដែនដីគោកមានកំដៅខ្លាំងពេក ឯមហាសាគរមានធាតុអាកាសក្ដៅបន្តិច ៗ ខ្យល់បក់ពីសមុទ្រទៅកាន់ដីគោក គឺពីទិសនិរតីទៅទិសឦសាន ។ ខ្យល់នេះត្រជាក់ហើយសើម ។ រដូវភ្លៀងគឺចាប់ពីខែឧសភាទៅខែវិច្ឆិកា ។ ផ្ទុយទៅវិញ, បើនៅសិសិររដូវ (រដូវត្រជាក់ខ្លាំង) ដែនដីគោកមានធាតុអាកាសត្រជាក់, ឯមហាសាគរនៅក្ដៅបន្តិច ៗ ដដែល ខ្យល់បក់ពីដែនដីគោកទៅកាន់សមុទ្រ គឺពីទិសឦសានទៅទិសនិរតី ខ្យល់ត្រជាក់ហើយស្ងួត ។

រដូវក្តៅគឺចាប់ពីខែវិច្ឆិកាទៅខែឧសភា ។ ប៉ុន្តែ សូមជ្រាបថា ធាតុអាកាសក្នុងប្រទេសផ្សេងៗមិនដូចគ្នាទេ ដូចជានៅរដូវស្ងួតរដូវ, ដំបន់ឯទៀតមានធាតុអាកាសក្តៅទាំងអស់ (កាល់គុត្តា : ខែកក្កដា ២៩ អង្សា ម៉ាដ្រាស : ខែកក្កដា ២៧ អង្សា) ។ ផ្ទុយទៅវិញ, នៅសិសិររដូវ, នៅដំបន់ខាងជើងនៃប្រទេស, ធាតុអាកាសត្រជាក់ណាស់ (ឡាហ៍រ : ខែមករា ១៣ អង្សា ; ម៉ាដ្រាស ខែមករា ២៤ អង្សា) ។

ទឹកភ្លៀងធ្លាក់មិនស្មើគ្នានៅក្នុងប្រទេសទេ ។ អាស្រ័យហេតុនេះហើយ, បានជានៅដំបន់ខ្លះៗ មានភ្លៀងយ៉ាងបរិបូណ៌, ឯដំបន់ឯទៀតៗវិញមានភ្លៀងតែបន្តិចបន្តួច ។ ហេតុនេះ បានជានៅជ្រុងខាងលិចនៃឧបទ្វីបដេកកង់មានភ្លៀង ពី ២ ទៅ ៤ ម៉ែត្រ ក្នុងមួយឆ្នាំ ។ ផ្ទុយទៅវិញនៅត្រង់តំបន់កណ្តាលនៃដេកកង់មានភ្លៀងតិចជាង ៧០០ ម ម. ។ ក្រៅពីនេះ, ខ្យល់ត្រជាក់បាននាំមកនូវទឹកភ្លៀងយ៉ាងសម្បូរត្រង់ទីទៀបជើងភ្នំហិមាលយា ។ នៅបេងហ្គាល់មានទឹកភ្លៀងពី ២ ទៅ ៤ ម៉ែត្រ ប៉ុន្តែខ្យល់រដូវបានទៅប៉ះនឹងភ្នំហិមាលយា ពុំអាចឆ្លងកាត់ភ្នំបានឡើយ ហើយក៏ត្រូវបេរទិសបកពីទិសពាយ័ព្យទៅទិសអគ្នេយ៍វិញ ។ ខ្យល់នេះ ថយត្រជាក់បន្តិចម្តង ។ ហើយពេលឥណ្ឌូ-គង្គាមានភ្លៀងតែ ១ ម. នៅតំបន់កណ្តាល ទឹង ៥០ ស.ម. នៅតំបន់ខាងជើង ក្នុងមួយឆ្នាំ ។

ការដែលទឹកភ្លៀងធ្លាក់មិនស្មើនៅក្នុងប្រទេស បណ្តាលឲ្យប្រជា

ជនទៅបែកខ្ញែកគ្នាដែរ, ហើយសកម្មភាពសេដ្ឋកិច្ចសោត ក៏ប្លែកគ្នាពីកន្លែងមួយទៅកន្លែងមួយ ។

ប្រទេសឥណ្ឌាមានរុក្ខជាតិសម្បូរតែនៅតំបន់ព្រៃភ្នំ ឯក្នុងវាលឥណ្ឌូគង្គាវិញ, គេឃើញមានតែវប្បកម្ម (ការសាបព្រោះ) ។ ប្រទេសឥណ្ឌាមានទន្លេធំពីរគឺ : អាំងឌុស និងគង្គា ។

ក)- ទន្លេអាំងឌុស : ទន្លេអាំងឌុសនេះមានប្រភពចេញមកពីភ្នំហិមាលយា ហើយហូរព័ទ្ធពេនតាមភ្នំនោះអស់ប្រវែង ១៥០០ គ.ម. ។ ទន្លេនេះមានបណ្ដោយទាំងអស់ចំនួន ៣.០០០ គ.ម. ហូរសំដៅទៅដែនដីសណ្ដរ ហើយកាត់តាមដំបន់ស្ងួតហែង ។ គឺជាទន្លេដែលគេពុំសូវប្រើការ ប៉ុន្តែ នៅត្រង់ដំបន់ដែលមានខ្សែទឹកហូរធម្មតា គឺត្រង់ប្រាំងខាងជើងដែលមានដៃទន្លេប្រាំហូរចាក់មក, គេអាចទប់យកទឹកបញ្ចូលទៅក្នុងដំបន់ជិតខាងបាន ។ នៅជិតដែនដីសណ្ដរនៃទន្លេនេះក៏មានកន្លែងសម្រាប់បញ្ចូលទឹកទៅក្នុងស្រែដែរ ។ សព្វថ្ងៃគេមានសង់ទំនប់ទឹកដ៏ធំពីរនៅទីនោះ ។

ខ) ទន្លេគង្គា : ទន្លេគង្គាប្លែកពីទន្លេអាំងឌុស ។ គឺទន្លេនេះហូរបែកចេញភ្លាមពីភ្នំហិមាលយា គឺឥតព័ទ្ធពេនតាមភ្នំទេ ។ គឺជាទន្លេរាបស្មើ មានព្រិលនិងទឹកភ្លៀងហូរចាក់បំពេញ មានបណ្ដោយចំនួន ៣០០០ គ.ម ហើយទន្លេនេះក៏សម្រាប់ទប់យកទឹកបញ្ចូលស្រែបានដែរ ។

នាវាអាចបើកចេញចូលបានដោយស្រួល ។ ទន្លេគង្គានេះបានហូរប្រទាក់ទៅនឹងទន្លេប្រាហ្មាពូត្រ ហើយកើតទៅជាកន្លែងសណ្ដរមួយយ៉ាងធំគឺវដ្តបេងហ្កាល់ ។

## អំពីប្រទេសប៉ាគីស្ថង់

គឺពួកមូលស៊ុយម៉ង់ដែលជាអ្នកបង្កើតរដ្ឋនេះ ពីឆ្នាំ ១៩៤៧ ហើយរដ្ឋនេះមានចែកជាពីរផ្នែកគឺ ប៉ាគីស្ថង់ខាងលិច និងប៉ាគីស្ថង់ខាងកើត, ឃ្លាតពីគ្នាចម្ងាយ ២.០០០ គ ម. ។ ប៉ាគីស្ថង់ខាងលិចស្ថិតនៅខាងទិសនិរតីមាន ទំហំ ៨០០ ០០០ គីឡូម៉ែត្រក្រឡា, ឯប៉ាគីស្ថង់ខាងកើតមានទំហំ ១៤០ ០១០ គីឡូម៉ែត្រក្រឡា ។

ក)– ប៉ាគីស្ថង់ខាងលិច : មានផ្ទៃធំជាងខាងកើត ប៉ុន្តែមានប្រជាជនតិច (៤៥ មនុស្ស ក្នុង ១ គ ម២ ) គឺជាតំបន់ស្ងួតហែងមានភ្លៀងធ្លាក់តិចជាង ៥០០ មីលីម៉ែត្រ, ហើយផលដំណាំអាចធ្វើបានតែដោយសារការបាចទឹកបញ្ចូលស្រែ ។ នៅខាងជើងនៃដំបន់នេះ គឺត្រង់ដំបន់បញ្ចាប់ ( Pendjab ប្រទេសស្ទឹងប្រាំ) រាជការអង់គ្លេសបានធ្វើកន្លែងសម្រាប់បាចទឹកបញ្ចូលស្រែមួយយ៉ាងពិសេស, ហើយបានទាំងដាំផលិតផលពីរមុខយ៉ាងសំខាន់គឺ: ស្រូវសាលី, និងកប្បាស ។ ផុយទៅវិញប៉ែកខាងត្បូងនៃប្រទេសប៉ាគីស្ថង់ខាងលិច ជាតំបន់គ្មានដីជាតិសោះ ។ គេបានសង់ទំនប់ទឹកដើម្បីយកទឹកធ្វើដំណាំ ។ រាជការអង់

គេស បានសង់ទំនប់ទឹកមួយត្រង់សាក្ការ ហើយតាំងពីប្រទេសឥណ្ឌា បានឯករាជ្យបរិបូណ៌មក, គេក៏បានសង់ទំនប់ទឹកមួយទៀតនៅឯតំបន់កូទ្រី ។ អាស្រ័យដោយមធ្យោបាយនេះ, គេក៏បានបង្កើតផលដំណាំស្រូវ និងកប្បាស ។ នៅក្នុងតំបន់នោះ គេឃើញមានទីក្រុងមួយយ៉ាងធំគឺ ការាជី ដែលជារដ្ឋធានីនៃប្រទេសប៉ាគីស្ថាន ។ តាំងពីពេលបានឯករាជ្យមក, ប្រជាជនក្នុងទីក្រុងនោះបានកើនឡើងជាលំដាប់ ដែលសព្វថ្ងៃមានប្រជាជនចំនួន ១.៣០០.០០០ នាក់ ។ ទីក្រុងនេះជាកំពង់ផែមួយយ៉ាងធំ និងជាមូលដ្ឋានអាកាសចរមួយយ៉ាងសម្បើម ។

ខ)– ប្រទេសប៉ាគីស្ថានខាងកើត : តំបន់នេះស្ថិតនៅតាមបណ្តោយបេនហ្គាល់ខាងកើត ជាតំបន់មានប្រជាជនច្រើនក្រៃលែង ( ៣៣០ មនុស្សក្នុង ១ គ.ម² ) ជាតំបន់សើមហើយមានដីជាតិណាស់ៗ គេច្រើនធ្វើផលដំណាំពីរដងក្នុងមួយឆ្នាំ ។ ផលដំណាំទីមួយគឺស្រូវ បន្ទាប់មកគឺធ្មៃ សម្រាប់ធ្វើបាវ ។

ទីក្រុងមិនសូវជាធំប៉ុន្មានទេ, មានទីក្រុងពីរដែលយើងត្រូវស្គាល់ គឺដាក្កា (Dacca) ដែលជាទីក្រុងរដ្ឋបាល មានប្រជាជនចំនួន ៤០០.០០០ នាក់ និងកំពង់ផែមួយហៅថាស៊ីតាហ្គុង (Chittagong) ។

គ)– អំពីបញ្ហាប្រទេសប៉ាគីស្ថាន : ប្រទេសប៉ាគីស្ថានជារដ្ឋប្រកបរបរកសិកម្ម ។ ក្នុងមួយឆ្នាំ ១ ប្រទេសប៉ាគីស្ថានធ្វើស្រូវបាន

ចំនួន ៨.០០០.០០០ តោន, ស្រូវសាលី ៣.០០០.០០០ តោន និង ក្រចៅ ៣/៤ នៃផលិតកម្មក្នុងសាកលលោក ។ មួយចំណែកទៀត, ប្រទេសប៉ាគីស្តង់បានធ្វើកប្បាសប្រកបដោយគុណភាពល្អក្រៃលែង និង មានដាំរុក្ខជាតិផ្សេង ៗ ដែលឲ្យប្រេង ។

ឧស្សាហកម្មពុំសូវចំរើនទេ ដោយប្រទេសនេះខ្វះធនធានខាង អណ្ដូងរ៉ែ ហើយបានចំបង្កើតតែឧស្សាហកម្មសម្រាប់ធ្វើកប្បាស, ធ្វើក្រចៅ, កេងចក្រធ្វើកប្បាស-ធ្វើក្រចៅ ។ ក្រៅពីនេះ ប្រទេសនេះក៏បាន ខិតខំបង្កើតកេងចក្រធ្វើជី, ធ្វើស៊ីម៉ង់ត៍ដែរ ដោយបានបង្កើតផែនការ៦ឆ្នាំ ដែលទើបតែនឹងចប់ ។ ប៉ុន្តែ ប្រទេសនេះមានឧបសគ្គមួយដ៏ធំ គឺថវិកា ជាតិភាគកណ្ដាលទុកសម្រាប់តែចិញ្ចឹមកងទ័ព ។ ដូច្នេះ ប្រទេសនេះ ត្រូវខ្វះមូលធនដើម្បីយកទៅបង្កើតកេងឧស្សាហកម្ម ពិតមែនតែសហរដ្ឋ អាមេរិកបានជួយជំនួយជាច្រើនក៏ដោយ ។ មានបញ្ហាដ៏លំបាកមួយទៀត ដែលត្រូវដោះស្រាយ គឺការប្រកួតប្រជែងគ្នារវាងប៉ាគីស្តង់ខាងកើតនឹង ប៉ាគីស្តង់ខាងលិច ។ ពួកប៉ាគីស្តង់ខាងលិចបានដណ្ដើមយកប៉ុស្តិ៍បញ្ជា-ការខ្វះពីប៉ាគីស្តង់ខាងកើត ហើយប្រជារាស្ត្រប៉ាគីស្តង់ខាងកើតបាន គក់ជាច្រើន ។

## អំពីសាធារណរដ្ឋឥណ្ឌា

សាធារណរដ្ឋឥណ្ឌាមានទំហំ ៣.០០០ ០០០ គ.ម២, ហើយមាន

ប្រជាជន ៣៦០.០០០.០០០ នាក់ គឺមាន ១២៦ មនុស្សក្នុង ១ គ.ម២ ។ ចំនួនមនុស្សក្នុង ១ គ.ម២ នេះ ឃើញថាច្រើនសមល្មម ចំពោះប្រទេសដែលប្រកបរបរកសិកម្ម ។ ឯកភាពជាតិពិបាកនឹងធ្វើណាស់ ។ សាធារណរដ្ឋឥណ្ឌាមានចែកជា ១៧ ខេត្ត ហើយខេត្តនីមួយ ៗ មានស្វយ័តភាពយ៉ាងធំទូលាយ ។ គឺជាសាធារណរដ្ឋ សហព័ន្ធ (République fédérale) ។ កន្លែងដែលសំខាន់ជាងគេនៃសហភាពឥណ្ឌា គឺវាលឥណ្ឌូគង្គា ។ វាលនេះប្រកបដោយដីមានជីជាតិ ។ ដំណាំទាំងឡាយមានធ្វើជាបន្ត ៗ គ្នាតាមលំដាប់នៃទឹកភ្លៀងធ្លាក់ ។ នៅបេនហ្គាល់ ពេលដីនៅសើមខ្លាំង, គេធ្វើរបរពីរដងក្នុងមួយឆ្នាំ, ដំបូងគេធ្វើស្រូវ, បន្ទាប់មកគេដាំអំពៅ លុះទឹករីងស្ងួតទៅវិញ ដំបូងគេធ្វើស្រូវម្យ៉ាងហៅថាមីយេ (Millet) រួចក្រោយមកគេធ្វើស្រូវសាលី ។

ដីវាលទាំងឡាយនៃទ្វីបដេក្កង់ ដែលស្ថិតនៅតាមឆ្នេរសមុទ្រជាដីសើម ។ អាចឲ្យគេធ្វើស្រូវ, ធ្វើសណ្តែកដី, ដាំកប្បាសបាន ហើយនៅត្រង់ទិសនិរតី គេមានដាំម្រេចផង ។

សារៈសំខាន់នៃសហភាពឥណ្ឌា ស្ថិតនៅត្រង់ប្រទេសនេះសម្បូណ៌ដោយសម្បត្តិអណ្តូងរ៉ែ ។ នៅត្រង់ខ្ពង់រាប (plateau) នៃឧបទ្វីបដេក្កង់, ឃើញមានម៉ង់ហ្គាណែសជាច្រើនក្រៃលែង (Manganèse) ដែលប្រទេសឥណ្ឌាជាប្រទេសលេខមួយក្នុងសាកលលោកក្នុងការនាំលោហ-

ជាតិនេះទៅលក់ឯបរទេសៗ នៅខាងជើងនៃដេកង់, គេឃើញមានអណ្តូងរ៉ែធ្យូងថ្ម នឹងអណ្តូងរ៉ែដែកជាច្រើនស្ថិតនៅជិតៗគ្នា (៣៩.០០០.០០០ តោនធ្យូងថ្ម) ។ អាស្រ័យដោយសម្បត្តិអណ្តូងរ៉ែនេះហើយ រោងឧស្សាហកម្មទាំងឡាយ ក៏អាចកើតឡើង គឺឧស្សាហកម្មនៃលោហកម្ម, នឹងឧស្សាហកម្មនៃគីមី ។ ក្រៅពីនេះ, ប្រទេសឥណ្ឌៀមានរោងចក្រខាងការត្បាញសំពត់មួយយ៉ាងធំក្នុងសាកលលោក , ប៉ុន្តែ រោងចក្រនេះធ្វើតែកប្បាសទេ, នឹងរោងចក្រធ្វើអម្បោះដ៏សំខាន់មួយទៀតនៅបុមបៃ ។ ទីក្រុងបុមបៃនេះមានប្រជាជន ៣ ០០០.០០០ នាក់, ហើយជាកំពង់ផែនៃប្រទេសផង ។

ផ្ទុយទៅវិញ កាល់គុត្តាជាទីក្រុងពិសេសខាងធ្វើដើមក្រចៅឲ្យទៅជាបាវ ។ ទីក្រុងនេះស្ថិតនៅជិតកន្លែងរ៉ែ ហើយជាកន្លែងធ្វើលោហធាតុផង ។ កាល់គុត្តាមានប្រជាជន ៦.០០០.០០០ នាក់ ស្ថិតនៅចម្ងាយ ៨០ គ.ម ពីសមុទ្រ, ជាប់នឹងដៃទន្លេគង្គា, ជាកំពង់ផែទីពីរនៃប្រទេស ។

### ការទាក់ទងគ្នារវាងប្រទេសទាំងពីរ
### (ប៉ាគីស្ថាននិងសហភាពឥណ្ឌៀ)

ពីដំបូង ការទាក់ទងគ្នារវាងប្រទេសទាំងពីរមានសភាពពុំសូវល្អទេ ។ ប្រទេសប៉ាគីស្ថាន ពុំព្រមលក់ក្រចៅទៅឲ្យរោងចក្រធ្វើអំបោះនៅឯកាល់គុត្តា ។ ជាពិសេសជម្លោះកើតមានកាន់តែធំឡើងចំពោះរឿងកាសីមៀរ

(Caehemire) ហើយសង្គ្រាមហៀបតែនឹងផ្ទុះឡើងជាច្រើនដង រវាងរដ្ឋទាំងពីរនេះ ។

ជាពិសេសទៅទៀត, គឺរដ្ឋទាំងពីរនេះរើសយកមាគ៌ានយោបាយក្រៅប្រទេសខុសពីគ្នាស្រឡះ ។ ប្រទេសប៉ាគីស្ថានដើរតាមក្រោយសហរដ្ឋអាមេរិក, ប្រទេសឥណ្ឌារើសយកនយោបាយអព្យាក្រឹត្យ មិនចូលនឹងបក្សខាងណាទាំងអស់ ។

ឥឡូវនេះ រដ្ឋទាំងពីរនេះមានការទាក់ទងគ្នាយ៉ាងប្រសើរ ។ ការយល់ព្រមចែកព្រំដែនទឹក គឺស្ទឹងទាំងឡាយក៏បានធ្វើឡើង ។ ស្ទឹងនេះមានប្រភពចេញមកពីសហភាពឥណ្ឌា ហើយអាចបញ្ចូលទឹកទៅក្នុងរដ្ឋប៉ាគីស្ថានបានត្រង់តំបន់បញ្ជាប់ ។

សេដ្ឋកិច្ចនៃប្រទេសទាំងពីរនេះគឺពឹងពាក់គ្នាទៅវិញទៅមក ។ ប្រទេសប៉ាគីស្ថានក្រខាងវត្ថុធាតុដើម អាចទិញធ្យូងថ្មនឹងដែកពីប្រទេសឥណ្ឌាបាន ចំណែកឯប្រទេសឥណ្ឌាទិញពីប្រទេសប៉ាគីស្ថានវិញ នូវផលិតផលខាងកសិកម្ម មានស្រូវនឹងស្រូវសាលីជាដើម ។

( ចប់ )

# លទ្ធផលនៃការប្រឡងប្រជែងអក្សរសាស្ត្រ នៃសមាគមអ្នកនិពន្ធខ្មែរ រង្វាន់ " ឥន្ទទេវី " ឆ្នាំ ១៩៦០-១៩៦១

ដោយសហជីវិន ទ្រិញ-ហ៊ាញ ប្រធានគណៈមេប្រយោគ

នៃសមាគមអ្នកនិពន្ធខ្មែរ

---

ការប្រឡងប្រជែងអក្សរសាស្ត្រទៅ រង្វាន់ " ឥន្ទទេវី " សម្រាប់ឆ្នាំ ១៩៦០ ទីង ១៩៦១ ដែលសមាគមអ្នកនិពន្ធខ្មែរ បានចាត់ចែងធ្វើនោះ បានលទ្ធផលដូចតទៅ ៖

## ក) ផ្នែកប្រលោមលោក – ( មានបេក្ខជន ៨៨ នាក់ )

រង្វាន់ទី ១– បានទៅលោក សួន-សុរិន្ទ ធ្វើការនៅព្រះរាជប្រតិភូស្ថានក្រុងភ្នំពេញ រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ។

រង្វាន់ទី ២– បានទៅលោក អ៊ឹម-ជុំ អ្នកតំណាងរាស្ត្រនៅរដ្ឋសភា ក្រុងភ្នំពេញ រឿងវ៉ែនណែត ។

រង្វាន់ទី ៣ បានទៅលោក ឈាយ-ហ៊ាង លេខាធិការនៅក្រុមអាជីវកម្ម រាជអាយស្វ័យយាន ក្រុងភ្នំពេញ រឿងជីវិតខ្ញុំ ។

## រង្វាន់លើកទឹកចិត្តមាន ៣ គឺៈ

១ បានទៅលោក គាយ-ហ៊ាងឌី ធ្វើការនៅទីចាត់ការអប់រំមូលដ្ឋានជាតិ ភ្នំពេញ រឿងភពរដ្ឋគិរ ។

២- បាននៅលោក គុយ-ឡុត លេខាធិការ នៅមន្ទីរពេទ្យកាល់ម៉ែត ភ្នំពេញ រឿងសែនគំរិសល់ ។

៣- បាននៅលោក សរ-ឡុច គ្រូបង្រៀននៅសាលាបឋមសិក្សាមោស ឃុំពោនម៉ាន ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង រឿងវាសនាយុវជន ។

១) ផ្នែកកវីនិពន្ធ–( មានបេក្ខជន ៨៧ នាក់ )

រង្វាន់ទី ១– បាននៅលោក ចាប-ពិន អធិបតីក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ កំណាព្យមានចំណងជើងថា : អធិប្បាយច្បាំសុភាសិត ។

រង្វាន់ទី ២- បាននៅលោក ជល-និត្យ ធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ កំណាព្យរឿងជនជា ។

រង្វាន់ទី ៣– បាននៅលោក ព៉ាង-សរ និស្សិតមន្ត្រីជាន់ខ្ពស់ នៅសាលាភូមិន្ទរដ្ឋបាល ភ្នំពេញ កំណាព្យរឿង ព្រះជីវប្រវត្តិ សម្តេច ព្រះនរោត្តម-សីហនុ ព្រះបិតាឯករាជ្យជាតិ ។

រង្វាន់លើកទឹកចិត្តមាន ៣ គឺ:

១– បាននៅលោក ឱម-ណាត្រី ធ្វើការនៅវិទ្យាស្ថានជាតិគរុកោសល្យ ភ្នំពេញ កំណាព្យ អក្សរសាស្ត្រ និងកវីខ្មែរ ។

២- បាទទៅលោក យូ-អ៊ុង ធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ កំណាព្យរឿង ធារធកស្សប ។

៣- បាទទៅលោក ញូង-សៀង លេខាធិការនៅពុទ្ធ-សាសនបណ្ឌិត្យភ្នំពេញ កំណាព្យ ការរលាយកពតែដងដី ដឹង កើតសារជាថ្មីឡើងវិញ ។

គ) ផ្នែករឿងល្ខោន- (មានបេក្ខជន ២០ នាក់)

រង្វាន់ទី១ (គ្មាន)

រង្វាន់ទី២- បានពីរគឺ :

១- បាទទៅលោក ជេង-ផុង ធ្វើគ្រូបង្រៀន ហើយជាអ្នកកំគន់វង់ល្ខោនព្រះរាជទ្រព្យ រឿងស៊ីកាឈើខ្វះ ផ្កាកាំផ្កាយតាំគល់ ។

២- បាទទៅលោក ជួង-កាង ធ្វើគ្រូបង្រៀន នៅមន្ទីរចាត់ការគរុកោសល្យ ភ្នំពេញ រឿងពិតជដងពពោះដង ។

រង្វាន់ទី ៣ មានពីរគឺ :

១- បាទទៅលោក លី-គីមអួង ធ្វើគ្រូបង្រៀន នៅមន្ទីរចាត់ការគរុកោសល្យ ភ្នំពេញ រឿងសោកលភាពត្រី ។

២- បាទទៅលោក តាំង-សេងគី អតីតសិស្សគរុវិជ្ជា រឿងវីរជនខ្មែរ ។

ឯពិធីប្រគល់រង្វាន់ដល់អស់លោកជ័យលាភី នឹងរៀបចំឡើងក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះប្រមុខរដ្ឋ ដែលទ្រង់ជាប្រធានកិត្តិយស នៃសមាគមអ្នកនិពន្ធខ្មែរនៅព្រះទីនាំងភោជនីយក្នុងព្រះបរមរាជវាំងចតុមុខ ភ្នំពេញ ។

កាលបរិច្ឆេទ នៃមហាបាតុកម្មផ្នែកវប្បធម៌នេះ នឹងមានជូនឲ្យបានជ្រាបនៅពេលខាងមុខ ។

ផ្នែកកំណត់ជីវប្រវត្តិការណ៍

## ពិធីសម្ពោធធម្មមន្ទីរ វត្តព្រះវិហារហ្លួង ឧត្តុង្គ

---

កាលពីថ្ងៃទី ១១ ខែមិថុនា គ. ស. ១៩៦១ សម្តេចព្រះរាជកនិដ្ឋារស្មីសោភ័ណ បានទ្រង់ស្តេចយាងជាព្រះអធិបតី នៃពិធីបុណ្យសម្ពោធធម្មមន្ទីរ វត្តព្រះវិហារហ្លួង ឃុំឧត្តុង្គ ស្រុកពញាឮ ខេត្តកណ្តាល ។ ធម្មមន្ទីរនេះ បានសាងឡើងពីឆ្នាំ ១៩៥៩ ដម្លៃ ៤៨៤.០០០៛០០ ជាស្នាព្រះហស្តនៃព្រះគ្រូមុនី ឆៀង-អ៊ុច ចៅអធិការវត្តនេះ ។ ក្នុងព្រះដំណើរនេះ ព្រះរាជវង្សានុវង្ស ជំទាវ នឹងឯកឧត្តម ឯកអគ្គរដ្ឋទូតនៃប្រទេសលាវ ព្រមទាំងឥស្សរជនដទៃទៀតជាច្រើន បានស្តេចយាង បានអញ្ជើញទៅរួមក្នុងពិធីនេះផង ។

នៅវេលាស្តេចយាងដល់ ទ្រង់បានទទួលនូវគារវកិច្ចអំពីសំណាក់ពុទ្ធបរិស័ទទាំងឡាយ ដែលមានលោក ប្រាក់-ម៉ៃ ជាតំណាងក្នុងបរិយាកាសដ៏សែនរីករាយ ។

លុះទ្រង់គង់ក្នុងទីដ៏សមគួរហើយ, លោក ប្រាក់-ម៉ៃ តំណាងគណៈកម្មការបុណ្យនឹងពុទ្ធបរិស័ទ បានថ្លែងសុន្ទរកថាមួយ សំដែងសេចក្តីត្រេកអរជាខ្លាំង ចំពោះសម្តេចព្រះរាជកនិដ្ឋារស្មីសោភ័ណាដែលទ្រង់បានស្តេច

យានមកជាព្រះអធិបតី នៃពិធីបុណ្យនេះ ព្រមទាំងបានរៀបរាប់អំពីជីវប្រវត្តិនៃវត្តនេះ ដែលសាងឡើងតាំងពីក្នុងរជ្ជកាលនៃព្រះករុណាព្រះអង្គអេង ហើយតែងបានទទួលនូវការឧបត្ថម្ភពីព្រះមហាក្សត្រទាំងឡាយព្រមទាំងព្រះរាជវង្សានុវង្ស រហូតដល់រជ្ជកាលនៃព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ នឹងសម្តេចព្រះមហាក្សត្រិយានី ជាព្រះមាតាជាតិនាបច្ចុប្បន្ននេះ ពុំដែលអាក់ខានឡើយ ។

នៅទីអវសាន សម្តេចព្រះរាជគនិដ្ឋារស្មីសោភ័ណ ទ្រង់បានដាំដើមពោធិព្រឹក្សពីរដើម នៅមុខ ឆម្មមណ្ឌីរ នោះ ជាកិច្ចបញ្ចប់ពិធីបុណ្យ ។

សូមបញ្ជាក់ថា វត្តព្រះវិហារហ្លួងនេះ ជាវត្តចាស់មួយ មានអាយុកាលដ៏វែង ហើយបានរក្សាទុកនូវប្រវត្តិនៃធម្មយុត្តិកនិកាយ តាំងពីកាលដែលកើតមាននៅក្នុងប្រទេសកម្ពុជា ហើយនឹងរក្សាទុកនូវគម្ពីរបាលី ក្បួនច្បាប់ផ្សេង ៗ តាំងពីសម័យនោះ រហូតមកដល់សម័យនេះ ជាបន្តបន្ទាប់ ។

ពុទ្ធសាសនបណ្ឌិត្យ សូមចូលរួមសំដែងសេចក្តីសោមនស្សជាអនេកប្បការ ចំពោះពិធីបុណ្យនេះ ហើយសូមប្រសិទ្ធិឲ្យវត្តនេះ មានអានុភាពទ្រទ្រង់ព្រះពុទ្ធសាសនាឲ្យបានស្ថិតស្ថេរបរកាលតទៅ ។

ពុទ្ធសាសនបណ្ឌិត្យ

---

## ពធបុណ្យនៅវត្តលង្កា

# ប្រគេន-ថ្វាយ សម្ដេចទាំងពីរព្រះអង្គ

---

ថ្ងៃទី ១០ មិថុនា ១៩៦១ នៅព្រះវិហារវត្តលង្កា ក្រុងភ្នំពេញ មានការជួបជុំពុទ្ធបរិស័ទជាច្រើន ក្រោមកិច្ចចាត់ចែងនៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ ធ្វើពិធីបុណ្យប្រគេនមហាកុសលចំពោះសម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ ដែលកំពុងព្យាបាលព្រះនេត្រ នៅប្រទេសបារាំង និងថ្វាយព្រះមហាកុសលចំពោះសម្ដេចព្រះប្រមុខរដ្ឋ ជាទីគោរព ជាទីស្នេហាស្មើជីវិតនៃយើង ដែលព្រះអង្គកំពុងព្យាបាលព្រះរោគ នៅប្រទេសបារាំង ព្រមទាំងទ្រង់កំពុងបំពេញព្រះរាជបេសកកម្ម នៅក្រុងហ្សឺណែវ រកសន្តិភាពជូនប្រទេសលាវ និងសាកលលោក ។

ថ្ងៃទី ១១ ខែឆ្នាំដដែល ម៉ោង ៩ ព្រឹក មានពិធីដាក់បាត្រព្រះសង្ឃ ១០០ អង្គ ចប់កិច្ចដាក់បាត្រ ព្រះសង្ឃស្វាធ្យាយពុទ្ធជ័យមង្គលប្រសិទ្ធពរ ប្រគេន-ថ្វាយ ចំពោះសម្ដេចទាំងពីរព្រះអង្គ សូមបាន, សូមទ្រង់បានសះស្បើយព្រះរោគ និងសូមទ្រង់បានជោគជ័យមហាប្រសើរក្នុងព្រះរាជបេសកកម្មដ៏សែនលំបាកនេះ ។

ពិធីនេះបានចប់សព្វគ្រប់នៅវេលាម៉ោង ១០, ៣០ នាទីព្រឹក ។

ពុទ្ធសាសនបណ្ឌិត្យសូមចូលរួមក្នុងពិធីបុណ្យនេះ ដោយកតញ្ញុតាព ។

ពុទ្ធសាសនបណ្ឌិត្យ